# ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ២០២២

## កម្ពុជា បង្ហាញឆន្ទៈ
## ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក្រោយក្រុមជនល្មើស ប្រើទឹកដីកម្ពុជាប្រព្រឹត្តបទល្មើស

https://dap-news.com/national/2022/11/29/296070/ BySS107Posted on November 29, 2022

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រាប់មិត្តចិនថា រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនក្រោយពីក្រុមជនល្មើសប្រើប្រាស់ទឹកដីប្រទេសកម្ពុជាធ្វើជាទីតាំងប្រព្រឹត្តបទល្មើស តាមរយៈទាក់ទងជាមួយមេក្លោងជាជនជាតិបរទេសដូចគ្នា។ ក្នុងពិធីទទួល មេដាយមាសអនុស្សាវរីយ៍មហាកំពែង ពីប្រទេសចិន នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ សម្តេច ស ខេង បានគូសបញ្ជាក់អំពីការវិវត្តនៃស្ថានភាពសន្តិសុខ ក្នុងរយៈពេលប្រមាណ ២ឆ្នាំ ចុងក្រោយនេះ ដោយឃើញថា ថ្វីត្បិតវិធានការរឹតបន្តឹងការធ្វើដំណើរ និងការបម្លាស់ទី ត្រូវបានអនុវត្តជាសកលដើម្បីទប់ស្កាត់ជំងឺរាតត្បាតកូវីដ-១៩ ក៏ប៉ុន្តែបទល្មើសឆ្លងដែន មិនត្រឹមតែមិនបានថមថយប៉ុណ្ណោះទេ តែផ្ទុយទៅវិញបែរជាមានការ កើនឡើងគួរឱ្យព្រួយបារម្ភ។ សម្តេច បន្តថា ទន្ទឹមនេះ ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន បានផ្តល់លទ្ធភាពដល់ឧក្រិដ្ឋជនក្នុងការប្រើប្រាស់មធ្យោបាយនេះ ដើម្បីធ្វើសកម្មភាពប្រព្រឹត្តបទល្មើសឆ្លងដែន ជាពិសេសអំពើជួញដូរ និងរត់ពន្ធមនុស្ស ការជួញដូរគ្រឿងញៀន និងអំពើឆបោកតាមប្រព័ន្ធទូរគមនាគមន៍ (ឬហៅថា Scam) និងបទល្មើសមិនប្រពៃណីមួយចំនួនទៀត។

ពាក់ព័ន្ធនឹងនិន្នាការនៃបទល្មើសទាំងនេះ សម្តេច ស ខេង បានសង្កត់ធ្ងន់ថា «ប្រទេសកម្ពុជាក៏ទទួលរងគ្រោះ ដោយសារក្រុមជនល្មើសជាជនបរទេសបានប្រើប្រាស់ទឹកដីកម្ពុជា ធ្វើជាទីតាំងប្រព្រឹត្តបទល្មើស តាមរយៈការទាក់ទងជាមួយមេក្លោងជាជនជាតិបរទេសដូចគ្នា នៅក្នុង និងក្រៅប្រទេសរបស់ខ្លួន ធ្វើការឆបោក និងអូសទាញជនរងគ្រោះឱ្យចូលមកប្រទេសកម្ពុជា ទាំងស្របច្បាប់ និងមិនស្របច្បាប់ ក្រោមការសន្យាក្លែងក្លាយនូវការងារដែលទទួលបានប្រាក់កម្រៃខ្ពស់»។ លើសពីនេះ សម្តេច ឧបនាយករដ្ឋមន្ត្រី បានបន្តទៀតថា «រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនមានអង្គការចាត់តាំងគ្រប់ប្រភេទ រាប់ទាំងអំពើជួញដូរ និងរត់ពន្ធមនុស្ស ហើយបញ្ហានេះមិនអាចប្រទេសណាមួយអនុវត្តតែឯកឯងបាននោះទេ គឺទាមទារចាំបាច់នូវកិច្ចសហការទាំងនៅក្នុងកម្រិតតំបន់ និងសកលលោក ដើម្បីដោះស្រាយបញ្ហាប្រឈមជាសកលនេះ»៕

## ការវិវត្តយ៉ាងរហ័សនៃបច្ចេកវិទ្យាព័ត៌មានផ្តល់លទ្ធភាពដល់ឧក្រិ.ដ្ឋជនក្នុងការប្រើ មធ្យោបាយធ្វើសកម្មភាពបទល្មើសឆ្លងដែន

https://kohsantepheapdaily.com.kh/article/1643300.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២២ ម៉ោង ១១:១០

រាជធានីភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានគូសបញ្ជាក់ថា ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មានបានផ្តល់លទ្ធភាពដល់ឧក្រិ.ដ្ឋជនក្នុងការប្រើប្រាស់មធ្យោបាយនេះដើម្បីធ្វើសកម្មភាពប្រព្រឹត្តបទល្មើសឆ្លងដែន។ ការបញ្ជាក់របស់សម្តេចក្រឡា ហោម ធ្វើឡើង ខណៈអញ្ជើញចូលរួមទទួលមេដាយមាស Great Wall Commemorative Medal តាមប្រព័ន្ធវីដេអូក្នុងសន្និសីទលើកទី១ នៃវេទិកាកិច្ចប្រតិបត្តិការសន្តិសុខសាធារណៈសកលនៅទីស្តីការក្រសួងមហាផ្ទៃកាលពីរសៀលថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ២០២២។ យោងតាមបណ្តាញសង្គមផ្ទាល់ខ្លួនរបស់សម្តេច ស ខេង បានលើកថា បានគូសបញ្ជាក់អំពីការវិវត្តនៃស្ថានភាពសន្តិសុខក្នុងរយៈពេលប្រមាណ២ឆ្នាំចុងក្រោយនេះដោយយើងឃើញថា ថ្វីត្បិតវិធានការរឹតបន្តឹងការធ្វើដំណើរ និង

ការបម្លាស់ទីត្រូវបានអនុវត្តជាសកល ដើម្បីទប់ស្កាត់ជំងឺរាតត្បាតកូវីដ-១៩ ក៏ប៉ុន្តែបទល្មើសឆ្លងដែនមិនត្រឹមតែមិនបានថមថយប៉ុណ្ណោះទេ តែផ្ទុយទៅវិញបែរជាមានការកើនឡើងគួរឱ្យព្រួយបារម្ភ។

សម្តេចបន្តថា៖«ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មានបានផ្តល់លទ្ធភាពដល់ឧក្រិ.ដ្ឋជនក្នុងការប្រើប្រាស់មធ្យោបាយនេះ ដើម្បីធ្វើសកម្មភាពប្រព្រឹត្តបទល្មើសឆ្លងដែន ជាពិសេសអំពើជួញដូរ និងរត់ពន្ធមនុស្ស ការជួញដូរគ្រឿងញៀ.ន និងអំពើឆបោកតាមប្រព័ន្ធទូរគមនាគមន៍ (ឬហៅថា Scam) និងបទល្មើសមិនប្រពៃណីមួយចំនួនទៀត»។ ពាក់ព័ន្ធនឹងនិន្នាការនៃបទល្មើសទាំងនេះ សម្តេចបានសង្កត់ធ្ងន់ថា ប្រទេសកម្ពុជាក៏ទទួលរងគ្រោះដោយសារក្រុមជនល្មើស ជាជនបរទេសបានប្រើប្រាស់ទឹកដីកម្ពុជា ធ្វើជាទីតាំងប្រព្រឹត្តបទល្មើសតាមរយៈការទាក់ទងជាមួយមេក្លោងជាជនជាតិបរទេសដូចគ្នានៅក្នុង និងក្រៅប្រទេសរបស់ខ្លួនធ្វើការឆបោក និងអូសទាញជនរងគ្រោះឱ្យចូលមកប្រទេសកម្ពុជាទាំងស្របច្បាប់ និងមិនស្របច្បាប់ក្រោមការសន្យាក្លែងក្លាយនូវការងារដែលទទួលបានប្រាក់កម្រៃខ្ពស់។

យ៉ាងណាក្តី សម្តេចក្រឡាហោមបានអះអាងថា រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងឧក្រិ.ដ្ឋកម្មឆ្លងដែនមានអង្គការចាត់តាំងគ្រប់ប្រភេទរាប់ទាំងអំពើជួញដូរ និងរត់ពន្ធមនុស្ស ហើយបញ្ហានេះមិនអាចប្រទេសណាមួយអនុវត្តតែឯកឯងបាននោះទេ គឺទាមទារចាំបាច់នូវកិច្ចសហការទាំងនៅក្នុងកម្រិតតំបន់ និងសកលលោក ដើម្បីដោះស្រាយបញ្ហាប្រឈមជាសកលនេះ។

សូមជម្រាបថាវេទិកា Liaryurgarg ត្រូវបានបង្កើតឡើងតាមសំណើរបស់ក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិននៅទីក្រុង Lianyungang នៃខេត្ត Jiangsu កាលពីឆ្នាំ២០១៥ និងជាវេទិកាសម្រាប់កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការដែលមាន «កិច្ចសហការសន្តិសុខដើម្បីវិបុលភាពរួម» ជាតម្លៃស្នូល។ វេទិកានេះ មានគោលដៅកម្ពស់កិច្ចសហប្រតិបត្តិការលើការអនុវត្តច្បាប់ និងសន្តិសុខសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកជាមួយនឹងការគិតគូរប្រកបដោយភាពច្នៃប្រឌិត និងវិធានការជាក់ស្តែងដោយមានការចូលរួមគ្នាការកសាង និងការគ្រប់គ្រងរបស់មន្ត្រីជាន់ខ្ពស់មកពីរដ្ឋាភិបាល និងអង្គការអន្តរជាតិ មន្ត្រីអនុវត្តច្បាប់ និងកងកម្លាំងនគរបាល អ្នកដឹកនាំអាជីវកម្ម និងអ្នកជំនាញប្រឹក្សាយោបល់៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៦ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ៨នាក់

http://freshnewsasia.com/index.php/en/localnews/267802-2022-11-29-08-40-19.html 2022-11-29 03:40pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៧ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៦ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេសចំនួន ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ០៦ករណី គឺស្នើឱ្យសង្គ្រោះជនជាតិចិនចំនួន ៨នាក់ និងវៀតណាម ១នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦២០ករណី មានមនុស្ស ១,៥៣០នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៣៦សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៤៧នាក់, ឃាត់ខ្លួនជនសង្ស័យ ៩០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៤៧ករណី។

សូមបញ្ជាក់ថា សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្ដឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ៤នាក់

http://freshnewsasia.com/index.php/en/localnews/267886-2022-11-30-02-55-59.html 2022-11-30

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេសចំនួន ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ០៣ករណី គឺស្នើឱ្យសង្គ្រោះជនជាតិចិនចំនួន ២នាក់ និងវៀតណាម ២នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៦២២ករណី មានមនុស្ស ១,៥៣៣នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៣៦សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៤៧នាក់, ឃាត់ខ្លួនជនសង្ស័យ ៩០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៤៩ករណី។

សូមបញ្ជាក់ថា សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# រដ្ឋមន្ត្រីការងារ៖ ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន នឹងរួមចំណែកលើកកម្ពស់សិទ្ធិការងារពលករទេសន្តរប្រវេសន៍

https://www.kampucheathmey.com/local-news/422563 ថ្ងៃពុធ ៣០ វិច្ឆិកា ២០២២ដោយ Sokhom Khon

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ទុកក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ជាក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា នឹងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធិភាពនៃការការពារការលើកកម្ពស់សិទ្ធិការងារពលករទេសន្តរប្រវេសន៍។ ថ្លែងក្នុងពិធីចុះហត្ថលេខាលើក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បងនៃការអនុវត្តក្រមសីលធម៌សម្រាប់ទីភ្នាក់ជ្រើសរើសឯកជនកម្ពុជានៅសណ្ឋាគារ សាន់វ៉េ នៅព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា នេះ លោករដ្ឋមន្ត្រីមានប្រសាសន៍ថា ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាក៏ជាឧបករណ៍មួយកំណត់នូវគោលការណ៍គ្រឹះជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់អនុវត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រងការជ្រើសរើស ការបណ្តុះបណ្តាលការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស។ លើសពីនេះ ក្រមសីលធម៌នេះនឹងរួមចំណែកពង្រឹងប្រសិទ្ធិភាពនៃការការពារការលើកកម្ពស់សិទ្ធិការងារ ក៏ដូចជាសុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេសនិងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារៈប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍អាចបញ្ជាក់បានអំពីការរំពឹងទុករបស់ពលករពីទីភ្នាក់ងារជ្រើសរើសឯកជនដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តរប្រវេសន៍ការងាររបស់ពួកគេ។

សូមរំលឹកថា ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងប្រព័ន្ធវាយតម្លៃសាកល្បងនៃការអនុវត្តក្រមសីលធម៌ទទួលបានការគាំទ្រជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ ILO សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA) និងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា( MAC) ដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹងស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ លោករដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ដែលបានទទួលអាជ្ញាបណ្ណពីក្រសួង ចូលរួមក្នុងការអនុវត្តនូវក្រមសីលធម៌ដ៏មានសារសំខាន់នេះដើម្បីបង្ហាញឱ្យឃើញការបេជ្ញាចិត្តខ្ពស់របស់ខ្លួនក្នុងការការពារសិទ្ធ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ។ លោករដ្ឋមន្ត្រី បានបន្តថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងខិតខំបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគីដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់ នៅក្រៅប្រទេស ទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់ អំពើជួញដូរមនុស្ស,លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ,កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ,ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស, ការផ្តល់ប្រឹក្សាការងារធ្វើនិងការបង្កើតមុខរបរ ដោយខ្លួនឯង។

លោករដ្ឋមន្ត្រីបានបន្ថែមថា បច្ចុប្បន្នប្រទេសកម្ពុជាមានពលករធ្វើការនៅបរទេសសរុបចំនួនប្រមាណជាង១លាន២សែននាក់និងបានផ្ញើរថវិកាមកកម្ពុជាដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗហើយនៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិពីព្រោះតាមរយៈ ការធ្វើការងារនៅបរទេសពួកគាត់មិន

ត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទទួលបាននូវជំនាញបទពិសោធន៍ ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការគាំពារការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើងនៅបរទេសតាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានាដោយប្រើប្រាស់គោលការណ៍យន្តការ និងនីតិវិធីជាធរមាន។ ជាមួយគ្នានេះដែរ លោករដ្ឋមន្ត្រីបានសម្តែងនូវការអបអរសាទរ ចំពោះ"សេចក្តីថ្លែងការណ៍អាស៊ានស្តីពីចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសក៍ក្នុងតំបន់អាស៊ាន" ដែលជាគំនិតផ្តួចផ្តើមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងអាណត្តិកម្ពុជាជាប្រធានអាស៊ាន ២០២២ ទើបតែទទួលបានការអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១។ លោករដ្ឋមន្ត្រីចាត់ទុកថា នេះជាសមិទ្ធិផលដ៏សំខាន់មួយទៀតរបស់អាស៊ាន និងជាការបោះជំហានដ៏ធំឆ្ពោះទៅកាន់ការធ្វើចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសក៍អាស៊ានស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍ និងឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍៕ អត្ថបទ៖ សំអឿន

## ក្រសួងការងារ នឹងបង្កើនការផាកពិន័យពី១ដល់៥ដងចំពោះនិយោជកណាប្រើប្រាស់ហត្ថពលកម្មបរទេសខុសច្បាប់

https://www.kampucheathmey.com/local-news/422765 ថ្ងៃពុធ ៣០ វិច្ឆិកា ២០២២ Sokhom Khon

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា ក្រសួងការងារនឹងបង្កើនការផាកពិន័យពី១ដល់៥ដងចំពោះនិយោជកណាដែលបានប្រើប្រាស់ហត្ថពលកម្មបរទេសខុសច្បាប់ដែលនេះជាវិធានការមួយចូលរួមទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជា។ ថ្លែងក្នុងពិធីចុះហត្ថលេខាលើក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងពិធីសម្ពោធផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បងនៅព្រឹកថ្ងៃទិ៣០ ខែវិច្ឆិកា លោករដ្ឋមន្ត្រីបានបន្តថា «ខ្ញុំសូមក្រើនរំលឹកថា ការប្រើប្រាស់ហត្ថពលកម្មបរទេសនៅកម្ពុជាត្រូវតែធ្វើឱ្យបានត្រឹមត្រូវដោយស្របច្បាប់បើមិនដូច្នេះទេ នឹងត្រូវទទួលនូវការផាកពិន័យ និងចាត់វិធានការតាមផ្លូវច្បាប់។ រឿងពលកម្មដោយបង្ខំការជួញដូរមនុស្សការបង្ហាំងមនុស្សដើម្បីបម្រើឱ្យស្ថានភាពផ្សេងៗរបស់ខ្លួនជាលក្ខណៈឯកជនត្រូវតែបង្ក្រាបជាដាច់ខាត និងចាត់វិធានការតាមច្បាប់»។

លោករដ្ឋមន្ត្រីបានបន្តទៀតថា គណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សដែលមានសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធានបានកំពុងខិតខំដោះស្រាយបញ្ហាជួញដូរនេះ។ លោករដ្ឋមន្ត្រីបានបន្ថែមថា ចំណែកក្រសួងការងារនឹងបង្កើនការផាកពិន័យ១ដល់៥ដងដល់និយោជកទាំងឡាយណាប្រើប្រាស់ហត្ថពលកម្មបរទេសខុសច្បាប់ ដែលពីមុនផាកតែ២ទៅ៣លានទេ ឥឡូវត្រូវគុណ៥ទៅ៦ដងដែលនេះគឺជាវិធានការមួយទប់ស្កាត់អំពើជួញដូរមនុស្ស អំពើឧក្រិដ្ឋកម្មណាមួយពាក់ព័ន្ធនឹងការជួញដូរមនុស្សនៅកម្ពុជា។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា កម្ពុជាមិនមែនត្រឹមតែបង្កលក្ខណៈឱ្យបងប្អូនពលករទៅធ្វើការនៅក្រៅប្រទេសប៉ុណ្ណោះទេហើយកម្ពុជាក៏មានទទួលពលករបរទេសដែរ ហើយក្លាយជាប្រទេសទទួលពលករបរទេសជាបណ្តើរៗហើយក៏មានបញ្ហាមួយចំនួនកំពុងដោះស្រាយដែរ។ លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា «អីចឹងយើងបញ្ជូនពលករទៅក្រៅប្រទេសក៏ឱ្យបានត្រឹមត្រូវនិងតម្លាភាពតាមច្បាប់និងការពារសិទ្ធិពលករតែពលករបរទេសចូលមកធ្វើការនៅខាងក្នុងប្រទេសក៏ត្រូវទទួលបានការការពារសិទ្ធិនិងអនុវត្តត្រឹមត្រូវតាមច្បាប់ផងដែរ»។ លោករដ្ឋមន្ត្រីបានឱ្យដឹងទៀតថា កន្លងមកអនុសាសន៍របស់សហរដ្ឋអាមេរិកទាក់ទងនឹងការជួញដូរមនុស្សក៏មានលើកឡើងពីចំណុច

ទាក់ទិននឹងការជ្រើសរើសពលករទេសន្តប្រវេសន៍នេះដែរក៏បានលើកឡើងពីបញ្ហានេះដែរ។ដូចនេះយើងត្រូវខិតខំធ្វើការងារនេះ។

លោករដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា «ខ្ញុំនិយាយនេះមិនមែនមានន័យថា យើងត្រូវខិតខំធ្វើផ្គាប់ចិត្តមិត្តភក្តិណាមួយនោះទេ។ ប៉ុន្តែបើមានរឿងនេះវាជាអកុសលសម្រាប់យើង ហើយយើងទាំងអស់គ្នាគ្មាននរណាចង់ឱ្យមានបញ្ហានឹងកើតឡើងទេ ហើយក៏មិនចង់ឃើញការរំលោភបំពានឬការកេងប្រវ័ញ្ចណាមួយទៅលើបងប្អូនពលករទេសន្តប្រវេសន៍ទេ»។ គួរបញ្ជាក់ថា គិតចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២២ ក្រុមការងារអធិការកិច្ចហត្ថពលកម្មបរទេសបានចុះត្រួតពិនិត្យ គោលដៅចំនួន ៣.០៨០ គោលដៅត្រួតពិនិត្យពលករបរទេសចំនួន ៣០.៨៣៤នាក់ ព្រមទាំងបានផាកពិន័យជនបរទេសគ្មានបណ្ណការងារចំនួន ២.៤១៦នាក់៕ អត្ថបទ៖ សំអឿន

## កម្ពុជា មានពលករជាង១លាន២សែននាក់ ធ្វើការនៅក្រៅប្រទេស

https://kohsantepheapdaily.com.kh/article/1643824.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២២ ម៉ោង ១៩:២៤

រាជធានីភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានគូសបញ្ជាក់ថា ក្រមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា រួមចំណែកពង្រឹងប្រសិទ្ធិភាព នៃការការពារ ការលើកកម្ពស់សិទ្ធិការងារពលករទេសន្តប្រវេសន៍ខ្មែរយើង នៅបរទេស ។ ថ្លែងក្នុងពិធីចុះហត្ថលេខា លើក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បង នៃការអនុវត្តក្រមសីលធម៌សម្រាប់ទីភ្នាក់ជ្រើសរើសឯកជនកម្ពុជា ធ្វើឡើងនៅសណ្ឋាគារ សាន់វេ នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ទុកក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ជាឧបករណ៍មួយកំណត់ នូវគោលការណ៍គ្រឹះ ជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិសម្រាប់ទីភ្នាក់ងារ ជ្រើសរើសឯកជនកម្ពុជាទាំងអស់ អនុវត្តប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ ក្នុងការគ្រប់គ្រងការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស ។

ឯកឧត្តមបញ្ជាក់ថា ៖ «ក្រមសីលធម៌នេះ នឹងរួមចំណែកពង្រឹងប្រសិទ្ធិភាព នៃការការពារ ការលើកកម្ពស់សិទ្ធិការងារ ក៏ដូចជាសុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេស ។ លើសពីនេះទៀត ក្រមសីលធម៌នេះ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារប្រយោជន៍ សម្រាប់ពលករទេសន្តប្រវេសន៍ អាចបញ្ជាក់បានអំពីការរំពឹងទុករបស់ពលករពីទីភ្នាក់ងារជ្រើសរើសឯកជន ដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តប្រវេសន៍ការងាររបស់ពួកគេ» ។ ឯកឧត្តមបន្តថា ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងប្រព័ន្ធ វាយតម្លៃសាកល្បង នៃការអនុវត្តក្រមសីលធម៌ ទទួលបានការគាំទ្រជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិ ខាងការងារ ILO សមាគម ACRA និងសមាគម MAC ដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹង ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ ដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ជាមួយគ្នានោះដែរ ឯកឧត្តមរដ្ឋមន្ត្រី បានលើកទឹកចិត្ត អោយទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ដែលបានទទួលអាជ្ញាបណ្ណពីក្រសួង ចូលរួមក្នុងការអនុវត្តនូវក្រមសីលធម៌ ដ៏មានសារសំខាន់នេះ ដើម្បីបង្ហាញឲ្យឃើញការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួនក្នុងការការពារសិទ្ធ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ ។

ឯកឧត្តមរដ្ឋមន្ត្រី មានប្រសាសន៍បន្តថា ក្រសួងការងារ បាននិងកំពុងខិតខំបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស, ទប់ស្កាត់ទេសន្តរប្រវេសន៍ ការងារដោយខុសច្បាប់ អំពើជួញដូរមនុស្ស, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារនិងការផ្ញើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្តតាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេរបេបសន្តិសុខសង្គ មមកក្នុងប្រទេស, ការផ្តល់ប្រឹក្សាការងារធ្វើ និងការបង្កើតមុខរបរ ដោយខ្លួនឯង ។

ឯកឧត្តមបានលើកឡើងថា បច្ចុប្បន្នប្រទេសកម្ពុជា មានពលករសរុបចំនួនប្រមាណជាង ១លាន ២សែននាក់ ។ បើតាមការប៉ាន់ស្មានពលករកម្ពុជា បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញពួកគាត់នឹងក្លាយជាធនធាន មនុស្សដ៏សំខាន់ ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈ ការធ្វើការងារនៅបរទេស ពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទទួលបាននូវជំនាញបទពិសោធន៍ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការគាំពារការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើង នៅបរទេស តាមរយៈកិច្ចសហប្រតិបត្តិការ ជាមួយរដ្ឋាភិបាលនៃប្រទេសទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានាដោយប្រើ ប្រាស់គោលការណ៍ យន្តការ និងនីតិវិធីជាធរមាន៕

## រដ្ឋមន្ត្រីការងារជំរុញទីភ្នាក់ងារដែលជ្រើសរើស-នាំពលករ ទៅធ្វើការនៅក្រៅប្រទេស ត្រូវការពារសិទ្ធិ និងផលប្រយោជន៍ពលករ

http://freshnewsasia.com/index.php/en/localnews/267912-2022-11-30-06-20-00.html 2022-11-30

**(ភ្នំពេញ)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានជំរុញឱ្យទីភ្នាក់ងារឯកជនទាំងឡាយដែលជ្រើសរើស បណ្តុះបណ្តាល គ្រប់គ្រង និងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស ត្រូវការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការគាំពារពលករខ្មែរនៅបរទេស។ ការជំរុញបែបនេះធ្វើឡើងថ្លែងក្នុងពិធីចុះហត្ថលេខាលើក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បង នៃការអនុវត្តក្រមសីលធម៌សម្រាប់ទីភ្នាក់ជ្រើសរើស ឯកជនកម្ពុជា នៅសណ្ឋាគារសាន់វ៉េ នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។

លោក អ៊ិត សំហេង បានចាត់ទុកក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ជាឧបករណ៍មួយកំណត់នូវគោលការណ៍គ្រឹះជាមូលដ្ឋានស្របតាមច្បាប់ជាតិ និងបទដ្ឋានការងារអន្តរជាតិសម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាទាំងអស់អនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការទទួលខុសត្រូវ និងគោរពក្រមសីលធម៌ខ្ពស់ក្នុងការគ្រប់គ្រង ការជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងការគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស។ ក្រមសីលធម៌នេះនឹងរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការការពារ ការលើកកម្ពស់សិទ្ធិការងារ ក៏ដូចជាសុខុមាលភាពរបស់ពលករទាំងនៅក្នុងស្រុក និងនៅបរទេស។ លើសពីនេះទៀត ក្រមសីលធម៌នេះនឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រកបដោយគណនេយ្យភាពផង ហើយក៏ជាប្រភពដែលមានសារៈប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍ អាចបញ្ជាក់បានអំពីការរំពឹងទុករបស់ពលករ ពីទីភ្នាក់ងារជ្រើសរើស ឯកជនដែលទាក់ទងទៅនឹងបទពិសោធន៍ទេសន្តរប្រវេសន៍ការងាររបស់ពួកគេ។

ក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងប្រព័ន្ធវាយតម្លៃសាកល្បងនៃការអនុវត្តក្រមសីលធម៌ទទួលបានការគាំទ្រជំនួយបច្ចេកទេស និងកិច្ចសហប្រតិបត្តិការពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការអន្តរជាតិខាងការងារ ILO សមាគម ACRA និងសមាគម MAC ដើម្បីផ្សព្វផ្សាយ និងបង្កើនការយល់ដឹងស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ លោករដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ដែលបានទទួលអាជ្ញាបណ្ណពីក្រសួងចូលរួមក្នុងការអនុវត្តនូវក្រមសីលធម៌ដ៏មានសារសំខាន់នេះ ដើម្បីបង្ហាញឱ្យឃើញការបេជ្ញាចិត្តខ្ពស់របស់ខ្លួនក្នុងការការពារសិទ្ធ និងផលប្រយោជន៍ស្របច្បាប់របស់ពលករ។ លោករដ្ឋមន្ត្រីបានបន្តថា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបាននិងកំពុងខិតខំបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស, ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់អំពើជួញដូរមនុស្ស, លើកកម្ពស់ការគាំពារសិទ្ធិនិងផលប្រយោជន៍ សុខភាពនិងសុវត្ថិភាពការងារ, កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ពលករ, ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស, ការផ្តល់ប្រឹក្សាការងារធ្វើ និងការបង្កើតមុខរបរដោយខ្លួនឯង។

បើតាមលោករដ្ឋមន្ត្រី អ៊ិត សំហេង បច្ចុប្បន្នប្រទេសកម្ពុជាមានពលករសរុបចំនួនប្រមាណជាង១លាន២សែននាក់។ បើតាមការប៉ាន់ស្មានពលករកម្ពុជាបានផ្ញើថវិកាមកកម្ពុជាដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ ពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈការធ្វើការងារនៅបរទេស ពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទទួលបាននូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុតក្នុងការគាំពារការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរនៅបរទេស តាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានាដោយប្រើប្រាស់គោលការណ៍ យន្តការ និងនីតិវិធីជាធរមាន៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១៥ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ២៥នាក់

http://freshnewsasia.com/index.php/en/localnews/268044-2022-12-01-05-10-58.html 2022-12-01

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ១៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេសចំនួន ២៥នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ១៥ករណី គឺស្នើឱ្យសង្គ្រោះជនជាតិចិនចំនួន ៩នាក់, ជនជាតិឥណ្ឌូនេស៊ីចំនួន ៦នាក់ និងវៀតណាម ១០នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៣០ករណី មានមនុស្ស ១,៥៤៨នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៣៨សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៤៩នាក់, ឃាត់ខ្លួនជនសង្ស័យ ៩០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៥៥ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ០៧ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ០៩នាក់

http://freshnewsasia.com/index.php/en/localnews/268256-2022-12-03-00-49-10.html 2022-12-03

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៧ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេសចំនួន ០៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ បានឱ្យដឹងថា សំណើទាំង ០៧ករណី គឺស្នើឱ្យសង្គ្រោះជនជាតិចិនចំនួន ០៣នាក់, ជនជាតិឥណ្ឌូនេស៊ីចំនួន ០៣នាក់ និងវៀតណាម ០៣នាក់។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៣៥ករណី មានមនុស្ស ១,៩៥៥នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៤០សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៥១នាក់, ឃាត់ខ្លួនជនសង្ស័យ ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៥៨ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០២២

## កម្ពុជាមានទីភ្នាក់ងារជ្រើសរើសពលករជាង ១០០ នៅទូទាំងប្រទេស

https://www.kampucheathmey.com/local-news/424277 ថ្ងៃសៅរ៍ ៣ ធ្នូ ២០២២ដោយ Dy Bunnara

លោក យូ ជីតារ៉ា តំណាងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានលើកឡើងថា បច្ចុប្បន្ននេះនៅកម្ពុជាមានទីភ្នាក់ងារជ្រើសរើសពលករឯកជនប្រមាណជាង ១០០ ដែលបានចុះបញ្ជីផ្លូវការនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លោកបានប្រាប់កម្ពុជាថ្មីនៅព្រឹកថ្ងៃទី០៣ធ្នូនេះថា ក្នុងចំណោមទីភ្នាក់ងារពលករជាង១០០ ក្នុងនោះមានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ជប៉ុន សិង្ហបុរី ហុងកុង ម៉ាឡេស៊ី និងអារ៉ាប៊ីតសាអូឌីតជាដើម។ ចំណែកប្រទេសកូរ៉េខាងត្បូងវិញជ្រើសរើសតាមរយៈរាជរដ្ឋាភិបាលទេ។ លោកបានបន្តថា បច្ចុប្បន្ននេះសមាគមកំពុងជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលករ ប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បងនៃក្រមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាដោយខ្លួនឯង ដើម្បីវាយតម្លៃពីសកម្មភាពការងាររបស់ខ្លួនទាំងផ្លូវច្បាប់ ដំណើរការជ្រើសរើស ការគ្រប់គ្រង ការគាំពារនិងការបញ្ជូនពលករនៅក្រៅប្រទេស។ ព្រោះថានៅពេលដែលក្រុមហ៊ុនណាមួយជាប់ក្នុងការវាយតម្លៃល្អនោះ វានឹងជួយធ្វើឱ្យក្រុមហ៊ុនមានកេរ្តិ៍ល្អ ស្អាតស្អំនិងមានតម្លាភាពទាក់ទាញពលករក៏ដូចជាដៃគូក្រុមហ៊ុននៅក្រៅប្រទេសមកទំនាក់ទំនងការងារកាន់តែច្រើនថែមទៀត។ លោកបានបន្តទៀតថា មានទីភ្នាក់ងារប្រមាណ១០ប៉ុណ្ណោះ បានកំពុងចូលរួមអនុវត្តប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បងនៃក្រមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ខណៈមានក្រុមហ៊ុនប្រមាណជាង ៩០ទៀតនៅមិនទាន់បានចូលរួមនៅឡើយទេ។

លោក បណ្ឌិត អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក៏បានលើកទឹកចិត្តដល់ទីភ្នាក់ងារដែលមិនទាន់បានចូលរួមប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បងនៃក្រមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ចូលរួមឱ្យបានគ្រប់ៗគ្នាដើម្បីផ្តល់ទំនុកចិត្តនិងភាពជឿជាក់ក្នុងការជ្រើសរើសពលករនិងបញ្ជូនពលករកាន់តែប្រសើរថែមទៀត។ លោករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ការពិតទីភ្នាក់ងារជ្រើសរើសពលករនៅពេលទទួលបានអាជ្ញាប័ណ្ណពីក្រសួងការងារមានភ្ជាប់រួចហើយនូវកិច្ចសន្យាថានឹងត្រូវធ្វើអ្វីខ្លះ ប៉ុន្តែក្នុងពេលប្រតិបត្តិឬអនុវត្តជាក់ស្តែងត្រូវធ្វើការប្តេជ្ញាចិត្តផ្ទាល់ខ្លួនទៀតរបស់ទីភ្នាក់ងារនីមួយៗ។ លោករដ្ឋមន្ត្រីបានបន្តថា «ទៅមុខថ្ងៃក្រសួងនឹងមិនបណ្តោយឱ្យភ្នាក់ងារជ្រើសរើសពលករធ្វើអ្វីខុសច្បាប់ ឬបំពានទៅលើកិច្ចព្រមព្រៀងឬកិច្ចសន្យាដែលបានចុះរួចហើយនោះទេ ព្រោះថាបើកាលណាជ្រើសរើសមិនបានត្រឹមត្រូវមិនមានតម្លាភាពទេវាអាចនឹងធ្វើឱ្យធ្លាក់ទៅនឹងការជួញដូរ»។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា កម្ពុជាបានរៀបចំកិច្ចព្រមព្រៀងពលករទេសន្តប្រវេសន្តជាលើកដំបូងនៅឆ្នាំ២០០២និង២០០៣ ជាមួយប្រទេសម៉ាឡេស៊ី។ បន្ទាប់មកទៀតប្រទេសថៃដោយផ្តើមពីទីភ្នាក់ងារ ២ ទៅ ៣ ប៉ុណ្ណោះ។ ប៉ុន្តែឥឡូវបានកើនឡើងជាង ១០០ ហើយក្នុងចំណោមទីភ្នាក់ងារជាង១០០ មានតែទីភ្នាក់ងារ ២ ទៅ ៣ ប៉ុណ្ណោះបានអនុវត្តមិនបានត្រឹមត្រូវហើយត្រូវក្រសួងចាត់វិធានការតាមផ្លូវច្បាប់។ ក្រៅពីនេះសុទ្ធតែធ្វើបានល្អហើយសូមលើកទឹកចិត្តឱ្យធ្វើបន្តទៀត។

បើតាមលោកហេង សួរ រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈធ្លាប់បានលើកឡើងថា បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង ១លាន៣សែននាក់ធ្វើការនៅក្រៅប្រទេសក្នុងនោះនៅថៃមានច្រើនជាងគេរហូតដល់ទៅ១,២២លាននាក់ នៅកូរ៉េខាងត្បូងមានជាង ៤៥ ០០០នាក់ នៅម៉ាឡេស៊ីមាន ២៣០២៧ នាក់នៅជប៉ុនមាន១១៤៥៣ នាក់ នៅសិង្ហបុរីមាន ៨២១នាក់ នៅចិនហុងកុងមាន ២០២នាក់ និងអារ៉ាប៊ីសាអូឌីត៤៣ នាក់ដោយក្នុង១ឆ្នាំៗបានផ្ញើថវិកាមកក្រុមគ្រួសារវិញប្រមាណជាង ៣ ពាន់លានដុល្លារ៕ អត្ថបទ៖ សំអឿន

# លោក ស ខេង អរគុណប្រទេសឡាវ ដែលផ្តល់កិច្ចសហប្រតិបត្តិការល្អក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ

https://www.postkhmer.com/national/2022-12-03-1713-244318.html អោម ប៊ុនធឿន | Publication date 03 December 2022 | 17:13 ICT

**ភ្នំពេញៈ** លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងអំណរគុណរដ្ឋាភិបាល និងក្រសួងសន្តិសុខសាធារណៈឡាវ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស បទល្មើសគ្រឿងញៀន។ លោក ស ខេង ថ្លែងបែបនេះពេលជួបសម្តែងការគួរសមជាមួយលោក អាត់សផានថង ស៊ីផានដូន អភិបាលរដ្ឋធានី វៀងចន្ទន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានរដ្ឋសភា នាព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២នេះ។ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា ប្រទេសកម្ពុជា និង ឡាវ ជាប្រទេសភូមិផងជាមួយគ្នា និងជាប្រទេសមានទំនៀមទម្លាប់ប្រពៃណីប្រហាក់ប្រហែលគ្នា។ ផ្អែកលើទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្នាកន្លងមក លោកសង្ឃឹមជឿជាក់ថា ភាគីទាំង ២ នឹងបន្តពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀត។

លោកថ្លែងថាៈ «ក្រសួងមហាផ្ទៃ តែងបានផ្តល់កិច្ចសហប្រតិបត្តិការជាមួយសមភាគីឡាវ យ៉ាងល្អប្រសើរក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរវាងខេត្តជាប់ព្រំដែន ក៏ដូចជា កិច្ចប្រជុំក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសន្តិសុខរវាងក្រសួង មហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ»។ លោកបន្តថា ភាគីទាំង ២ តែងបានបន្តផ្សារភ្ជាប់ទំនាក់ទំនងទោះបីជាក្នុងស្ថានភាពនៃវិបត្តិជំងឺកូវីដ១៩ ក៏ដោយ ក៏បានជួបប្រជុំជាមួយគ្នាតាមកាលកំណត់ តាមរយៈប្រព័ន្ធវីដអូដែរ។ លោកថ្លែងថាៈ «ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងមហាផ្ទៃ ខ្ញុំសូមថ្លែងអំណរគុណរដ្ឋាភិបាល និងក្រសួងសន្តិសុខសាធារណៈឡាវ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស បទល្មើសគ្រឿងញៀន»។ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃបញ្ជាក់ថា កម្ពុជាត្រៀមខ្លួនជានិច្ចក្នុងការបន្តពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការតាមយន្តការដែលមានស្រាប់ ធ្វើយ៉ាងណាថែរក្សាបរិយាកាសសន្តិសុខបានល្អប្រសើរ សម្រាប់ប្រទេសទាំង ២ រួមចំណែកដល់ការពង្រីកទំនាក់ទំនង និងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំង២ ពិសេសរវាងពលរដ្ឋរស់នៅតាមព្រំដែន។

លោក អាត់សផានថង ស៊ីផានដូន អភិបាលរដ្ឋធានីវៀងចន្ទន៍ ថ្លែងថា លោកពិតជាមានសេចក្តីរីករាយក្នុងឱកាសបានមកបំពេញទស្សនកិច្ចនៅកម្ពុជា ជាពិសេស អរគុណចំពោះការទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅរាក់ទាក់ពីសំណាក់លោកអភិបាលរាជធានីភ្នំពេញ។ លោកបានជម្រាប លោក ស ខេង ថា ក្រុងវៀងចន្ទន៍ និងរាជធានីភ្នំពេញ បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការជាមួយគ្នា តាំងពីឆ្នាំ ២០០៦មក ហើយចាប់តាំងពីពេលនោះមកភាគីទាំង ២ បានផ្លាស់ប្តូរទស្សនកិច្ចជាមួយគ្នាទៅវិញទៅមក ជាពិសេស ក្នុងរយៈពេលកន្លងមក ភាគីទាំង២ មានកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរប្រតិភូចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ទៅលើវិស័យអប់រំ និងការអភិវឌ្ឍ។ លោកបានលើកឡើងថា លោកបានឃើញការអភិវឌ្ឍរីកចម្រើនយ៉ាងច្រើនរបស់រាជធានីភ្នំពេញ ហើយលោកចាត់ទុកថា នេះជាបទពិសោធន៍មួយសម្រាប់រដ្ឋធានី វៀងចន្ទន៍ ធ្វើការផ្លាស់ប្តូរជាមួយកម្ពុជា ដើម្បីរួមចំណែកយកបទពិសោធន៍នេះ ទៅបន្តអភិវឌ្ឍន៍រដ្ឋធានីវៀងចន្ទន៍៕

# ជនរងគ្រោះពីការបោកប្រាស់ការងារតាមអ៊ីនធឺណិតនៅកម្ពុជា និយាយថា ពួកគេមិនត្រូវបានធ្វើទារុណកម្មទេ

https://www.khmertimeskh.com/1196036//?p=1196036 Khmer Times December 4, 2022

ជនរងគ្រោះជនជាតិម៉ាឡេស៊ី ៧ នាក់ ពីការបោកប្រាស់ការងារតាមអ៊ីនធឺណិត ដែលដំណើរការក្នុងប្រទេសកម្ពុជាដោយជនជាតិតៃវ៉ាន់ ថ្មីៗនេះបានរៀបរាប់ពីបទពិសោធន៍របស់ពួកគេ ហើយបាននិយាយយ៉ាងច្បាស់ថា ពួកគេមិនត្រូវបានធ្វើទារុណកម្មទេ។ ទោះបីជាទង្វើរបស់ពួកគេត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រង ២៤ ម៉ោងក្នុងមួយថ្ងៃក៏ដោយ ក៏ជនជាតិម៉ាឡេស៊ី ៧នាក់ រួមទាំងស្ត្រីម្នាក់ដែលមានអាយុចន្លោះពី១៨ ទៅ៣៤ ឆ្នាំ មកពីរដ្ឋ Johor ភាគខាងត្បូងបំផុត។ អ្នកស្វែងរកការងារធ្វើបានរងគ្រោះដោយសារក្រុមបោកប្រាស់ការងារនៅកម្ពុជា។ ម្នាក់ក្នុងចំណោមជនរងគ្រោះដែលត្រឹមចង់ឱ្យគេស្គាល់ឈ្មោះថា វ៉ាន់ អាយុ ៣៤ឆ្នាំ បាននិយាយថា នៅពេលដែលពួកគេមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានគេដាក់រយៈពេលប្រាំខែនៅក្នុងអ្វីដែលគេជឿថាជាមជ្ឈមណ្ឌលប្រតិបត្តិការរបស់ក្រុមបោកប្រាស់ ដែលជាសណ្ឋាគារមួយក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ លោកបានបន្តថា មុនពេលចាកចេញមកប្រទេសកម្ពុជា ពួកគេត្រូវបានភ្នាក់ងារក្នុងស្រុកផ្តល់ការងារនៅកាស៊ីណូមួយជាមួយនឹងប្រាក់ខែច្រើនរហូតដល់ ១ ១០០ ដុល្លារក្នុងមួយខែ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលមកដល់ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាអ្នកបោកប្រាស់សម្រាប់ប្រតិបត្តិការ cryptocurrency ដែលគ្រប់គ្រងដោយជនជាតិតៃវ៉ាន់។ "យើងត្រូវបានទាក់ទាញដោយប្រាក់ខែ ហើយត្រូវបានគេផ្តល់ការងារជាអ្នកគ្រប់គ្រងម៉ាស៊ីនមេនៅកាស៊ីណូ ប៉ុន្តែនៅពេលយើងទៅដល់ទីនោះ យើងត្រូវបានគេប្រាប់ឱ្យធ្វើការជាអ្នកបោកប្រាស់។ គាត់បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានមួយនៅមជ្ឈមណ្ឌលសេវាកម្មរបស់តំណាងសភានីតិបញ្ញត្តិរដ្ឋ Larkin កាលពីពេលថ្មីៗនេះថា "ប្រសិនបើយើងបដិសេធមិនចុះហត្ថលេខាលើកិច្ចសន្យា (ជាអ្នកបោកប្រាស់) សម្រាប់រយៈពេលប្រាំមួយខែយើងត្រូវបានគេបង្ខំឱ្យបង់ប្រាក់ ១៥,០០០ RM (ប្រហែល ៣៤០០ ដុល្លារក្នុងមនុស្សម្នាក់ដើម្បីត្រលប់មកផ្ទះវិញដូច្នេះយើងត្រូវបានគេបង្ខំឱ្យចុះហត្ថលេខាលើកិច្ចសន្យា" ។

លោក Wan មកពី Kampung Melayu Paloh លោក Kluang បាននិយាយថា រយៈពេលប្រាំខែនៅក្នុងប្រទេសកម្ពុជា ពួកគេមិនបានទទួលប្រាក់ខែរបស់ពួកគេទេ។ ទោះជាយ៉ាងណាពួកគេមិនត្រូវបានធ្វើបាបដោយក្រុមបោកប្រាស់ទេ។ ការមិនបានទទួលប្រាក់បៀវត្សរ៍របស់ពួកគេ ឬត្រូវបានបង់ត្រឹមតែប្រភាគនៃអ្វីដែលត្រូវកំណត់ហាក់ដូចជា SOP ស្តង់ដារនៃក្រុមទាំងនេះ។ លោកបានរំឭកថា៖ «ទោះជាយ៉ាងណា ជនរងគ្រោះមុនៗមួយចំនួនបាននិយាយថាត្រូវគេវាយហើយយកកាំភ្លើងភ្ជង់លើពួកគេ... ដូច្នេះសម្រាប់រយៈពេលនៅទីនោះ យើងមិនតវ៉ាទេ ប៉ុន្តែត្រូវធ្វើតាមការបញ្ជារ»។ យោងតាមលោក Wan គាត់និងមនុស្សប្រាំមួយនាក់ផ្សេងទៀតត្រូវបានដាក់ផែនការរយៈពេលមួយខែដើម្បីរត់គេចខ្លួន មុនពេលទាក់ទងអង្គការមនុស្សធម៌អន្តរជាតិម៉ាឡេស៊ី (MHO) ដើម្បីសុំការជួយសង្គ្រោះ ហើយបានរៀបចំរត់គេចពីក្តាប់ដៃរបស់ក្រុមនោះដោយផ្តល់លេសថាចង់ចេញទៅហាងកាត់សក់។

ជាមួយគ្នានេះដែរ ជនរងគ្រោះម្នាក់ទៀតដែលចង់ឱ្យគេស្គាល់ត្រឹមតែឈ្មោះ Hawa អាយុ៣០ឆ្នាំ បានទទួលយកការងារក្នុងប្រទេសកម្ពុជា ដោយសារនាងចង់សន្សំប្រាក់សម្រាប់ពិធីមង្គលការរបស់នាង។ Hawa ដែលមកពី Skudai បាននិយាយថា "គូដណ្តឹងរបស់ខ្ញុំ និងខ្ញុំបានទទួលយកការផ្តល់ជូននេះ ប៉ុន្តែមានការភ្ញាក់ផ្អើលនៅពេលដែលយើងទទួលបានដំណឹងថាយើងនឹងធ្វើការងារដែលមិនទាក់ទងនឹងការផ្តល់ជូនដើម។ ជនរងគ្រោះនៃការបោកប្រាស់មិនមែនមានតែជាជនជាតិម៉ាឡេស៊ីប៉ុណ្ណោះទេ គឺមានទាំងមកពីប្រទេសឥណ្ឌា ចិន និងឥណ្ឌូនេស៊ីផងដែរ"។ ។

Mohd Hairi Mad Shah នៃគណៈកម្មាធិការធនធានមនុស្ស សហករណ៍ យុវជន ការអភិវឌ្ឍន៍សហគ្រិន និងកីឡា និងយុវជន Johor បាននិយាយថា រដ្ឋាភិបាលរដ្ឋត្រូវទទួលបន្ទុកចំណាយលើការនាំយកជនរងគ្រោះទាំងប្រាំពីរនាក់មកផ្ទះ ហើយក្នុងនោះរួមមានកន្លែងស្នាក់នៅ សំបុត្រយន្តហោះ និងអាហារដែលមានតម្លៃប្រហែល ១៥០០០RM (៣៤០០ដុល្លារ) ហើយនឹងជួយជនរងគ្រោះស្វែងរកការងារថ្មីព្រោះមានការងារចំនួន១៩០០០ ក្នុងវិស័យផ្សេងៗក្នុងរដ្ឋ។ Daily Express

## តុលាការកំពូល ជម្រះបណ្ដឹងសាទុក្ខ បុរសជាប់ចោទអាមេរិកកាំងម្នាក់ ពាក់ព័ន្ធនឹងការរួមភេទជាមួយក្មេងប្រុសខ្មែរ និង ផលិតផលរូបថតអាសអាភាស !

https://cen.com.kh/archives/582702.html Posted ByPen Srey NeatDecember 4, 2022

ភ្នំពេញៈ បុរសជាប់ចោទ ជនជាតិអាមេរិកម្នាក់ កាលពីថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២២ ត្រូវបានតុលាការកំពូលធ្វើការ ជំនុំជម្រះលើបណ្ដឹងសាទុក្ខរបស់គាត់ ដែលត្រូវបានតុលាការជាន់ទាប កាត់ទោស គាត់ដាក់ពន្ធនាគារកំណត់ ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការបៀតបៀនកេរ្តិ៍ខ្មាស និង ការរួមភេទជាមួយកុមារខ្មែរ ជាច្រើននាក់តាមរន្ធ (បានសម្រេច) ប្រព្រឹត្តនៅក្នុងបន្ទប់ជួលរបស់ ជនល្មើស ស្ថិត នៅភូមិសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីពីអំឡុងឆ្នាំ ២០១៩។

លោក និល ណុន ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូល បានថ្លែងឲ្យដឹង នៅក្នុងអង្គសវនាការថា ជនជាប់ចោទ រូបនេះ មានឈ្មោះ ROBINSON SHAUN EARI ( រ៉ូប៊ីនសុន ស៊ីនអែល ) ភេទប្រុស អាយុ ៤១ ឆ្នាំ ជនជាតិអាមេរិកកាំង ។ ចំណែកឯ ក្មេងប្រុសរងគ្រោះមានឈ្មោះ ស.វ.ណ. ភេទ ប្រុស អាយុ ១៤ ឆ្នាំ មានទីលំនៅ នៅចំណុចកើតហេតុ ខាងលើ។ លោកចៅក្រមបានថ្លែងឱ្យដឹងថាៈ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទឈ្មោះ ROBINSON SHAUN EARI ត្រូវបានសាលាដំបូងខេត្តសៀមរាប កាលថ្ងៃ ទី ១៨ ខែ មិនា ឆ្នាំ ២០២០ កាត់ទោស ដាក់ពន្ធនាគារ កំណត់ ០៧ ឆ្នាំ និង បង្គាប់ឱ្យសងជំងឺចិត្តចំនួន ២០ លានរៀល ទៅកុមារកម្ពុជាម្នាក់ដែលជា ជនរងគ្រោះ។ ជនជាប់ចោទត្រូវបានជាប់ចោទពីបទៈ ការទិញពេស្យាចារកុមារ និង ការផលិត រូបភាព និងសម្ភារៈ អាសអាភាស នៃនៃកុមា តាមមាត្រា ២៣ និង មាត្រា ៣៤ នៃច្បាប់ស្តីពីការបង្រ្កាបអំពើ ជួញដូរ មនុស្ស និង អំពើ អាជីវកម្មផ្លូវភេទ។

ជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍ ខណៈសាលាឧទ្ធរណ៍បាត់ដំបង បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដដែល ។ គាត់ក៏បានបន្តប្ដឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត ។ ជនជាប់ចោទឈ្មោះ ROBINSON SHAUN EARI ត្រូវបានចាប់ឃាត់ខ្លួន កាលពថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០១៩ នៅភូមិសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ក្រោយឃាត់ខ្លួន , សមត្ថកិច្ចនគរបាលជំនាញ ដកហូតបានវត្ថុតាងមាន៖ ១. កុំព្យូទ័រឡែបថប ១ គ្រឿង ,២ .អង្គ ចងចាំ ១ គ្រឿង ,៣.ដៃ ហ្គេម ក្មេង លេង៣ គ្រឿង ,៤. ទឹក ថ្នាំ រអិល ២ ដប ( ទឹកសម្រាប់រួមភេទ ) ព្រមទាំង ថតអាក្រាត និង វិដេអូ សិច មួយចំនួន ពីគាត់។ នៅក្នុងសំណុំរឿងនេះ តុលាការកំពូលនឹងប្រកាសដីកា នៅព្រឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២២ នេះ ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

# ពលករខ្មែរមួយចំនួនដាច់ចិត្តដើរសុំទាននៅប្រទេសថៃ

https://www.rfa.org/khmer/news/economy/some-cambodian-workers-became-beggars-in-thailand-12032022044108.html ដោយ ម៉ៅ សុជានី2022.12.03

ពលករខ្មែរមួយចំនួនដែលកំពុងរស់នៅប្រទេសថៃ អ្នកខ្លះដើរកូតទ្រ អ្នកខ្លះនាំកូនតូចអង្គុយនៅទី សាធារណៈ សុំទានដើម្បីដោះស្រាយជីវភាព ព្រោះមេការសំណង់មិនបើកប្រាក់ខែឲ្យពួកគាត់ជាដើម។ មន្ត្រីសង្គមស៊ីវិល ថា ពលករខ្មែរនៅក្រៅស្រុក ត្រូវថៅកែ និងមេការកេងប្រវ័ញ្ចកម្លាំងពលកម្មញឹកញាប់ ហើយគ្មានដំណោះស្រាយ គឺបង្ហាញពីភាពខ្សោយ និងខ្វះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលខ្មែរ។ ពលករខ្មែរមួយចំនួន សម្រេចចិត្តដើរសុំទាន នៅតាមទីសាធារណៈក្នុងប្រទេសថៃ ដើម្បីរកប្រាក់មកចិញ្ចឹមជីវិត។ ពួកគាត់គ្មានប្រាក់ចាយវាយប្រចាំថ្ងៃ កាត់កេរ្តិ៍ កាត់ខ្មាស ដើរសុំទានតាមទីប្រជុំជន ទីផ្សារ ចិញ្ចើមថ្នល់ រកប្រាក់ជំនួយពីជនមានចិត្តសប្បុរស ដើម្បីយកមកដោះស្រាយសេដ្ឋកិច្ចគ្រួសារ ដោយសារមេការសំណង់មិនព្រមបើកប្រាក់ឈ្នួលឲ្យពួកគាត់ និងខ្វះប្រាក់ចំណូលជាដើម។

ពលករខ្មែរម្នាក់ មានស្រុកកំណើតនៅខេត្តកំពង់ចាម រស់នៅក្នុងប្រទេសថៃជាង៥ឆ្នាំ លោក វេត សាង ចាញ់បោកមេការសំណង់ ដែលជាជនជាតិខ្មែរដូចគ្នា លួងលោមប្រើឲ្យធ្វើការសំណង់អស់ជាច្រើនខែ តែមិនព្រមបើកប្រាក់ខែឲ្យលោក។ លោក វេត សាង ថា ប័ណ្ណការងាររបស់លោកអស់សុពលភាព ទើបលោកមិនហ៊ានប្ដឹងមេការដែលកេងកម្លាំងពលកម្មរបស់លោក។ លោកស្នើសុំស្ថាប័នពាក់ព័ន្ធ ជួយរកការងារឲ្យលោកធ្វើជាប្រចាំនៅស្ថាប័នរដ្ឋ ឬស្ថាប័នឯកជន ដែលពាក់ព័ន្ធវិស័យភ្លេងបុរាណ ដើម្បីបានប្រាក់ខែ ឬក៏ប្រាក់ប្រចាំថ្ងៃ សម្រាប់ចិញ្ចឹមជីវិត ព្រោះលោកកំពុងជួបការលំបាកនៅថៃ ហើយដើរកូតទ្រកំដរជីវិតតាមផ្លូវគេអាណិត គេដាក់ទានគ្រាន់តែសម្រាប់ដោះស្រាយបានមួយគ្រាៗប៉ុណ្ណោះ។ លោក វេត សាង៖ «បានមួយគ្រាៗហ្នឹង នែ!ដោះស្រាយ ថ្លៃបន្ទប់ ថ្លៃហូបចុកប្រចាំថ្ងៃតិចតួច ថ្លៃផ្លូវដែលយើងចងការគេជិះពីខ្មែរមកណា»។

ក្រៅពីពលករខ្មែរម្នាក់នេះ ក៏មានពលករខ្មែរមួយចំនួននាំកូនតូចៗ អង្គុយសុំទាននៅក្បែរផ្សារទំនើប នៅទីប្រជុំជន នៅទីក្រុងដែលមានមនុស្សដើរកកកុញ ភាគច្រើនពួកគាត់ត្រូវថៅកែនាំមកធ្វើការ ហើយមិនបើកប្រាក់ខែឲ្យ។ ពលការិនីម្នាក់ ដែលចិញ្ចឹមកូនបីនាក់ និងម្ដាយចាស់ម្នាក់ កំពុងសុំទាននៅប្រទេសថៃ ឲ្យដឹងថា លោកស្រីបាត់បង់មុខរបរតាំងពីជំងឺកូវីដ-១៩ផ្ទុះជាសាកល គឺលោកស្រីជាអ្នកលក់ស្បែកជើង នៅក្បែរផ្សារមួយនៅជាយក្រុងបាងកក។ លោកស្រីបន្ថែមថា បន្ទាប់ពីគ្មានការងារធ្វើ ហើយត្រឡប់ទៅស្រុកវិញមិនបាន ថែមទាំងជំពាក់បំណុលទៀត គ្មានផ្លូវជ្រើសរើសក៏នាំកូនអង្គុយសុំទាន នៅទីនេះតែម្ដងទៅ។ លោកស្រីមានបំណងចង់បានផ្ទះមួយស្នាក់នៅ ដោយមិនចាំបាច់ជួលគេប្រចាំខែ។ «ចង់បានតែផ្ទះនៅ ហើយសុំឲ្យអាកូនធំហ្នឹង ដែលវារៀន ចង់បានឲ្យតែវាបានការងារធ្វើទៅមិនបាច់មកស្រុកថៃ មានការងារធ្វើទៅវាជួយចិញ្ចឹមយើង»។

ស្រដៀងគ្នានេះដែរ នៅមិនឆ្ងាយពីលោកស្រី ពិសី ក៏មានពលការិនីខ្មែរម្នាក់ទៀត កំពុងអង្គុយសុំទាន លើស្ពានអាកាសក្បែរផ្សារទំនើប គឺលោកស្រី នី នីន ប្រាប់ថា លោកស្រីដើរលក់ប៉េងប៉ោង តែរកចំណូលមិនសូវបាន ក៏ឆ្លៀតនាំកូនតូចមកអង្គុយសុំទាន ដើម្បីបានប្រាក់ខ្លះទៀតទប់ទល់ការចំណាយ។ លោកស្រីបន្តថា លោកស្រីរកប្រាក់បន្ថែមគ្រាន់នឹងគ្រប់ថ្លៃទឹកដោះគោកូន និងថ្លៃបន្ទប់ស្នាក់នៅក្នុងមួយខែជាងមួយពាន់(១.២០០)បាត។ លោកស្រីឲ្យដឹងទៀតថា លោកស្រីមិនបានមកអង្គុយសុំគ្រោលថ្ងៃទេ ហើយមកអង្គុយតែពីរ បី ម៉ោង ក៏ត្រឡប់ទៅសប់ខ្យល់ប៉េងប៉ោងវិញ ដើម្បីយកទៅលក់។ លោកស្រី នី នីន៖ «តិចទៀតខ្ញុំទៅផ្ទះវិញហើយ ទៅលក់ប៉េងប៉ោងវិញ។ មានគេលក់ច្រើនដែរនៅក្នុងហ្នឹង ហើយខ្ញុំលក់ប៉េងប៉ោងលក់មិនសព្វមុខដូចគេទេ លក់តិចៗហ្នឹង ព្រោះអីបើយើងលក់បន្តិចហ្នឹង យើងលក់មិនឈ្នះគេទេ»។

កាលពីពេលថ្មីៗនេះ សមត្ថកិច្ចអន្តោប្រវេសន៍ថៃ បានចាប់បុរសគមខ្វងម្នាក់ ដែលបានដើរសុំទាននៅតាមផ្សារក្នុងខេត្តឈុនបុរី (Chun Buri) ។ បុរសគមខ្វងនេះគាត់ជាពលករខ្មែរចំណាកស្រុកទាំងគ្រួសារ ប៉ុន្តែពិបាករកការងារធ្វើ ក៏ដើរសុំទាន ហើយត្រូវប៉ូលិសថៃ ឃាត់ខ្លួនដើម្បីស៊ើបសួរនៅថ្ងៃទី៣ ខែកញ្ញា កន្លងទៅ។

ជុំវិញរឿងនេះដែរ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍អង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា លើកឡើងថា ពលករខ្មែរដែលធ្វើការងារ ហើយត្រូវថៅកែមិនបើកប្រាក់ខែឲ្យ ធ្វើឲ្យពួកគាត់អស់ជម្រើសរហូតដើរសុំទាន យកប្រាក់មកដោះស្រាយជីវភាព ស្ថានទូតខ្មែរនៅប្រទេសថៃត្រូវរកដំណោះស្រាយជូនពួកគាត់។ លោកបន្តថា កម្ពុជាត្រូវបង្កលក្ខណៈងាយស្រួល សម្រាប់ឲ្យពលករចំណាកស្រុកដោយសុវត្ថិភាព ជៀសវាងពួកគាត់ចេញបោកគេ ហើយដើរសុំទាន។ លោក ឌី ថេហូយ៉ា៖ «អ៊ីចឹងហើយបានជាទូទៅយើងទៅប្រទេសថៃ ម៉ាញសិត (mine set) ផ្នត់គំនិតរបស់ថៃហ្នឹង មើលមកយើង ហាក់ដូចជាជាតិសាស្ត្រមួយ ដែលអន់ថយជាងគេ ជាជាតិសាស្ត្រមួយដែលទៅសុំទានគេ ជាជាតិសាស្ត្រមួយដែលអត់មានការងារធ្វើ ចំណាកស្រុកទៅរកការងារស្រុកគេ ។ ជាពិសេសគឺយើងឃើញថា មានពលករខ្មែរមួយចំនួនដែរ ដែលទៅរក (ការងារ) ធ្វើម៉េចជៀសពីការងារជាអ្នកសុំទានកន្លែងផ្សេងៗអ៊ីចឹងណា»។

ពលករខ្មែរ ដែលត្រូវមេការសំណង់កេងប្រវ័ញ្ចពលកម្មពួកគាត់ និងគ្មានប្រាក់ចំណូលដាច់ចិត្តមកអង្គុយសុំទាន លើកឡើងថា ពួកគាត់មិនចង់មកអង្គុយសុំគេដូច្នេះទេ ប៉ុន្តែដោយសារតែស្ថានភាពសេដ្ឋកិច្ច បានបង្ខំឲ្យពួកគាត់មកធ្វើដូច្នេះ។ ពលករខ្មែរចូលមកប្រទេសថៃ ដើម្បីរកការងារធ្វើ តែពួកគាត់ខ្លះធ្វើចំណាកស្រុកទាំងប្រថុយប្រថាន រហូតចេញបោកគេជាច្រើនករណី ដូចជា ប្រើកម្លាំងពលកម្មច្រើនហួសកម្រិត ធ្វើការលើសម៉ោង មិនបើកប្រាក់ខែទៀងទាត់ និងយកទៅលក់លើទូកនេសាទជាដើម។ ពលករខ្មែរ ដែលសុំទានក្នុងប្រទេសថៃ មានប្រមាណម្ភៃ (២០) នាក់។ មន្ត្រីសង្គមស៊ីវិលយល់ថា នៅពេលពលករខ្មែរចំណាកស្រុកជួបការលំបាកហើយចង់មកផ្ទះវិញ រដ្ឋាភិបាលត្រូវជួយសម្រួលឲ្យពួកគាត់បានត្រឡប់មកកម្ពុជាវិញ ព្រោះកន្លងមកពួកគាត់ក៏បានបង់ពន្ធជូនរដ្ឋដែរ ពលករខ្មែរគួរទទួលបានជីវភាពមួយថ្លៃថ្នូរ។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះ ពីស្ថានទូតកម្ពុជាផ្នែកទទួលបន្ទុកពលករ និងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បានទេ កាលថ្ងៃទី២ ខែធ្នូ ដោយទូរស័ព្ទហៅចូលតែពុំមានអ្នកទទួល៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://www.gdlf-kh.com/2022/12/04/-56/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអាទិត្យ ១១កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ ឯកឧត្តមឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ចំនួន០៣នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ)

បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន៦នាក់ ស្រី២នាក់ ក្មេង២នាក់ ក្មេងស្រី១នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងធ្វើការពិនិត្យប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្តិ៍ជាលទ្ធផលត្រឹមត្រូវទាំងអស់ បន្ទាប់មកកម្លាំងយើងបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង១ទៀត ដែលស្នើឲ្យជួយសង្គ្រោះជនជាតិវៀតណាមម្នាក់

http://freshnewsasia.com/index.php/en/localnews/268473-2022-12-05-04-29-40.html 2022-12-05 11:29am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២២ម្សិលមិញនេះ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន ១ករណីទៀត ដែលស្នើឲ្យជួយសង្គ្រោះជនជាតិវៀតណាមម្នាក់។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២២ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៤០ករណី មានមនុស្ស ១៥៦២នាក់ មាន ១៥សញ្ជាតិ

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ៣៤៣សំណើ និងបិទសំណុំរឿង ១៣៧ករណី (រកឃើញ ៧៥៦នាក់, ឃាត់ខ្លួន ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។

**៣៖** កំពុងបន្តប្រតិបត្តិការស្រាវជ្រាវ ១៦០សំណើ។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមានដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០២២

## ពលករខ្មែរមួយចំនួន
## ងាកមករកស៊ីលក់បន្លែក្នុងផ្សារនៅប្រទេសថៃ សម្រាប់ដោះស្រាយជីវភាពគ្រួសារ

https://www.rfa.org/khmer/news/economy/some-cambodian-workers-in-thailand-make-good-money-to-support-their-families-by-selling-vegetables-12052022130621.html ដោយ ឡេង ម៉ាលី 2022.12.05

ពលករខ្មែរមួយចំនួន ដែលកំពុងធ្វើការក្នុងប្រទេសថៃ រកចំណូលបានគួរសមពីមុខរបរលក់ដូរបន្លែក្នុងផ្សារ ដោយទិញបន្លែពីកន្លែងមួយ ទៅលក់នៅកន្លែងមួយផ្សេងទៀត។ ពួកគាត់ថា ជីវភាពបានគ្រាន់បើជាងមុន បន្ទាប់ពីងាកមកចាប់មុខរបរជួញដូរបន្លែនេះ គឺរកប្រាក់សម្រាប់ផ្គត់ផ្គង់គ្រួសារបានគ្រប់គ្រាន់។ ពលករខ្មែរមួយចំនួន ងាកមកលក់ដូរបន្លែនៅផ្សារក្នុងប្រទេសថៃ បានប្រាក់ចំណូលសមរម្យ សម្រាប់ដោះស្រាយជីវភាពគ្រួសារ។ ពលករលក់បន្លែមានច្រើនប្រភេទ គឺអ្នកខ្លះទទួលទិញនៅនឹងកន្លែងរួចដាក់លក់តែម្ដង អ្នកខ្លះជួយទិញឬលក់ឲ្យថៅកែ និងអ្នកខ្លះទៀតទិញពីតំបន់មួយ នាំទៅលក់នៅតំបន់មួយផ្សេងទៀត។

ពលករខ្មែរម្នាក់ ដែលលក់បន្លែនៅផ្សារមួយកន្លែងក្បែរវាលយន្តហោះអន្តរជាតិ ដនមឿង (Don Mueang) លោក ខន សុឃឿន ប្រាប់វិទ្យុអាស៊ីសេរី កាលពីព្រលប់ថ្ងៃទី៤ ខែធ្នូ ថា ថ្ងៃខ្លះលោកអាចរកចំណូលពីការលក់បន្លែបាន ៣.០០០បាតក្នុងមួយថ្ងៃ ស្មើនឹងជិតកៅសិប (៨៦,៤០)ដុល្លារ។ លោកបន្តថា ពីមុនលោកជាពលករស៊ីឈ្នួលជួយលក់ និងទិញបន្លែឲ្យថៅកែថៃ ដោយធ្វើការយូរទៅលោកដឹងពីវិធីជួញដូរបន្លែ ក៏សម្រេចចិត្តចេញមកលក់ខ្លួនឯង តែថៅកែថៃជាអ្នកឈរឈ្មោះជាម្ចាស់តូបលក់បន្លែ។ លោក ខន សុឃឿន៖ «ត្រង់ថាបើសិនជាយើងលក់មួយភ្លែតអ៊ីចឹង បើថារបស់ប៊ិន មួយភ្លែតជួនកាលមួយម៉ឺន ត្រឹមរយៈពេលតែបីម៉ោងមួយម៉ឺន ប្រាំពាន់ក៏មាន ពីរពាន់ ទៅតាមរបស់ដែលថាយើងបានតិចៗអ៊ីចឹងច្រើន តែសំខាន់លក់របស់ណាអត់មាន របស់គេអត់មានហើយ យើងលក់គឺអត់ចេញតែម្ដង»។

ប្រហាក់ប្រហែលគ្នានេះដែរ ពលករខ្មែរម្នាក់ទៀត ដែលដឹកបន្លែដើរបោះឲ្យម៉ូយក្នុងផ្សារថៃ នៅក្បែរក្រុងរ៉ង់ស៊ិត ខេត្តប៉ាធុមថានី (Pathum Thani) លោក ប៉ែន ប៊ុនថន ឲ្យដឹងថា លោករកចំណូលពីការដឹកបន្លែដាក់តាមតូបក្នុងផ្សារបានជាមធ្យម ៤.០០០បាត ស្មើនឹង ១១៥,២០ដុល្លារ ក្នុងមួយថ្ងៃ។ លោកបន្តថា បើគិតប្រាក់ចំណាយប្រចាំថ្ងៃរួច លោកអាចសន្សំបានប្រហែលពាក់កណ្ដាលនៃប្រាក់ចំណូល។ លោកអះអាងថា នៅក្នុងផ្សារថៃនេះ មានអាជីវករខ្មែរជាងពីររយនាក់ ដែលជាអ្នកទិញដូរបន្លែ ផ្លែឈើ ពោត ដំឡូង ល្ពៅ សណ្ដែក ដោយខ្លួនឯង ប៉ុន្តែត្រូវមានថៅកែថៃជានាទ្យ ដើម្បីងាយស្រួលលក់ដូរ។ លោក ប៉ែន ប៊ុនថន៖ «អារឿងលក់ហ្នឹងបើយើងលក់នៅផ្សារហ្នឹង យើងចង់កើតថៅកែខ្លួនឯងក៏វាកើតបាន តែកុំឲ្យតែគេ(ប៉ូលិស)ដឹង។ ទាល់យើងមានខ្នងបង្អែកដូចថាមានថៃ គេជាអ្នកជានាពីក្រោយអ៊ីចឹងណា។ តែយើងបើកចំហថា យើងចេញមុខមាត់ខ្លាំងពេកអាហ្នឹងគេ គេអាចចែងយើងបាន យើងធ្វើ យើងចេះតែអ៊ីចឹងធ្វើលាក់លៀមដែរហ្នឹងណា»។

នៅក្នុងផ្សារថៃមួយ ដែលស្ថិតនៅជាយទីក្រុងបាងកកនេះ មានអាជីវករ និងពលករចម្រុះជាតិសាសន៍ ដូចជា ឡាវ (Lao) ភូមា (Myanmar) ចិន (China) និងកម្ពុជា។ ពួកគេទិញលក់ទំនិញមានទាំងបន្លែក្នុងស្រុក និងបន្លែនាំមកពីក្រៅស្រុក មានជាអាទិ៍ បន្លែនាំចូលមកពីប្រទេសចិន (China) កូរ៉េ (Korea) វៀតណាម (Vietnam) និងផ្លែឈើខ្លះនាំមកពីប្រទេសខ្មែរ មានដូចជា ស្វាយ ទុរេន និងមៀន ជាដើម ដែលមានដាក់លក់ហូរហែនៅក្នុងផ្សារមួយនេះ។

ជុំវិញរឿងនេះ ប្រធានអង្គការសង់ត្រាល់ (Central) លោក មឿន តុលា លើកឡើងថា ច្បាប់ប្រទេសថៃមិនអាចឲ្យពលករបរទេសមកធ្វើអាជីវករ ឬអ្នកលក់ដូរដោយខ្លួនឯងទេ តែបើមានថៅកែថៃជានាយឈ្មោះជាម្ចាស់ពលករបរទេសអាចលក់ដូរបាន។ លោកបន្តថា ថៃទុកអាទិភាពជាម្ចាស់មុខរបរផ្សេងៗ ឲ្យពលរដ្ឋថៃ ចំណែកពលរដ្ឋខ្មែរ ឬបរទេសបានត្រឹមសិទ្ធិជាពលករ តែបើជនបរទេសដែលមានមុខជំនួញធំ អាចធ្វើជាថៅកែបាន។ លោក មឿន តុលា៖ «គេអត់បើកឲ្យជនបរទេសហ្នឹងមានសិទ្ធិធ្វើស្វ័យនិយោជន៍ដូចខ្មែរយើងទេ។ ខ្មែរយើង យើងឲ្យជនបរទេសអាចធ្វើស្វ័យនិយោជន៍បាន ដូចជាជនជាតិចិនអីលក់ចេកអាំងបាន លក់ចេកចៀនបានណា ប៉ុន្តែថៃអត់ទេថៃ គេអត់អាច គេអត់បើក គេអត់អនុញ្ញាតអ៊ីចឹងទេ។ ប៉ុន្តែលើកលែងតែជនបរទេសដែលមានទុនធំៗ ម៉ង អាហ្នឹងគេវិនិយោគមកអាហ្នឹងបាន អាហ្នឹងទើបអាច»។

របាយការណ៍ក្រសួងការងារកម្ពុជា ឲ្យដឹងថា ពលករខ្មែរដែលកំពុងធ្វើការក្នុងប្រទេសថៃ ហើយបានចុះឈ្មោះក្នុងបញ្ជីការងារមានប្រមាណ ១លាន ២សែន (១.២០០.០០០) នាក់។ ប៉ុន្តែរបាយការណ៍អង្គការសង់ត្រាល់ (Central) ឲ្យដឹងថា មានពលករខ្មែរ ដែលកំពុងធ្វើការ និងរស់នៅ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ក្នុងប្រទេសថៃជាង ២លាន (២.០០០.០០០) នាក់៕

## សមត្ថកិច្ចកម្ពុជាទទួលបានបណ្តឹង៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិខ្មែរ៤នាក់ និងចិន៣នាក់

http://freshnewsasia.com/index.php/en/localnews/268582-2022-12-06-00-46-34.html 2022-12-06 07:46am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ម្សិលមិញនេះ សមត្ថកិច្ចកម្ពុជា បានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិខ្មែរចំនួន៤នាក់ និងជនជាតិចិន៣នាក់។ នេះបើតាមនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៤២ករណី មានមនុស្ស ១៥៦៧នាក់ មាន ១៥សញ្ជាតិ

**២៖** ស្រាវជ្រាវអង្កេតបឋមបាន ៣៤៣សំណើ និងបិទសំណុំរឿង ១៣៧ករណី (រកឃើញ ៧៥៦នាក់, ឃាត់ខ្លួន ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។

**៣៖** កំពុងបន្តប្រតិបត្តិការស្រាវជ្រាវ ១៦២សំណើ។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០២២

## ថៅកែហាងម៉ាស្សាម្នាក់និងនារីរងគ្រោះចំនួន៨នាក់ជាប់ពាក់ព័ន្ធករណីបង្កប់សេវាផ្លូវភេទ ត្រូវនគរបាលឃាត់ខ្លួន

http://nokorwatnews.com/archives/938704

ភ្នំពេញ ៖ បុរសម្នាក់ជាថៅកែហាងនិងជាអ្នកមើលការខុសត្រូវនៅទីតាំងម៉ាស្សាកោសជប់ បង្កប់ការរួមភេទចំនួន២ទីតាំងផ្សេងគ្នា ត្រូវបាននគរបាលនៃស្នងការដ្ឋានរាជធានីភ្នំពេញធ្វើការឃាត់ខ្លួន។ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះបង្ក្រាបជាក់ស្តែងករណីប្រព្រឹត្តអំពើសញ្ចារកម្ម មានស្ថានទម្ងន់ទោស បើកហាងម៉ាស្សាបង្កប់បម្រើសេវាផ្លូវភេទ ដោយបានឃាត់ខ្លួនបុរសជាថៅកែហាងម្នាក់ និងនារីរងគ្រោះចំនួន០៨នាក់ ក្នុងនោះមានអនីតិជនចំនួន០២នាក់ និងវត្ថុតាងស្រោមអនាម័យប្រើប្រាស់រួចមួយចំនួននិងមិនទាន់ប្រើប្រាស់មួយចំនួន។ ថៅកែហាងមានឈ្មោះ ប៉ក ឧត្តម ភេទប្រុស អាយុ៣៥ឆ្នាំ ស្នាក់នៅផ្ទះលេខ៣៣ ផ្លូវបេតុង ក្នុងបុរីពិភពថ្មី សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

លោកឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្រោមការសម្របសម្រួលដោយលោក ទី មុនិន្ទ ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំបញ្ជាផ្ទាល់ដោយលោកវរសេនីយ៍ទោ ហាក់ លី នាយការិយាល័យ បានធ្វើការឃាត់ខ្លួនបុរសថៅកែហាងម្នាក់ និងនារីរងគ្រោះ ក្មេងៗចំនួន០៨នាក់ នៅវេលាម៉ោង០៨និង៣០នាទីយប់ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ នៅហាងម៉ាស្សាចំនួន២ទីតាំង គឺទី១នៅចំណុចហាងយីហោ«កុលាបក្រហម១៦៨» ស្ថិតនៅផ្ទះលេខ៣៣ ផ្លូវបេតុង និងទី២ ទីតាំងហាងគ្មានយីហោ ផ្ទះលេខ២៨១ ផ្លូវបេតុងទី១ ស្ថិតក្នុងភូមិស្ទួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា បុរសជាអ្នកគ្រប់គ្រងហាងទាំង២ទីតាំង ក្នុងនោះមានហាងម៉ាស្សាយីហោ«កុលាបក្រហម ១៦៨» មាននារីម៉ាស្សានិង រួមភេទចំនួន២នាក់ និងទីតាំងមួយទៀតផ្ទះលេខ២៨១ គ្មានយីហោ មានស្រីៗរង់ចាំទទួលភ្ញៀវម៉ាស្សានិងរួមភេទចំនួន ០៦នាក់ ក្នុងនោះមានអនីតិជន០២នាក់និងមានបន្ទប់សម្រាប់រួមភេទចំនួន ០៣បន្ទប់ តម្លៃម៉ាស្សាធម្មតា ២០.០០០រៀលក្នុងមួយម៉ោង និងតម្លៃនៃការរួមភេទក្នុងមួយដងចាប់ពី ២០$ ទៅ ២៥$ ហើយលុយដែលបានមកពីការ រួមភេទ គឺថៅកែហាងចែកស្មើគ្នាជាមួយស្រីៗម៉ាស្សាទាំងនោះ ។ ប្រភពដដែលបានឱ្យដឹងទៀតថា ហាងម៉ាស្សានេះបើក ដំណើរការរកស៊ីទទួលភ្ញៀវចាប់ពីម៉ោង ០៩ព្រឹក រហូតដល់រំលងអធ្រាត្រទើបបិទទ្វារ រីឯនារីដែលជាអនីតិជនចំនួន ០២នាក់ គឺចូលមកបម្រើការងារចាប់ពីម៉ោង០៨យប់ រហូតដល់ម៉ោង១០យប់ ។

ក្រោយប្រតិបត្តិការ កម្លាំងជំនាញបាននាំខ្លួនបុរសថៅកែហាងម៉ាស្សា ទៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីសួរនាំនិងកសាងសំណុំរឿងចាត់ការតាមនីតិវិធី។ ចំណែកនារីរងគ្រោះទាំង០៨នាក់ត្រូវបានប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញធ្វើការអប់រំ៕

## វៀតណាម ស្នើសុំអនុសាសន៍ពីកម្ពុជា
## លើកិច្ចសហការប្រយុទ្ធប្រឆាំង បទល្មើសឆ្លងដែន គ្រប់ប្រភេទ

https://dap-news.com/national/2022/12/08/298163/ ByPH104Posted on December 8, 2022

**ភ្នំពេញ៖ លោក LE VAN PHUONG ប្រធានស្ថានតំណាងក្រសួង នគរបាល អមស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំកម្ពុជា បានស្នើសុំអនុសាសន៍ចង្អុល ដឹកនាំបំពេញបន្ថែមពី នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ លើកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំង បទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសបង្កើនការធានាសន្តិសុខ និងសណ្តាប់ធ្នាប់ជារួម នៃប្រទេសទាំងពីរ កម្ពុជា-វៀតណាម ។**

ការស្នើសុំនេះធ្វើឡើង នាថ្ងៃទី៨ ធ្នូនេះ ក្នុងឱកាសលោក LE VAN PHUONG និងសហការីចូលជួបសម្តែងការ គួរសមជាមួយ នាយឧត្តមសេនីយ៍ នេត សាវឿន និងឧទ្ទេសនាមលោក NGUYEN VAN CUONG អនុប្រធានទទួលកិច្ចការតម្រួត ព្រមទាំងរាយការណ៍ អំពីលទ្ធផល កិច្ចសហប្រតិបត្តិការ រវាងនគរបាលជាតិកម្ពុជា និងនគរបាលវៀតណាម ដែលសម្រេចបានក្នុងឆ្នាំ២០២២ និងទិសដៅអនុវត្តន៍ បន្តនាពេលខាងមុខ នៅអគ្គស្នងការដ្ឋាន នគរបាលជាតិ ។ ក្នុងជំនួបនេះ ភាគីតំណាងក្រសួង នគរបាលវៀតណាម ក៏បានស្នើសុំអនុសាសន៍ចង្អុលដឹកនាំបំពេញបន្ថែមពី នាយឧត្តមសេនីយ៍ នេត សាវឿន លើកិច្ចសហប្រតិបត្តិការ ប្រយុទ្ធប្រឆាំង បទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសបង្កើនការធានាសន្តិសុខ និងសណ្តាប់ធ្នាប់ជារួម នៃប្រទេសទាំងពីរ កម្ពុជា-វៀតណាម។

ជាការឆ្លើយតប នាយឧត្តមសេនីយ៍អគ្គស្នងការ នគរបាលជាតិ បានថ្លែងនូវការកោតសរសើរ និងគាំទ្រដល់លទ្ធផល នៃកិច្ចសហប្រតិបត្តិការ ដែលភាគីទាំងពីរសម្រេចបានក្នុងឆ្នាំ២០២២នេះ ។ ជាអនុសាសន៍ដឹកនាំបន្ថែមលើលទ្ធផលដ៏ល្អដែលមានស្រាប់ នាយឧត្តមសេនីយ៍ នេត សាវឿន ក៏បានចង្អុលដឹកនាំឱ្យនាយកដ្ឋាន-អង្គភាពជំនាញ នៃភាគីទាំងពីរបន្តលើក កម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការផ្លាស់ប្តូរព័ត៌មាន ទាន់ហេតុការណ៍ និងបទពិសោធន៍ ព្រមទាំងពង្រឹងការសម្របសម្រួលរួមសហការ ដោះស្រាយប្រយុទ្ធប្រឆាំងបទល្មើស ឱ្យបានទាន់ពេលវេលា ចំគោលដៅ និងមានប្រសិទ្ធភាព និយាយជារួមសហការដោះស្រាយ កុំឱ្យបទល្មើស មានការរីករាលដាល ។ ក្នុងជំនួបនេះដែរ ភាគីទាំងពីរកម្ពុជា-វៀតណាម ក៏បានប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ឱ្យបានល្អប្រសើរបន្ថែមទៀត រវាងស្ថាប័នអនុវត្តច្បាប់នៃ ប្រទេសទាំងពីរ ក្នុងការបង្ការទប់ស្កាត់បទ ល្មើសឆ្លងដែនគ្រប់ប្រភេទ ៕

# ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០២២

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ទៀត ដែលស្នើឱ្យជួយសង្រ្គោះជនជាតិវៀតណាម ៣នាក់

http://freshnewsasia.com/index.php/en/localnews/268988-2022-12-09-03-32-46.html 2022-12-09 10:32am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៦ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៤២ករណី មានមនុស្ស ១,៥៥៧នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៤៦សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៦២នាក់, ឃាត់ខ្លួនជនសង្ស័យ ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៥៩ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយធន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមានដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## ពលករ មីយ៉ាន់ម៉ា ជិត ៣០០នាក់ប្រមូលផ្តុំគ្នាទាមទារដំណោះស្រាយចំពោះមេខ្យល់ ថៃ

https://www.kampucheathmey.com/global-news/428325 ថ្ងៃសុក្រ ៩ ធ្នូ ២០២២ដោយ Sonya

ប្រភពព័ត៌មានបានរាយការណ៍ថា នៅព្រឹកថ្ងៃទី៩ ខែធ្នូនេះ មានពលករមីយ៉ាន់ម៉ាប្រមាណ ៣០០នាក់បានប្រមូលផ្តុំគ្នានៅមុខការិយាល័យគាំពារ និងសុខុមាលភាពការងារខេត្តសាមុតសាខន ដើម្បីតវ៉ាទាមទារឱ្យមន្ត្រីរដ្ឋាភិបាលថៃដែលពាក់ព័ន្ធជួយពន្លឿនការដោះស្រាយបញ្ហាមេខ្យល់ថៃដែលបានប្រមូលលុយពីពលករមីយ៉ាន់ម៉ាក្នុងម្នាក់ៗជាង១ម៉ឺនបាត ជាថ្នូរនឹងការបានចូលធ្វើការងារនៅក្នុងរោងចក្រផលិតត្រីខកំប៉ុងនាំចេញមួយកន្លែង ស្ថិតនៅក្នុងស្រុក/ខេត្តសាមុតសាខន ដែលអស់រយៈពេលជាង៤ខែបានកន្លងមកហើយ ប៉ុន្តែពលករភាគច្រើននៅតែមិនទាន់មាននរណាហៅឱ្យចូលធ្វើការឡើយ។

យោងតាមការសាកសួរស្ត្រីម្នាក់ដែលជាអ្នកសម្របសម្រួលក្រុមពលករមីយ៉ាន់ម៉ាដែលដឹងរឿងរ៉ាវនេះបានឱ្យដឹងថា មានមេខ្យល់ថៃម្នាក់ដែលគេស្គាល់ថា ឈ្មោះ ធី បានទាក់ទងនិងទារប្រាក់ពីពលករមីយ៉ាន់ម៉ាចំនួន ៤០០នាក់ ក្នុងម្នាក់ៗជាង ១ម៉ឺនបាត ជាថ្នូរនឹងការបានចូលធ្វើការងារក្នុងរោងចក្រផលិតត្រីខកំប៉ុងនាំចេញមួយកន្លែងដោយបានធ្វើឯកសារនិងប្រមូលប្រាក់ពីពលករមីយ៉ាន់ម៉ាចាប់តាំងពីអំឡុងខែកក្កដា ឆ្នាំ២០២២ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែមិនទាន់អាចនាំពលករទាំងអស់ចូលធ្វើការបាននៅឡើយ ដែលក្រុមពលករទាំងនោះធ្លាប់បានប្តឹងរដ្ឋាភិបាលឱ្យជួយអន្តរាគមន៍ប៉ុន្មានដងមកហើយ ប៉ុន្តែនៅតែមិនមានការវិវត្តទៅមុខដដែល៕ **គង់ សំអាន**

## សមត្ថកិច្ចចម្រុះស្រាវជ្រាវឃាត់ខ្លួនគ្រូបង្រៀនម្នាក់ ពាក់ព័ន្ធករណី ចែកចាយវីដេអូអាសអាភាសកុមារ តាមរយៈសារអេឡិចត្រូនិក

https://cen.com.kh/archives/587274.html Posted ByPen Srey NeatDecember 10, 2022

កោះកុង ៖ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង១៣និង៣៥នាទី កម្លាំងការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល និងកម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ព្រមទាំងកម្លាំងអធិការដ្ឋាននគរបាលស្រុកបូទុមសាគរ ចូលរួមសហការជាមួយកម្លាំងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាក្រសួងមហាផ្ទៃ បានអនុវត្តតាមដីកាបញ្ជាឲ្យចូលខ្លួនលេខ៥១៦អ-យ-ក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឯកឧត្តម

ច្រឹង ខ្មៅ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នាំខ្លួនឈ្មោះ ហ៊ួត ហ៊ុយ ភេទប្រុស អាយុ ៣២ ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្រូបង្រៀន មានទីលំនៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង ពីបទ ៖ ចែកចាយវីដេអូអាសអាភាសកុមារតាមរយៈសារអេឡិចត្រូនិក (Video File) បានបង្ហាញពីបុរសពេញវ័យជាច្រើន បានធ្វើការរួមភេទដោយប្រើមាត់ជាមួយអនីតិជន ។ បច្ចុប្បន្ន មុខសញ្ញាសង្ស័យត្រូវបានប្រគល់ជូន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាក្រសួងមហាផ្ទៃ ចាត់ការតាមនីតិវិធី ៕រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ឃុំខ្លួនថៅកែហាងម៉ាស្សាម្នាក់ ពាក់ព័ន្ធបទល្មើស សញ្ញាកម្មមានស្ថានទម្ងន់ទោស បើកកន្លែងម៉ាស្សាបង្កប់សេវាកម្មផ្លូវភេទ

https://cen.com.kh/archives/587288.html Posted ByPen Srey NeatDecember 10, 2022

ភ្នំពេញ៖ ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២២នេះ បានបង្គាប់ឲ្យឃុំខ្លួន ជនត្រូវចោទត្រូវជាថៅកែហាងម៉ាស្សាម្នាក់ និង បញ្ជូនទៅឃុំខ្លួន នៅក្នុងពន្ធនាគារ ជាបណ្ដោះអាសន្ន ដើម្បីរង់ចាំ ចាត់ការតាមផ្លូវច្បាប់ ជាប់ពាក់ព័ន្ធអំពើ សញ្ញាកម្មមានស្ថានទម្ងន់ទោស ដោយបើកកន្លែងម៉ាស្សា បង្កប់សេវាកម្មផ្លូវភេទ ប្រព្រឹត្ត នៅត្រង់ចំណុចពីរទីតាំងផ្សេងគ្នា ។

ទីតាំងទី១. នៅចំណុចហាងយីហោ«កុលាបក្រហម១៦៨» ស្ថិតនៅផ្ទះលេខ៣៣ ផ្លូវបេតុង ។

ទីតាំងទី២. ទីតាំងហាងគ្មានយីហោ ផ្ទះលេខ២៨១ ផ្លូវបេតុងទី១ ស្ថិតនៅភូមិស្ទួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

យោងតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានឱ្យដឹងថា មានឈ្មោះ ប៉ក ឧត្តម ភេទប្រុស អាយុ៣៥ឆ្នាំ ស្នាក់នៅផ្ទះលេខ៣៣ ផ្លូវបេតុង ក្នុងបុរីពិភពថ្មី សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។ តាមប្រភពបានឲ្យដឹងថា ទីតាំងហាងម៉ាស្សាយីហោ«កុលាបក្រហម» មាននារីម៉ាស្សា និង រួមភេទ ចំនួនពីរនាក់ និងទីតាំងមួយទៀត មានស្រីៗរង់ចាំទទួលភ្ញៀវម៉ាស្សា និងរួមភេទ ចំនួនប្រាំមួយនាក់ ដែលពីរនាក់ជាអនីតិជន និងមានបន្ទប់សម្រាប់រួមភេទចំនួនបីបន្ទប់។ ជនត្រូវចោទ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ ″ សញ្ញាកម្មមានស្ថានទម្ងន់ទោស ″ តាមមាត្រា ២៧ នៃច្បាប់ស្ដីពីការជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ ។ ជនត្រូវចោទត្រូវជា ថៅកែហាងម៉ាស្សា ត្រូវបានសមត្ថកិច្ចចាប់ខ្លួន កាលពីថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០២២ស្ថិតនៅភូមិស្ទួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។ ចំណែកនារីរងគ្រោះទាំង ៨ នាក់ ត្រូវបានប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញធ្វើការអប់រំ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## រដ្ឋបាលខេត្តសៀមរាប
## ជួបពិភាក្សាជាមួយតំណាងក្រុមហ៊ុនកូរ៉េ លើការងារបញ្ជូនពលករទៅបរទេស

https://www.postkhmer.com/national/2022-12-10-1530-244562.html អោម ប៊ុនធឿន | Publication date 10 December 2022 | 15:30 ICT

**សៀមរាប៖** រដ្ឋបាលខេត្តសៀមរាប ដឹកនាំដោយ អភិបាលរងខេត្ត លោក ពិន ប្រាកដ នៅថ្ងៃទី៩ ខែធ្នូ បានជួបពិភាក្សាការងារជាមួយ លោក Kim Mu Young នាយកប្រតិបត្តិក្រុមហ៊ុន EUM Place នៃសាធារណរដ្ឋកូរ៉េ ស្ដីពីការលើកកម្ពស់អាជីវកម្ម ការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការប្រកបដោយមិត្តភាព។ រដ្ឋបាលខេត្តសៀមរាបបានឱ្យដឹងថា គោលបំណងនៃជំនួបពិភាក្សានេះ គឺដើម្បីពិភាក្សាលើការងារបញ្ជូនពលករទៅបរទេសការកសាងបទដ្ឋានលក្ខណៈវិនិច្ឆ័យ និងនីតិវិធីឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការជ្រើសរើស និងអប់រំបណ្ដុះបណ្ដាល ដើម្បីបំពេញ

សំណូមពរ និងលក្ខខណ្ឌការងារប្រកបដោយតម្លាភាពសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេស។

រដ្ឋបាលខេត្តនេះបញ្ជាក់ថា៖ «ជំនួបនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ រៀបចំ និងចាត់ចែងបែបបទបញ្ជូន និងគ្រប់គ្រងពលករដែលទៅធ្វើការនៅសាធារណរដ្ឋកូរ៉េរហូតត្រឡប់មកកម្ពុជាវិញ»។ ជំនួបនេះក៏ជាការទំនាក់ទំនងជាមួយភាគីកូរ៉េ ដើម្បីក្តាប់ព័ត៌មាន និងតម្រូវការទីផ្សារការងារ ហើយដោះស្រាយឱ្យបានទាន់ពេលវេលាផងដែរ។ រដ្ឋបាលខេត្តសៀមរាបបញ្ជាក់ថា កម្ពុជាមានក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស បង្កើតឡើងស្របតាមអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស និងត្រូវបានកែសម្រួលតាមរយៈអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីកំណែតម្រូវឈ្មោះក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ទៅជាគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ៦នាក់

http://freshnewsasia.com/index.php/en/localnews/269261-2022-12-11-05-54-58.html 2022-12-11 12:54pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៩ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ០៦នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៤៩ករណី មានមនុស្ស ១,៥៨០នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៥០សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៧០នាក់, ឃាត់ខ្លួនជនសង្ស័យ ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៦២ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

# មហាជនជាង ៣ពាន់នាក់
# នឹងជួបជុំគ្នាប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃស្អែកនេះ

https://www.btv.com.kh/article/18079 2022/12/11 07:49:02 am

មហាជនប្រមាណជាង ៣០០០ អង្គ/នាក់ មកពីគ្រប់អង្គភាព ស្ថាប័នទាំងអស់ នឹងមានការជួប ជុំគ្នានៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ស្អែកនេះ ដើម្បីប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឆ្នាំ២០២២ ខណៈកម្មវិធីនេះនឹងក្លាយទៅជាយុទ្ធនាការអប់រំដ៏ធំមួយ សម្រាប់ជាការពញ្ញាក់ស្មារតី ឲ្យប្រជាពលរដ្ឋទាំងអស់យល់ដឹងអំពី អំពើជួញដូរមនុស្ស និង ចូលរួមបង្ការទប់ស្កាត់ និងការពារខ្លួនពីអំពើជួញដូរមនុស្ស។

យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលទូរទស្សន៍ BTVទទួលបាននាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២នេះ បានឲ្យដឹងថា ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ នេះ ត្រូវបានប្រារព្ធធ្វើនៅថ្នាក់ជាតិ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ នៅសាលមហោស្រព និងពិព័រណ៌កោះពេជ្រ ដោយមានការជួបជុំពីថ្នាក់ដឹកនាំ ជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរថ្នាក់ ក្រោមជាតិ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងប្រចាំនៅកម្ពុជា ប្រធាន ឬតំណាងអង្គការ សហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល តំណាងគ្រប់និកាយសាសនា សាស្ត្រាចារ្យ សិស្ស និស្សិត បញ្ញវន្ត និងវិស័យឯកជន ប្រមាណជាង ៣០០០ អង្គ/នាក់ ។

សេចក្តីជូនដំណឹងបានបន្តថា ការប្រារព្ធកម្មវិធីនេះគឺក្នុងគោលបំណង បង្ហាញនូវស្មារតីសាមគ្គីភាព និងការយកចិត្តទុកដាក់ ចំពោះការងារប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប និងការការពារសិទ្ធិមនុស្សនៅកម្ពុជា។ ជាការបំផុសការយល់ដឹងយ៉ាងទូលំទូលាយអំពីព្រឹត្តិការណ៍ ស្ថានភាព និងនិន្នាការនៃអំពើជួញដូរមនុស្ស។ ធ្វើការផ្សព្វផ្សាយអំពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូពាក់ព័ន្ធជាតិ អន្តរជាតិនានា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសុវត្ថិភាព និងការអភិវឌ្ឍន៍ជាតិ ។

សេចក្តីជូនដំណឹងដដែលបានបញ្ជាក់បន្ថែមថា ដើម្បីក្លាយជាយុទ្ធនាការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស សូមលើកទឹកចិត្ត ដល់គ្រប់គណៈកម្មាធិការ រាជធានី-ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) បន្តកិច្ចសហការជាមួយវិស័យពាក់ព័ន្ធ និងដៃគូជាតិ អន្តរជាតិ ឃុំ សង្កាត់ និង សាលារៀន ចាត់តាំងការរៀបចំ ផ្សព្វផ្សាយ តាមរូបភាពផ្សេងៗ នូវសារទាំងឡាយ នៃទិវា ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ៖ **«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព»** សម្រាប់ជាការពញ្ញាក់ស្មារតី ឲ្យប្រជាពលរដ្ឋទាំងអស់យល់ដឹងអំពី អំពើជួញដូរមនុស្ស និង ចូលរួមបង្ការទប់ស្កាត់ និងការពារខ្លួនពីអំពើជួញដូរមនុស្ស ។

នេះជាការរួមចំណែកដ៏ធំធេងក្នុងការលើកកម្ពស់ សន្តិសុខ សុវត្ថិភាពសង្គម និងសន្តិភាពជាតិ ឲ្យមានស្ថេរភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព តាមការគ្រោងទុក៕ អត្ថបទ៖ បាន ចក់

# ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០២២

## សម្តេច ស ខេង អញ្ជើញប្រារព្ធ ទិវាជាតិប្រឆាំង ការជួញដូរមនុស្ស ១២ ធ្នូ

https://dap-news.com/national/2022/12/12/298819/ ByPH104Posted on December 12, 2022

**ភ្នំពេញ ៖ នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ សម្តេច ស ខេង នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញជាអធិបតី ក្នុងកម្មវិធីទិវាជាតិ ប្រឆាំងការជួះដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់ អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅ អភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព» នៅសាលមហោស្រពកោះពេជ្រ ។**

ទិវាជាតិនេះ ក៏មានការចូលរួមពីថ្នាក់ដឹកនាំ នៃរាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា រដ្ឋសភា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរថ្នាក់ក្រោមជាតិ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ស្ថានតំណាងប្រចាំនៅកម្ពុជា តំណាងអង្គការសហប្រជាជាតិ អង្គការដៃគូជាតិអន្តរជាតិ អង្គការសង្គមស៊ីវិល តំណាងគ្រប់និកាយសាសនា សាស្ត្រាចារ្យ សិស្ស និស្សិត បញ្ញវ័ន្ត និងវិស័យឯកជន ប្រមាណជាង ៣០០០ អង្គ/នាក់។

គួរបញ្ជាក់ថា ទិវាជាតិប្រឆាំង ការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០២២ លើកទី១៩ នាពេលនេះ ធ្វើឡើងក្នុងគោល បំណងបង្ហាញស្មារតីសាមគ្គីភាព និងការយកចិត្តទុកដាក់ ចំពោះការងារប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប និងការការពារសិទ្ធិមនុស្ស នៅកម្ពុជា ជាការបំផុសការយល់ដឹង យ៉ាងទូលំទូលាយ អំពីព្រឹត្តិការណ៍ ស្ថានភាព និងនិន្នាការនៃអំពើជួញដូរមនុស្ស, ផ្សព្វផ្សាយ អំពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិនានា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសុវត្ថិភាព និងការអភិវឌ្ឍជាតិ ។ ទាំងនេះជាការរួមចំណែកដ៏ធំធេង ក្នុងការលើកកម្ពស់សន្តិសុខ សុវត្ថិភាពសង្គម និងសន្តិភាពជាតិឱ្យមានស្ថិរភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះ នៃការអភិវឌ្ឍជាតិគ្រប់វិស័យ ស្របតាមគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពតាមការគ្រោងទុក ៕

## សម្តេច ស ខេង៖ ព្រះពុទ្ធសាសនា គណៈធម្មយុត្តិកនិកាយ បានចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស ធ្វើជាទាសភាព ក្នុងសម័យទំនើប

https://dap-news.com/national/2022/12/12/298750/ ByKD102Posted on December 12, 2022

**ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងឱ្យដឹងថា ព្រះពុទ្ធសាសនា គណៈធម្មយុត្តិកនិកាយ បានចូលរួមសកម្មភាពជាតិសំខាន់ៗ ព្រមទាំងទប់ស្កាត់ការជួញដូរមនុស្ស ធ្វើជាទាសភាព ក្នុងសម័យទំនើប ដោយបង្រៀនពុទ្ធបរិស័ទឱ្យលើក កំពស់តម្លៃរបស់មនុស្សជាតិ។**

នាឱកាសអញ្ជើញជាអធិបតី ក្នុងពិធីបុណ្យខួបឆ្នាំទី៣១ គណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា (៧ ធ្នូ ១៩៩១-៧ ធ្នូ ២០២២) ប្រារព្ធនៅវត្តបទុមធម្មយុត្ត ក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី១១ ធ្នូ សម្តេច ស ខេង បានបញ្ជាក់ថា ព្រះពុទ្ធសាសនាគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា បានបម្រើផ្នែកជំនឿដល់ ពុទ្ធបរិស័ទគ្រប់ទិសទីទាំងអស់ មិនតែប៉ុណ្ណោះព្រះពុទ្ធសាសនា គណៈធម្មយុត្តិកនិកាយនេះ ជាផ្នែកមួយដ៏សំខាន់បំផុត ក្នុងការចូលរួមរក្សាការពារ សន្តិភាព នៅកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

សម្តេច មានប្រសាសន៍ថា «ព្រះពុទ្ធសាសនា គណៈធម្មយុត្តិកនិកាយ បានចូលរួមក្នុងសកម្មភាពជាតិ សំខាន់ៗមួយចំនួនមានជាអាទិ៍៖ ការទប់ស្កាត់ការជួញដូរមនុស្សធ្វើជាទាសភាព ក្នុងសម័យទំនើប ដោយបង្រៀនពុទ្ធបរិស័ទឱ្យលើកកំពស់តម្លៃ របស់មនុស្សជាតិ ការពារ និងរក្សាសន្តិភាពជាតិ មិនបង្កអសន្តិសុខដល់សង្គមជាតិ និងធ្វើសកម្មភាព មនុស្សធម៌ផ្សេងៗ តាមគន្លង នៃព្រះធម៌ នៃព្រះពុទ្ធសាសនា។ សម្តេច បន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយចំពោះ សាសនា បានយ៉ាងត្រឹមត្រូវ និង យ៉ាងទូលំទូលាយ ដោយមិនអនុញ្ញាតឲ្យមានការរើសអើង មិនប្រកាន់ពូជសាសន៍ មិនប្រកាន់ពណ៌សម្បុរ និងមិនប្រកាន់ជំនឿសាសនាអ្វីទាំងអស់ និងបានប្រកាន់ខ្ជាប់នូវការអប់រំ ពិសេសអប់រំស្រទាប់យុវជន និងកុមារ ឲ្យយល់ដឹងច្បាស់លាស់ អំពីតម្លៃដ៏វិសេសវិសាលនៃព្រះពុទ្ធសាសនា វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ដែលត្រូវតែចូលរួមថែរក្សា លើកតម្កើង អភិវឌ្ឍ ព្រមទាំងកាត់បន្ថយជាបណ្តើរៗ នូវឥទ្ធិពលជាអវិជ្ជមាននៃវប្បធម៌ ដែលជ្រៀតចូលពីបរទេស។

លើសពីនេះ សម្តេច ស ខេង បញ្ជាក់ទៀតថា រាជរដ្ឋាភិបាលក៏បានពង្រឹងសុខដុមនីយកម្ម រវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងការរើសអើង ប្រឆាំងការបែងចែកក្នុងចំណោម ប្រជាពលរដ្ឋដែលកាន់សាសនា ខុសគ្នា សំដៅប្រែក្លាយសក្តានុពល នៃសាសនាទាំងអស់ ឲ្យក្លាយទៅជាកម្លាំងជំរុញ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងពង្រឹងសន្តិភាព សាមគ្គីភាព ថែរក្សាប្រពៃណីជាតិ លើកតម្កើងសីលធម៌ និងរាំងស្កាត់ការយកសាសនាទៅធ្វើអាជីវកម្ម៕

## រកឃើញមនុស្សជាង១ពាន់នាក់ ក្រោយសុំអន្ត រាគមន៍ជួយសង្គ្រោះក្នុងរយៈពេលជាង៣ខែ

https://kohsantepheapdaily.com.kh/article/1650197.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ១២ ខែ ធ្នូ ឆ្នាំ ២០២២ ម៉ោង ១៦:៣៣

រាជធានីភ្នំពេញ ៖ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបានបញ្ជាក់ថា រយៈពេលជាង៣ខែចាប់ពីថ្ងៃទី១៨ ខែសីហា មកដល់ខែវិច្ឆិកា ២០២២ កន្លងទៅ សមត្ថកិច្ចរកឃើញមនុស្សចំនួន១១២២នាក់ ក្រោយសុំឱ្យធ្វើអន្តរាគមន៍ក្នុងគេហទំព័រហ្វេសប៊ុក សម្តេចក្រឡាហោម ស ខេង ដើម្បីជួយសង្គ្រោះពាក់ ព័ន្ធបទល្មើសនានា។

លោកជំទាវជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិ ការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងក្នុងទិវាជាតិ ប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំ ពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោល ដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ក្រោមអធិបតីភាព សម្តេចក្រឡា ហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ នៅសាលមហោស្រពកោះពេជ្ររាជធានីភ្នំពេញថា រាជរដ្ឋាភិបាលកម្ពុជាមិនអាចព្រងើយកន្តើយបានឡើយ ហើយត្រូវឆ្លើយតបជាបន្ទាន់ តាមវិធានការបោសសម្អាត បទល្មើសយ៉ាងមានប្រសិទ្ធ ភាពនោះគឺ «ផែនការប្រតិបត្តិ ការបង្កើនការបង្ក្រាបអំពើជួញ ដូរមនុស្សគ្រប់ទំរង់ និងបទល្មើសពាក់ព័ន្ធ» តាមសេចក្តីសម្រេចរបស់ គ.ជ.ប.ជ និងបង្កើតក្រុម ការងារប្រតិបត្តិការដឹកនាំដោយ អគ្គស្នងការនគរបាលជាតិ និងបើកយុទ្ធនាការនៅទូទាំងប្រទេស រុករកបទល្មើសបណ្តាញជន ល្មើស និងសង្គ្រោះជនរងគ្រោះ នៅតាមទីតាំងដែលមានការសង្ស័យយ៉ាងសកម្ម។

លោកជំទាវបានគូសបញ្ជាក់ថា «៦៧៦សំណើ ត្រូវបានដាក់ចូលក្នុងគេហទំព័រហ្វេសប៊ុក សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយផ្ទាល់ និងត្រូវបានស៊ើបអង្កេត និងបង្ក្រាបបទល្មើសបន្តបន្ទាប់ ។ ជាលទ្ធផលគិតចាប់ពីថ្ងៃទី១៨ ខែសីហា មកដល់វិច្ឆិកា ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះសុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ យើងបានរកឃើញមនុស្សចំនួន ១១២២នាក់ ស្រី

១២១នាក់ ហើយក្នុងចំណោមជនទាំងនោះ អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន និងពលកម្មដោយបង្ខំ ១៥៣នាក់ ស្រី១៨នាក់ មាន៦សញ្ជាតិ និងដោយអំពើចំណែកជនក្រៅពីនេះ បានបដិសេធថា ខ្លួនមិនបានទទួលភាពរងគ្រោះទេ និងមានបំណងចង់ប្តូរទៅទីតាំងការងារថ្មីដែលមាន ប្រាក់ខែខ្ពស់ជាងនេះ ឬថា គ្រាន់តែជាការបារម្ភរបស់ក្រុមគ្រួសារតែប៉ុណ្ណោះ»។

ជាមួយគ្នានោះដែរ លោកជំទាវរដ្ឋលេខាធិការបន្ថែមថា ទោះបីជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែនាំចេញពីទីតាំងដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីសុវត្ថិភាព ពលករ និងមិនអនុ ញ្ញាតឱ្យវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញឡើយ ។ គិតពីចាប់ផ្តើម ប្រតិបត្តិការដល់ត្រឹម ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ជនសង្ស័យ ២២នាក់ មាន ៣សញ្ជាតិ ដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ២នាក់ និងជនសង្ស័យពាក់ព័ន្ធ នឹងអំពើជួញដូរផ្លូវភេទ ៤នាក់ ១សញ្ជាតិ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់កម្ពុជា។ ទីតាំងសង្ស័យប្រព្រឹត្តបទល្មើសចំនួន៥ ត្រូវបានបិទជាស្ថាពរ និង៤ ទីតាំងបិទបណ្តោះអាសន្ន ដើម្បីស្រាវជ្រាវរកបទល្មើស។

លោកជំទាវលើកឡើងថា ក្រោមវិសាលភាពនៃការអភិវឌ្ឍន៍រីកចម្រើន វិស័យសំណង់ហេដ្ឋាចនាសម្ព័ន្ធ វិស័យសេវាកម្ម វិស័យ ពាណិជ្ជកម្មវិស័យឧស្សាហកម្ម, វិស័យកសិកម្ម បរិស្ថាន និងការអភិវឌ្ឍន៍ជនបទ បានបង្កើនការងារឱ្យ ប្រជាពល រដ្ឋក្នុងស្រុក រាប់សែននាក់ ។ ទន្ទឹមនឹងនោះ ប្រជាជនមួយចំនួន នៅតែមានបំណងចេញទៅរក ការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន មិនស្តាប់ការអប់រំណែនាំមិនតាមដាន ព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្លាប់ និងជឿការអូសទាញ កួតកពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរ មនុស្ស និងខាតបង់យ៉ាងធ្ងន់ធ្ងរ៕

## ពលករខ្មែរមួយក្រុមធ្វើការនៅប្រទេសថៃ ត្អូញត្អែរពីថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយមិនបើកប្រាក់ខែឲ្យពួកគាត់

https://www.rfa.org/khmer/news/social-economy/a-group-of-cambodian-workers-working-in-thailand-complain-about-their-employers-exploiting-them-for-not-paying-their-salaries-12112022182701.html ដោយ ជាតិ ចំណាន2022.12.11

ពលករខ្មែរមួយក្រុមធ្វើការសំណង់នៅប្រទេសថៃ ត្អូញត្អែរពីថៅកែថៃកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយមិនបើកប្រាក់ខែឲ្យពួកគាត់អស់ជាច្រើនខែ។ ពួកគាត់ថា ពេលទៅទាមទារបើកប្រាក់ខែ ថៅកែថៃគំរាមហៅប៉ូលិសមកចាប់ ហើយមកទល់ពេលនេះនៅមិនទាន់បានសំណងត្រឹមត្រូវពីថៅកែថៃនោះទេ។ ពលករខ្មែរប្រមាណ៥០នាក់ ធ្វើការសំណង់នៅខេត្តរ៉ាក់យ៉ង (Rak Yong) ប្រទេសថៃ ត្រូវថៅកែថៃ បោកប្រាស់ មិនព្រមបើកប្រាក់ឈ្នួលឲ្យពួកគាត់ ក្នុងម្នាក់ៗប្រហែល៣ខែហើយ។ ពួកគាត់បានចាកចេញពីថៅកែចាស់ឈ្មោះលោក វីឆា និងលោកស្រី ចេ នីម ជាអ្នកម៉ៅការសំណង់ក្រុមហ៊ុន ណាខនសាវ៉ាន់គ្រុប (Nakhon Sawan Group)ទៅរកការងារថ្មីធ្វើនៅទីក្រុងបាងកក និងនៅខេត្តផ្សេងៗទៀត ដោយមិនទាន់បានទទួលសំណងពីថៅកែចាស់នោះឡើយ។

ពលករខ្មែរម្នាក់ ធ្វើការក្នុងប្រទេសថៃជិត១០ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ លោក ជន សន ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី១១ ខែធ្នូ ថា លោក និងពលករខ្មែរ រួមនឹង ភូមា (Myanmar) ប្រមាណ៨០នាក់ ត្រូវថៅកែថៃ ប្រើឲ្យធ្វើការ ដោយសន្យាបើកប្រាក់ខែឲ្យពួកគាត់ ប៉ុន្តែមិនព្រមបើកឱ្យអស់ជាច្រើនខែហើយឲ្យរហូតមកទល់ពេលនេះ។ លោកបន្តថា លោក និងពលករឯទៀត បានទៅរកការងារនៅកន្លែងផ្សេង ដើម្បីរកប្រាក់មកចាយវាយប្រចាំថ្ងៃ ព្រោះបើចាំថៅកែចាស់នោះ ពួកគាត់នឹងគ្មានអាហារហូបនោះទេ។លោកស្នើដល់ស្ថានទូតខ្មែរ

ជួយដល់ពលករខ្មែរឲ្យទទួលបានសំណងសមរម្យពីថៅកែថៃ៖ «អត់បង! អត់! សព្វថ្ងៃអត់មានឲ្យខ្ញុំទេបង កាលណាយើងទៅទារទៅរករឿងយកតម្រួតមកគំរាមយើង។ បងដឹងថៅកែហ្នឹងវាដូចថា វាបើកលុយហើយអត់ឲ្យយើង វាអត់ឲ្យយើងបណ្ដោយបង។ ខ្ញុំធ្វើការនៅថៃយូរឆ្នាំដែរហើយ ប្រហែលជាប្អូនដប់ឆ្នាំ អត់ដែលប៉ះទេបង ទើបប៉ះមួយនេះឯងអត់ឲ្យយើងបណ្ដោយ»។

ចំណែកពលករខ្មែរម្នាក់ទៀត ជាអ្នកបកប្រែនៅខេត្តសុរិន្ទ (Surin) លោក ជ័យ មង្គល ប្រាប់ថា លោកតែងទៅជួយសម្របសម្រួល នៅពេលដែលថៅកែថៃកេងប្រវ័ញ្ចពលករខ្មែរ។ លោកបញ្ជាក់ថា ពលករខ្មែរជាច្រើនដែលថៅកែមិនបើកប្រាក់ឈ្នួលឲ្យ និងរងការរំលោភសិទ្ធិការងារនោះ មានដូចជា កម្មករសំណង់ កម្មកររោងចក្រ និងកម្មករក្នុងវិស័យផ្សេងទៀត។ លោកអំពាវនាវដល់ក្រសួងការងារកម្ពុជា និងស្ថានទូតខ្មែរចុះជួយពលករដែលកំពុងរងទុក្ខលំបាក ដោយសារថៅកែកេងប្រវ័ញ្ចទាំងនោះ៖ «បើថៅកែហ្នឹងមិនបើកអាប្រាក់ខែឲ្យយើង យើងអាចទៅប្ដឹងបានតើ! ខ្ញុំធ្លាប់ធ្វើបកប្រែឲ្យកម្មករខ្មែរនៅថៃប៉ុន្មានដងហើយបាទ អាហ្នុងជួនកាលគាត់អត់ដឹងណា ជួនកាលគាត់ខ្លាចគាត់ យើងមិនដឹងថាគាត់ទៅដោយស្ថានភាពយ៉ាងណានោះណា ការងារកម្មករអត់មានក្រដាសស្នាមអ៊ី អាហ្នុងធ្វើឲ្យគាត់ខ្លាច»។ កន្លងមកក៏មានពលករខ្មែរប្រមាណមួយរយនាក់ ធ្វើការសំណង់នៅទីក្រុងបាងកក ត្រូវថៅកែថៃមិនបើកប្រាក់ខែឲ្យពួកគាត់ដែរ។ ពួកគាត់ខ្វះស្បៀងអាហារ អស់ជាច្រើនខែ ហើយក៏មិនបានទទួលសំណងពីថៅកែថៃដូចគ្នា។

ជុំវិញរឿងនេះ មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា (Central) លោក លឹង សុផុន លើកឡើងថា ពលករខ្មែរ ដែលភាគច្រើនថៅកែថៃមិនសូវគោរពសិទ្ធិការងាររបស់ពួកគាត់ គឺច្រើនតែពលករមានឯកសារមិនគ្រប់គ្រាន់ និងពលករដែលឆ្លងដែនទាំងប្រថុយប្រថាន។ ទោះយ៉ាងណាលោកស្នើដល់ ពលករខ្មែរត្រូវសិក្សាឲ្យបានច្បាស់លាស់ពីការងារនៅប្រទេសថៃ ដើម្បីចូលធ្វើការងារឱ្យស្របច្បាប់ ហើយជៀសវាងថៅកែរំលោភបំពាន៖ «បងប្អូនពលករដែលគេមិនបើកលុយឲ្យ ភាគច្រើនអ្នកដែលរ៉ាប់ម៉ៅតគ្នាអ៊ីចឹង ថៅកែរ៉ាប់ម៉ៅហ្នឹងគាត់ គាត់ថាពេលខ្លះទៅគាត់អត់មានលុយបើកឲ្យទៅ ពេលខ្លះទៅគាត់ចេះតែពន្យារណា មិនដឹងថាជាលេសរបស់គាត់ ឬជាស្អីទេ តែគាត់លក្ខណៈថា អើ!ចាំសន្យាអ៊ីចឹង ពលករភាគច្រើនគាត់មិនដឹងជាទៅណា គាត់អត់មានលុយក្នុងការហូបគ្រប់គ្រាន់អ៊ីចឹង គាត់ក៏លក្ខណៈនៅចាំអ៊ីចឹងទៅ ហើយធ្វើការខ្ចីលុយគេចាយហូបប្រចាំថ្ងៃអ៊ីចឹងទៅណា»។ មន្ត្រីសង្គមស៊ីវិលរូបនេះ ក៏ធ្លាប់លើកឡើងថា រដ្ឋាភិបាលខ្មែរ និងថៃ គួរតែឲ្យពលករខ្មែរធ្វើឯកសារការងារ បង់សេវាក្នុងតម្លៃសមរម្យ ដើម្បីងាយស្រួលដល់ពួកគាត់ទទួលបានការងារស្របច្បាប់។

របាយការណ៍របស់ក្រសួងការងារកម្ពុជា ឲ្យដឹងថា ពលករខ្មែរ ដែលកំពុងធ្វើការក្នុងប្រទេសថៃ ហើយបានចុះក្នុងបញ្ជីការងាររបស់ក្រសួងស្របតាមស្តង់ដារប្រមាណ មួយលានពីរសែន (១.២០០.០០០) នាក់។ ចំណែករបាយការណ៍របស់អង្គការសង់ត្រាល់ (Central) រកឃើញថា ពលករខ្មែរ ដែលកំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់មានជាងពីរលាន(២.០០០.០០០)នាក់៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://www.gdlf-kh.com/2022/12/11/-58/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអាទិត្យ ៣រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃ ទី១១ ខែធ្នូ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ ឯកឧត្តមឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៦នាក់ ស្រី៦នាក់ ក្មេង៦នាក់ ក្មេងស្រី១នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងធ្វើការពិនិត្យប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្តិ៍ជាលទ្ធផលត្រឹមត្រូវទាំងអស់ បន្ទាប់មកកម្លាំងយើងបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## អ្នកធ្វើការខាងសិទ្ធិស្ត្រី
## ទទូចឲ្យរដ្ឋាភិបាលបង្កើតច្បាប់ប្រឆាំងការរើសអើងលើស្ត្រី និងយេនឌ័រ

https://www.rfi.fr/km//20221212-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 12/12/2022

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW) ទទូចឲ្យរដ្ឋាភិបាលកម្ពុជាដាក់ចេញជាជំហានចាំបាច់ដើម្បីឆ្ពោះទៅរកជោគជ័យលើកការងារប្រឆាំងការរើសអើងលើស្ត្រី និងអ្នកដែលមិនកំណត់អត្តសញ្ញាណយេនឌ័រ។ ការទទូចបែបនេះធ្វើឡើងសម្រាប់យុទ្ធនាការ១៦ថ្ងៃ ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ក៏ដូចជាសម្រាប់ទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០២២នេះផងដែរ។

តាមរយៈសេចក្តីថ្លែងការណ៍ថ្ងៃទី៩ធ្នូដែលទើបតែចេញផ្សាយជាសាធារណៈនៅថ្ងៃទី១២ធ្នូ អង្គការមិនមែនរដ្ឋាភិបាលចំនួន១៧ស្ថាប័នដែលធ្វើការងារផ្តោតលើសិទ្ធិស្ត្រី និងសិទ្ធិមនុស្ស បានអំពាវនាវរួមគ្នាឲ្យរដ្ឋាភិបាលបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងដែលមានលក្ខណៈពេញលេញ។ នោះដើម្បីធានាថាយន្តការច្បាប់នេះត្រូវបានអនុវត្តនូវសិទ្ធិរបស់ស្ត្រី ដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស៊ី-ដ ហើយលុបចោលរាល់មាត្រាទាំងអស់នៅក្នុងច្បាប់ទាំងឡាយណាដែលមិនស្របនឹងសិទ្ធិទាំងនេះ។ ក្រៅពីការអំពាវនាវឲ្យបង្កើតប្រឆាំងការរើសអើង ក្រុមអង្គការទាំងនោះ ក៏អំពាវនាវឲ្យរដ្ឋាភិបាល បម្រុងថវិកាជំនួយរយៈពេលវែងសម្រាប់អនុវត្តការងារបញ្ជ្រាបយេនឌ័រ ប្រយោជន៍បង្កើនសមភាពយេនឌ័រលើគ្រប់វិស័យ។ រដ្ឋាភិបាលក៏ចាំបាច់ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដើម្បីឆ្លុះបញ្ចាំងថាសិទ្ធិរបស់អ្នកនៅរស់រានមានជីវិតពីអំពើហិង្សាស្របទៅតាមជម្រើសរបស់ពួកគេក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។ នេះបើតាមសេចក្តីថ្លែងការណ៍ដដែល។

ក្រុមអ្នកធ្វើការខាងសិទ្ធិ ក៏ទទួចផងដែរឲ្យរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិខាងការងារ(ILO)លេខ១៩០ស្តីពីការលុបបំបាត់អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ និងផ្តល់និយមន័យគ្រប់ជ្រុងជ្រោយ និងផ្តល់ដំណោះស្រាយគ្រប់ទម្រង់នៃការបៀតបៀន។ អំពើបៀតបៀននេះ ត្រូវបានអង្គការសង្គមស៊ីវិលកត់សំគាល់ថា តែងតែកើតឡើងទៅលើស្ត្រីជាអ្នកតវ៉ានៅក្រុមហ៊ុនណាហ្គាវើលដ៍ពីសំណាក់កងសន្តិសុខ ហើយបុគ្គលដែលប្រព្រឹត្តិគួរតែត្រូវចាប់ឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ៕

## កម្លាំងនគរបាល
## ចុះត្រួតពិនិត្យច្រករបៀងកម្ពុជា- ថៃ ទប់ស្កាត់ពលករលួចឆ្លងដែន មនុស្សខុសច្បាប់

https://www.khmertimeskh.com/501201064// កែវ រចនា / Khmer Times December 12, 2022

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ កម្លាំងចម្រុះនៅច្រកដើមខ្នុរ បានដឹកនាំកម្លាំង ដើម្បីត្រួតពិនិត្យ និងទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់តាមបន្ទាត់ព្រំដែនកម្ពុជា–ថៃ។ កម្លាំងចម្រុះបានពិនិត្យឃើញថា នៅចំណុចទីតាំងច្រករបៀងដើមខ្នុរនោះពុំមានពលករឆ្លងដែនខុសច្បាប់នោះទេ។ ការចុះពិនិត្យនេះ គឺក្រោយមានការចុះផ្សាយថា ច្រកនេះមានអ្នកលួចឆ្លងដែន ខុសច្បាប់ទៅប្រទេសថៃ។ យ៉ាងណា លោកវីរសេនីយ៍ឯក សួង សៅ ក៏បានអំពាវនាវដល់អ្នកសារព័ត៌មាន សូមចុះផ្សាយព័ត៌មានឲ្យមានវិជ្ជាជីវៈ យកព័ត៌មានពិត ច្បាស់លាស់ ជៀសវាងផ្សាយព័ត៌មានមិនពិត នាំឲ្យប៉ះពាល់ដល់កិត្តិយស បំបាក់ទឹកចិត្ត បើមិនបានលើកទឹកចិត្តទេ កុំបំពានកងកម្លាំងដែលការពារព្រំដែន លះបង់ចាកឆ្ងាយពីប្រពន្ធកូន ផ្ទះសម្បែង ដោយគោរពបទបញ្ជាថ្នាក់ដឹកនាំ ការពារបទល្មើស នឹងពលករឆ្លងដែនខុសច្បាប់ តាមខ្សែរបន្ទាត់ការពារព្រំដែនផងដែរ៕

## រដ្ឋមន្ត្រីការងារ ដាក់ឲ្យប្រើប្រាស់សៀវភៅគោលការណ៍ ណែនាំស្តីពីអធិការកិច្ចការងារ ជាផែនទីបង្ហាញផ្លូវ សម្រាប់ចុះធ្វើអធិការកិច្ចការងារ

http://freshnewsasia.com/index.php/en/localnews/269338-2022-12-12-07-41-20.html 2022-12-12 02:41pm

**(ភ្នំពេញ)៖** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ បានប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ នូវសៀវភៅគោលការណ៍ណែនាំ ស្តីពីអធិការកិច្ចការងារ ដែលជាផែនទីបង្ហាញផ្លូវដ៏មានសារសំខាន់ សម្រាប់អធិការការងារ សម្រាប់ពង្រឹងយន្តការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាព សំដៅលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ និងភាពសុខុដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣។

លោក អ៊ិត សំហេង បានលើកឡើងថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកែសម្រួលយន្តការអធិការកិច្ចការងារ តាមរយៈការប្រមូលបញ្ចូលគ្នាក្រុមអធិការកិច្ចការងារច្រើនក្រុមឱ្យទៅជាក្រុមអធិការកិច្ចការងារតែមួយ និងទំនើបកម្មការធ្វើអធិការកិច្ចការងារផ្ទៃក្នុង សំដៅលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ ដោយក្រសួងបានបន្តពង្រឹងយន្តការក្រុមអធិការកិច្ចការងារតែមួយ សំដៅកាត់បន្ថយការរំខានដល់ប្រតិបត្តិការអាជីវកម្ម កាត់បន្ថយបន្ទុករបស់ម្ចាស់រោងចក្រ សហគ្រាស និងធានាប្រសិទ្ធភាព និងអនុលោមភាពតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងចុះអធិការកិច្ច ដោយផ្តោតលើចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាសនីមួយៗ។ គិតត្រឹម៩ខែ ឆ្នាំ២០២២ ក្រសួងបានចុះអធិការកិច្ចការងារសរុបចំនួន ៣ ៤៦៤លើក ក្នុងនោះ

អធិការកិច្ចការងារសាមញ្ញចំនួន ៣ ៣៤៤លើក ចុះធ្វើអធិការកិច្ចតាមដានការដាក់កំហិតចំនួន ១០លើក និងចុះអធិការកិច្ចការងារពិសេសចំនួន ១១០លើក។

តាមរយៈការចុះអធិការកិច្ចការងារនេះ ពិនិត្យឃើញថា អត្រារោងចក្រ សហគ្រាស ដែលមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានទាក់ទងនឹងវិស័យការងារមានការថយចុះជាបន្តបន្ទាប់។ ក្រសួងបានអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងវិស័យការងារឱ្យក្លាយជាអធិការការងារ អធិការពេទ្យការងារ និងអភិបាលការងារ ដោយបានផ្តល់វិក្រឹត្យការដល់មន្ត្រីអធិការកិច្ចការងារ ដើម្បីមាននីតិសម្បទាគ្រប់គ្រាន់ជាមន្ត្រីនគរបាលយុត្តិធម៌។ បន្ថែមលើនេះទៀត ដើម្បីគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារ សំដៅពង្រឹងប្រសិទ្ធភាពនៃចុះអធិការកិច្ចការងារ ក្រសួងបានដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម កាលពីថ្ងៃ១ ខែមករា ឆ្នាំ២០២២។

លោករដ្ឋមន្ត្រីសង្កត់ធ្ងន់ថា តាមរយៈវេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនលើកទី១៨ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវវិធានការកំណែទម្រង់មុតស្រួចជាកញ្ចប់សំដៅពង្រឹងភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់បរិយាកាសវិនិយោគនៅកម្ពុជាក្នុងនោះ បានកំណត់នូវអាទិភាពក្នុងការរៀបចំក្រុមអធិការកិច្ចអន្តរស្ថាប័ន និងចុះតែមួយលើកចំពោះគោលដៅតែមួយ ដោយប្របាច់បញ្ចូលក្រុមអធិការកិច្ចទាំងអស់ឱ្យទៅជាក្រុមតែមួយនិងចុះតែមួយលើកក្នុង១ឆ្នាំ ចំពោះគោលដៅមួយ ដោយរៀបចំជាបញ្ជីសកម្មភាពអធិការកិច្ចនិងការកំណត់ពេលវេលាចុះឱ្យបានច្បាស់លាស់ លើកលែងតែមានករណីចាំបាច់ ឬករណីមានបទល្មើស ដែលត្រូវឱ្យមានការធ្វើអធិការកិច្ចពិសេសដោយឡែក របស់ក្រុមការងារជំនាញមានសមត្ថកិច្ច។ បច្ចុប្បន្ន ក្រុមការងាររៀបចំក្រុមអធិការកិច្ចអន្តរស្ថាប័នក្នុងវិស័យចំនួន ៣ ត្រូវបានបង្កើត រួមមាន វិស័យកម្មន្តសាល, វិស័យ កសិកម្ម និងវិស័យឧស្សាហកម្មទេសចរណ៍ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធចំនួន ៦ ដូចជា វិស័យកម្មន្តសាល វិស័យកសិកម្ម និងវិស័យឧស្សាហកម្មទេសចរណ៍។

**លោករដ្ឋមន្ត្រីសង្ឃឹមថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តតាមសៀវភៅគោលការណ៍ណែនាំនេះដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារប្រកបដោយស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ ព្រមទាំងណែនាំនូវចំណុចមួយចំនួនដូចខាងក្រោម៖**

១. អគ្គនាយកដ្ឋានការងារបន្តអនុវត្តឱ្យបានសមស្រប និងទទួលបន្ទុកដឹកនាំសម្របសម្រួល ភាគីពាក់ព័ន្ធក្នុងតាមដាន និងត្រួតពិនិត្យលើការអនុវត្តរាល់វិធានការ និងសកម្មភាពដែលបានដាក់ចេញក្នុងសៀវភៅគោលការណ៍ណែនាំនេះ ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមការរំពឹងទុក។

២. អធិការការងារទាំងអស់ត្រូវតែស្វែងយល់ និងអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមគោលការណ៍ណែនាំនេះ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការចុះធ្វើអធិការកិច្ចការងារ សំដៅធានាបាននូវការលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ និងភាពសុខុដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ។

៣. អធិការការងារទាំងអស់ត្រូវបន្តអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំទាំងចំណេះដឹង និងចំណេះធ្វើ ដើម្បីក្លាយជាអធិការងារដែលមានសមត្ថភាពក្នុងការបំពេញ ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព៕

# ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០២២

## រាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការប្រតិបត្តិការ ដើម្បីរុករក បង្ក្រាប និងចោទសម្អាតបទល្មើសជួញដូរមនុស្ស គ្រប់ទម្រង់

https://cen.com.kh/archives/588290.html Posted ByPen Srey NeatDecember 13, 2022

ភ្នំពេញ៖ សម្ដេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ពិធីអបអរទិវាជាតិ១២ធ្នូប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ ក្រោមប្រធានបទ«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព» ប្រារព្ធនៅមជ្ឈមណ្ឌលកោះពេជ្រនារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២នេះ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ បានឱ្យដឹងថាក្នុងឆមាសទី១ នៃឆ្នាំ២០២២ ស្ថានភាព នៃអំពើជួញដូរមនុស្ស មានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះ គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។ នៅពេលដែលស្ថានភាពទូទៅ បានរៀបរយល្អប្រសើរហើយចំពោះសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បែរជាកើតមានបទល្មើសថ្មី លើទឹកដីកម្ពុជាដែលបង្កឡើងដោយឧក្រិដ្ឋជនមួយចំនួន សម្ងំលាក់ខ្លួនប្រព្រឹត្តបទល្មើស ក្នុងអាជីវកម្មបន្លំភ្នែក ដោយប្រើប្រាស់ឱកាសដ៏ល្អ ដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងផ្ដល់ឱ្យ សម្រាប់ការវិនិយោគ ដើម្បីការអភិវឌ្ឍន៍ នៅក្នុងតំបន់ប៉ូលសេដ្ឋកិច្ចធំៗ ដូចជា ខេត្តព្រះសីហនុ រាជធានីភ្នំពេញ ជាដើម និង បណ្ដាខេត្តមួយចំនួនទៀត ទៅធ្វើសកម្មភាពឧក្រិដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ គិតចាប់ពីថ្ងៃ ទី១៨ ខែសីហា មកដល់ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះ សុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន ១១២២នាក់ ស្រី ១២១នាក់ ហើយ តែក្នុងចំណោមជនទាំងនោះ អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន និងពលកម្មដោយបង្ខំ ១៥៣នាក់ ស្រី១៨នាក់ មាន៦សញ្ជាតិ និងដោយអំពើ ចំណែកជនក្រៅពីនេះ បានបដិសេធថាខ្លួន មិនបានទទួលភាពរងគ្រោះទេ និងមានបំណងចង់ប្ដូរទៅទីតាំងការងារថ្មីដែលមានប្រាក់ខែខ្ពស់ជាងនេះ ឬថា គ្រាន់តែជាការបារម្ភ របស់ក្រុមគ្រួសារតែប៉ុណ្ណោះ។ លោកជំទាវរដ្ឋលេខាធិការបន្តថា រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែ នាំចេញពីទីតាំងដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីសុវត្ថិភាពពលករ និងមិនអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញឡើយ ហើយគិតពីចាប់ផ្ដើមប្រតិបត្តិការដល់ត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ជនសង្ស័យ២២នាក់ មានបីសញ្ជាតិ ដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ២២នាក់ និងជនសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ ០៤នាក់ ០១ សញ្ជាតិ ត្រូវបាន កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការ តាមនីតិវិធីច្បាប់កម្ពុជា។ ទីតាំងសង្ស័យប្រព្រឹត្តបទល្មើស ចំនួន៥ ត្រូវបានបិទជាស្ថាពរ និងបួនទីតាំងបិទបណ្ដោះអាសន្នដើម្បីស្រាវជ្រាវរកបទល្មើស។

សម្ដេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្ដីទី និងជាប្រធាន គ.ជ.ប.ជ មានប្រសាសន៍ថា ឆ្នាំ២០២២ នេះ ជាឆ្នាំដែលមានឱកាសអាចរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្សក្រោមប្រធានបទ រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកប ដោយចីរភាព ដែលស្របទៅទស្សនវិស័យ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរក្សានូវសន្តិសុខ សុវត្ថិភាពសង្គម ដើម្បីជាមូលដ្ឋានបង្អែក នៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យក្នុងរយៈពេលវែង។ សម្ដេចបន្តថា គ.ជ.ប.ជ តែងប្រារព្ធរៀបចំកម្មវិធីទិវាជាតិនេះជារៀងរាល់ឆ្នាំ

យ៉ាងអធិកអធម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងតាមបណ្ដាសាលារៀនគ្រប់ប្រកលួក នៅទូទាំងប្រទេស ដែលមានអ្នកចូលរួម រហូតដល់រាប់សែននាក់។

សម្ដេចមានប្រសាសន៍ថា ចរន្តនៃការវិលត្រឡប់មកវិញដោយឥតគ្រោងទុករបស់ពលករកម្ពុជា ពីប្រទេសគោលដៅ ក្នុងអំឡុងកូវីដ-១៩ ជាពិសេស ក្នុងឆ្នាំ២០២០ និង២០២១ បានកើនរហូតដល់ជាង ៣០ម៉ឺននាក់ និងថាក្នុងដំណាក់កាលនេះហើយដែលការគ្រប់គ្រងព្រំដែន មានភាពប្រឈម ស្មុគស្មាញ ដោយចំនួននៃពលករ វិលត្រឡប់ កើនឡើងយ៉ាងគំហុក ជារៀងរាល់ថ្ងៃ ក្នុងនោះជនទេសន្តរប្រវេសន៍បរទេសខុសច្បាប់ជាច្រើន មានឱកាសបន្លំខ្លួន ចូលមកកម្ពុជា ដោយខុសច្បាប់ និងបានសម្ងំលាក់ខ្លួន ធ្វើការងារជាមួយនិយោជក ទុច្ចរិតមួយចំនួន ដែលបង្កើតបានជាបទល្មើសយ៉ាងអាណាធិបតេយ្យ លើទឹកដីកម្ពុជា។

សម្ដេចបន្ថែមថា ស្ថិតក្នុងស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជា មិនបានព្រងើយកន្តើយឡើយ បានដាក់ចេញនូវវិធានការប្រតិបត្តិការ ដើម្បីរុករក បង្ក្រាប និងបោសសម្អាតបទល្មើសជួញដូរមនុស្ស គ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធដទៃទៀត យ៉ាងសកម្ម តាមវិធានការច្បាប់ រហូតធ្វើឲ្យកម្ពុជា វិលត្រឡប់មករកស្ថានភាពសុវត្ថិភាព និងសន្តិសុខជាប្រក្រតីឡើងវិញ នៅទូទាំងផ្ទៃប្រទេស និងថារាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេស អំពើជួញដូរមនុស្ស និងបន្តអនុវត្តរាល់បទដ្ឋានដែលជាប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធិ និងកិច្ចការពារសុវត្ថិភាពមនុស្សជាតិ។

សម្ដេចបន្ថែមថា«កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការរៀបចំ អនុម័ត អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស កតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលហៅកាត់ថា GCM រហូតត្រូវ បានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផ្នែកទេសន្តរប្រវេសន៍ ថាជា « ប្រទេស ជ័យលាភី នៃគំនិតផ្ដួចផ្ដើម របស់កតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍» ក្នុងការប្ដេជ្ញាចិត្តខ្ពស់ការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ពលករទេសន្តរប្រវេសន៍ និងការពារពួកគេពីភាពរងគ្រោះ ដោយការរំលោភបំពាន និងកេងប្រវ័ញ្ច គ្រប់រូបភាព»។

ជាមួយគ្នានេះ សម្ដេចបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ គ្រប់សមាសភាព នៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានក្រសួង ស្ថាប័ន និងអង្គភាពជំនាញទាំង២៧ ជាសមាជិក និងមានរចនាសម្ព័ន្ធតាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ រួមជាមួយនឹងការចូលរួមគាំទ្រយ៉ាងសកម្មពី បណ្ដាទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការដៃគូអន្តរជាតិ អង្គការសង្គមស៊ីវិលក្នុងស្រុក និងវិស័យឯកជន ដែលបានខិតខំប្រឹងប្រែងរួមគ្នា រិះរកគ្រប់មធ្យោបាយ ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ ព្រមទាំងផ្ដល់កិច្ចការពារជនរងគ្រោះ ទាំងស្ត្រី បុរស និងកុមារ និងបានចូលរួមដោះស្រាយបញ្ហាជាច្រើន សម្រាប់ប្រជាពលរដ្ឋតាមសហគមន៍ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលគ្មានសុវត្ថិភាព។

នាឱកាសនោះដែរ សម្ដេចបានអំពាវនាវថ្នាក់ដឹកនាំ មន្ត្រីរាជការ អាជ្ញាធរ កម្លាំងសមត្ថកិច្ច និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ខិតខំតាមដានបាតុភាព និងបទល្មើសផ្សេងៗ និងគ្រប់គ្រងព្រំដែនឲ្យបានគត់មត់ ដើម្បីទប់ស្កាត់មូលហេតុរួមផ្សំ ដែលនាំឲ្យមានអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ រួមគ្នាលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍ដែលគ្មានសុវត្ថិភាព ខុសច្បាប់ និងការងារខុសច្បាប់។ សម្ដេចក៏ស្នើថ្នាក់ដឹកនាំគ្រប់និកាយសាសនា បន្តការផ្សព្វផ្សាយខ្លឹមសារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សាសនិកទាំងឡាយ នៅតាមសហគមន៍ទូទាំងប្រទេស ឲ្យបានយល់ជ្រួតជ្រាប ខ្លឹមសារ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមវិធានការ និងបានលើកទឹកចិត្តដល់គ្រប់វិស័យពាក់ព័ន្ធជាតិ និងអន្តរជាតិ សូមបន្តរិះរកនូវវិធានការជាគន្លឹះនានា និងរួមសហការគ្នាជាផ្លូង

មួយ ធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាក្នុងការ «បង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បី ព្រះរាជាណាចក្រកម្ពុជា គ្មានអំពើជួញដូរមនុស្ស»៕រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន ១១២២នាក់ ដែលជាជនរងគ្រោះ សុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ នៃអំពើជួញដូរមនុស្ស

https://cen.com.kh/archives/588347.html Posted ByPen Srey NeatDecember 13, 2022

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ បានឱ្យដឹងថា ក្នុងឆមាសទី១ នៃឆ្នាំ២០២២ ស្ថានភាព នៃអំពើជួញដូរមនុស្ស មានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះ គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ។ គិតចាប់ពីថ្ងៃ ទី១៨ ខែសីហា មកដល់ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះ សុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន ១១២២នាក់ ស្រី ១២១នាក់។ លោកជំទាវ ជូ ប៊ុនអេង បានថ្លែងយ៉ាងដូច្នេះ ក្នុងឱកាសពិធីអបអរទិវាជាតិ ១២ធ្នូប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព» ប្រារព្ធនៅមជ្ឈមណ្ឌលកោះពេជ្រនារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២នេះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហៅកាត់ថា គ.ជ.ប.ជ បានឱ្យដឹងថាក្នុងឆមាសទី១ នៃឆ្នាំ២០២២ ស្ថានភាព នៃអំពើជួញដូរមនុស្ស មានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះ គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។ នៅពេលដែលស្ថានភាពទូទៅ បានរៀបរយល្អប្រសើរហើយចំពោះសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បែរជាកើតមានបទល្មើសថ្មី លើទឹកដីកម្ពុជា ដែលបង្កឡើងដោយឧក្រិដ្ឋជនមួយចំនួន សម្ងំលាក់ខ្លួនប្រព្រឹត្តបទល្មើស ក្នុងអាជីវកម្មបន្លំភ្នែក ដោយប្រើប្រាស់ឱកាសដ៏ល្អ ដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងផ្តល់ឱ្យ សម្រាប់ការវិនិយោគ ដើម្បីការអភិវឌ្ឍន៍ នៅក្នុងតំបន់ប៉ូលសេដ្ឋកិច្ចធំៗ ដូចជា ខេត្តព្រះសីហនុ រាជធានីភ្នំពេញ ជាដើម និង បណ្តាខេត្តមួយចំនួនទៀត ទៅធ្វើសកម្មភាពឧក្រិដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ គិតចាប់ពីថ្ងៃ ទី១៨ ខែសីហា មកដល់ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះ សុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន ១១២២នាក់ ស្រី ១២១នាក់ ហើយ តែក្នុងចំណោមជនទាំងនោះ អ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន និងពលកម្មដោយបង្ខំ ១៥៣នាក់ ស្រី១៨នាក់ មាន៦សញ្ជាតិ និងដោយអំពើ ចំណែកជនក្រៅពីនេះ បានបដិសេធថាខ្លួន មិនបានទទួលភាពរងគ្រោះទេ និងមានបំណងចង់ប្តូរទៅទីតាំងការងារថ្មីដែលមានប្រាក់ខែខ្ពស់ជាងនេះ ឬថា គ្រាន់តែជាការបារម្ភ របស់ក្រុមគ្រួសារតែប៉ុណ្ណោះ។

លោកជំទាវរដ្ឋលេខាធិការបន្តថា រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែ នាំចេញពីទីតាំងដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីសុវត្ថិភាពពលករ និងមិនអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញឡើយ ហើយគិតពីចាប់ផ្តើមប្រតិបត្តិការដល់ត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ជនសង្ស័យ២២នាក់ មានបីសញ្ជាតិ ដែលសង្ស័យពាក់ព័ន្ធ

នឹងបទល្មើសជួញដូរមនុស្ស ២២នាក់ និងជនសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ ០៤នាក់ ០១ សញ្ជាតិ ត្រូវបាន កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការ តាមនីតិវិធីច្បាប់កម្ពុជា។ ទីតាំងសង្ស័យប្រព្រឹត្តបទល្មើស ចំនួន៥ ត្រូវបានបិទជាស្ថាពរ និងបួនទីតាំងបិទបណ្ដោះអាសន្នដើម្បីស្រាវជ្រាវរកបទល្មើស៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ជនជាតិឥណ្ឌូនេស៊ីបន្ថែមទៀតត្រូវបានសង្គ្រោះពីក្រុមជួញដូរនៅកម្ពុជា

https://www.khmertimeskh.com/501201675// Khmer Times December 13, 2022

ក្រសួងការបរទេសឥណ្ឌូណេស៊ីបាននិយាយកាលពីថ្ងៃអាទិត្យថា នគរបាលកម្ពុជាបានជួយសង្គ្រោះជនជាតិឥណ្ឌូនេស៊ីចំនួន៣៤ នាក់ដែលត្រូវបានចាញ់បោកឱ្យធ្វើការដោយបង្ខំ បន្ទាប់ពីពួកគេបានមកប្រទេសនេះក្នុងគោលបំណងធ្វើការងារដែលមានប្រាក់ខែខ្ពស់។ ជនរងគ្រោះម្នាក់បានព្យាយាមទាក់ទងទៅស្ថានទូតឥណ្ឌូណេស៊ីនៅភ្នំពេញកាលពីថ្ងៃព្រហស្បតិ៍ ហើយស្ថានទូតដឹងថាមានជនជាតិឥណ្ឌូនេស៊ីជាង៣០នាក់កំពុងត្រូវបានឃុំខ្លួនឱ្យធ្វើការនៅក្នុងក្រុមហ៊ុនបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតក្នុងក្រុងប៉ោយប៉ែតក្បែរព្រំដែនជាមួយប្រទេសថៃ។ ភ្លាមៗនោះ មន្ត្រីស្ថានទូតបានទាក់ទងនគរបាលក្នុងតំបន់ ដើម្បីជួយសង្គ្រោះពលករទាំងនោះ នេះបើយោងតាម Judha Nugraha ប្រធានការពារជនជាតិឥណ្ឌូនេស៊ីនៅក្រៅប្រទេស។

Judha បានប្រាប់អ្នកយកព័ត៌មាន BTV ថា "កាលពីថ្ងៃទី៩ ខែធ្នូ នគរបាលបានជួយសង្គ្រោះមនុស្ស៣១ នាក់ បន្ថែមពីលើបីនាក់ទៀតដែលត្រូវបានជួយសង្គ្រោះកាលពីមុន ដូច្នេះជនជាតិឥណ្ឌូនេស៊ី ៣៤ នាក់ត្រូវបានជួយសង្គ្រោះពីក្រុមហ៊ុនបោកប្រាស់តាមអ៊ីនធឺណិត" ។ "បច្ចុប្បន្ន ពួកគេមានសុវត្ថិភាព" ។ លោកបានបន្តថា ជនរងគ្រោះទាំងអស់កំពុងត្រូវបានសួរចម្លើយនៅស្នងការដ្ឋាននគរបាលក្រុងប៉ោយប៉ែត ហើយអាចចំណាយពេលមួយសប្ដាហ៍សម្រាប់ការស៊ើបអង្កេតដើម្បីសន្និដ្ឋានមុននឹងបញ្ជូនពួកគេទៅស្ថានទូតឥណ្ឌូនេស៊ី។ Judha បាននិយាយថា ចាប់តាំងពីឆ្នាំ២០២០ ជនជាតិឥណ្ឌូនេស៊ីជាង ១,០០០ នាក់បានក្លាយជាជនរងគ្រោះនៃបណ្ដាញជួញដូរមនុស្សក្នុងតំបន់ដែលប្រតិបត្តិការនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍មួយចំនួនដូចជាប្រទេសកម្ពុជា មីយ៉ាន់ម៉ា ហ្វីលីពីនឡាវ និងប្រទេសថៃ។

ពួកគេត្រូវបានសន្យាថានឹងទទួលបានប្រាក់ខែ ១,២០០ ដុល្លារក្នុងមួយខែដោយមិនចាំបាច់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ មន្ត្រីរូបនេះបាននិយាយថា ពួកគេគ្រាន់តែត្រូវធ្វើលិខិតឆ្លងដែន ហើយធ្វើដំណើរទៅប្រទេសជិតខាងដើម្បីទទួលបានការងារ។ Judha បានបន្ថែមថា "នៅពេលបានទៅដល់ប្រទេសគោលដៅ ពួកគេត្រូវបានបង្ខំឱ្យធ្វើការងារបោកប្រាស់ និងទទួលរងការគំរាមកំហែងប្រសិនបើពួកគេមិនបំពេញតាមគោលដៅបាន" ។ បណ្ដាញក្នុងតំបន់បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្ដល់ឱកាសការងារក្លែងក្លាយ ដូចជាបុគ្គលិកផ្នែកសេវាកម្មអតិថិជន ដែលមិនតម្រូវឱ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ លោកបាបនិយាយទៀតថា «ក្នុងចំណោមជនជាតិឥណ្ឌូនេស៊ី ១,០១៨ នាក់ដែលជាជនរងគ្រោះ មាន ៦៧៩ នាក់ត្រូវបានជួយសង្គ្រោះនៅកម្ពុជា។ វាជាការដាស់តឿនឲ្យយើងចាត់វិធានការបង្ការ»។ លោកបានបន្ថែមថា នគរបាលឥណ្ឌូណេស៊ីនឹងតាមដានការស៊ើបអង្កេតនៅពេលដែលជនជាតិឥណ្ឌូនេស៊ីទាំងអស់ត្រឡប់ទៅផ្ទះវិញ៕

## ឆមាសទី១នៃឆ្នាំ២០២២
## ស្ថានភាពនៃអំពើជួញដូរមនុស្សមានភាពល្អប្រសើរ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១

https://www.information.gov.kh/articles/93602 វិទ្យុជាតិកម្ពុជា ៖ ស៊ឹង សុផារី ១៣.១២.២០២២

អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានលើកឡើងថា ឆមាសទី១នៃឆ្នាំ២០២២ ស្ថានភាពនៃអំពើជួញដូរមនុស្សមានភាពល្អប្រសើរ បើប្រៀបធៀបទៅនឹង ឆ្នាំ២០២១ ដោយសារអត្រានៃបទល្មើសបានថយចុះគួរឱ្យកត់សម្គាល់ ។ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រសួងមហាផ្ទៃ បានមានប្រសាសន៍ក្នុងកម្មវិធីទិវាជាតិប្រឆាំងការជួញដូរ មនុស្ស ១២ ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅ សម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ថា រាជរដ្ឋាភិបាលកម្ពុជាបានខិតខំដោះស្រាយបញ្ហា ដែលជះឥទ្ធិពលពីវិបត្តិកូវីដ១៩ គួបផ្សំនឹងការប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកនិងគ្រោះធម្មជាតិ ដែល បានយាយីនៅគ្រប់ទីកន្លែង ជាពិសេសចំពោះការធ្វើសមាហរណកម្មពលករដែលបានត្រឡប់ពីប្រទេស គោលដៅប្រមាណជាង៣០ម៉ឺននាក់ ដែលភាគច្រើនជាអ្នកចាកចេញពីភូមិស្រុកក្នុងរយៈពេលយូរ ខ្វះលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពនិងងាយរងគ្រោះ ឱ្យទទួលបានស្ថានភាពល្អប្រសើរ មានការងារមុខរបរ ជាប្រក្រតី និងទទួលបានសេវាសង្គមទាំងឡាយ ។

លោកជំទាវ បានបន្តថា ក្នុងនោះនៅក្នុងឆមាសទី១ នៃឆ្នាំ២០២២កន្លងទៅ ស្ថានភាពនៃការជួញដូរមនុស្សក៏មានភាពល្អប្រសើរជាងបណ្តាឆ្នាំមុនៗ ដោយសារតែរាជរដ្ឋាភិបាលនៅតែបន្តយកចិត្តទុកដាក់ ពង្រឹង ការអនុវត្តន៍ច្បាប់ បង្កើនកិច្ចការពារជនរងគ្រោះ លើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសលើក កម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ។ សំឡេង៖ « នៅក្នុងឆមាសទីមួយនៃឆ្នាំ២០២២កន្លងទៅនេះ ស្ថានភាពនៃអំពើជួញដូរមនុស្សមានភាព ល្អប្រសើរ ដោយអត្រាដែលបទល្មើសបានថយចុះគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ក្នុងនោះ នៅពេលដែលស្ថានភាពទូទៅបានរៀបរយល្អប្រសើរហើយ ចំពោះសកម្មភាពការទប់ស្កាត់ និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បែរជាកើតមានបទល្មើសថ្មីនៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងដោយឧក្រិដ្ឋជនមួយចំនួន ដែលសម្ងំលាក់ខ្លួនប្រព្រឹត្ត បទល្មើសក្នុងអាជីវកម្មបន្លំភ្នែក ដោយប្រើប្រាស់ឱកាសដ៏ល្អដែលរាជរដ្ឋាភិបាលបាននិងកំពុងផ្តល់ឲ្យ សម្រាប់ការវិនិយោគដើម្បីការអភិវឌ្ឍនៅក្នុងតំបន់ប៉ូលសេដ្ឋកិច្ចធំៗ ដូចជាខេត្តព្រះសីហនុ រាជធានី ភ្នំពេញជាដើម និងបណ្តាខេត្តមួយចំនួនទៀត ដែលធ្វើសកម្មភាពឧក្រិដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស» ។

លោកជំទាវបានបន្ថែមថា ឧក្រិដ្ឋជន ដែលបានប្រព្រឹត្តសកម្មភាពឃោរឃៅទៅលើជនរងគ្រោះ ដោយពលកម្មដោយបង្ខំ ការឆបោកតាមប្រព័ន្ធអនឡាញ ការអូសទាញជនងាយរងគ្រោះពីក្រៅប្រទេស ដើម្បីបង្ខំឱ្យបម្រើសកម្មភាពឆបោកខុសច្បាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលភាគច្រើនប្រព្រឹត្តដោយ ជនបរទេសទៅលើជនបរទេសដូចគ្នាផង និងមានបណ្តាញទាក់ទងគ្នាយ៉ាងសកម្ម តាមប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានឬអនឡាញ ប្រទាក់ក្រឡាពីប្រទេសមួយទៅប្រទេសមួយផងដែរ ។ លោកជំទាវ ក៏បានមានប្រសាសន៍បន្ថែមថា នេះជាភាពប្រឈមថ្មីដែលរាជរដ្ឋាភិបាលកម្ពុជា មិនអាច ព្រងើយកន្តើយបានឡើយ ហើយត្រូវឆ្លើយតបជាបន្ទាន់ តាមវិធានការបោសសម្អាតបទល្មើសយ៉ាងមាន ប្រសិទ្ធភាព នោះគឺ «ផែនការប្រតិបត្តិការបង្កើន ការបង្ក្រាបអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើស ពាក់ព័ន្ធ» តាមសេចក្តីសម្រេចរបស់ គ.ជ.ប.ជ និងបង្កើតក្រុមការងារប្រតិបត្តិការ ដឹកនាំដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ និងបើកយុទ្ធនាការនៅទូទាំងប្រទេស រុករកបទល្មើស បណ្តាញជនល្មើស និង សង្គ្រោះជនរងគ្រោះ នៅតាមទីតាំងដែលមានការសង្ស័យយ៉ាងសកម្ម ៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្ដឹង ១ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ១នាក់

http://freshnewsasia.com/index.php/en/localnews/269597-2022-12-13-13-19-21.html 2022-12-13 08:19pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៦៤៩ករណី មានមនុស្ស ១,៥៨០នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៣៥១សំណើ និងបិទសំណុំរឿង ១៣៧សំណើ (រកឃើញមនុស្ស ៧៧២នាក់, ឃាត់ខ្លួនជនសង្ស័យ ៩៥នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ១៦១ករណី។

សូមបញ្ជាក់ថា សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្ដល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://www.gdlf-kh.com/2022/12/13/-61/ Vicheka ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅព្រឹកថ្ងៃអង្គារ ៥រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ីមេ បញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ចំនួន០៣នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី មុឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច ៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៥នាក់ ស្រី៦នាក់ ក្មេងស្រី១នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ និងធ្វើការពិនិត្យប័ណ្ណចាក់វ៉ាក់សាំងនៅនឹងប៉ុស្ដិ៍ជាលទ្ធផលត្រឹមត្រូវទាំងអស់ បន្ទាប់មកកម្លាំងយើងបានអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ២០២២

## សម្ដេច ស ខេង ប្រកាសឱ្យសមត្ថកិច្ចត្រូវចំចាប់មេខ្លោងជួញដូរមនុស្ស និងគ្រឿងញៀន ដើម្បីទាញកម្ពុជាចេញពីបញ្ជីប្រផេះ

https://kbn.news/archives/282982 December 14, 2022

ភ្នំពេញ៖ សម្ដេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជំរុញឲ្យសមត្ថកិច្ចតាមចាប់មេខ្លោងជួញដូរមនុស្ស និងគ្រឿងញៀន រួមទាំងស៊ើបអង្កេតបទល្មើសពាក់ព័ន្ធផ្សេងទៀត ជុំវិញការលាងលុយកខ្វក់ ដើម្បីទាញកម្ពុជាចេញពីបញ្ជីប្រផេះ។ នៅទិវាជាតិប្រឆាំងការជួញដូរមនុស្ស លើកទៅ១៦ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» សម្ដេច ស ខេង សង្កត់ធ្ងន់ថា ការបង្ក្រាបបទល្មើសមួយបានជោគជ័យ លុះត្រាតែរកេរកមុខមេខ្លោង ហើយចាប់ផ្តន្ទាទោសតាមច្បាប់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា កម្ពុជា មានពេលយ៉ាងយូរត្រឹមត្រីមាសទី១ ឆ្នាំ២០២៣ ដើម្បីខិតខំធ្វើយ៉ាងណា ឲ្យកម្ពុជាចេញពីបញ្ជីប្រផេះ របស់អង្គការឃ្លាំមើលការលាងលុយកខ្វក់អន្តរជាតិ «FATF» ដែលមានមូលដ្ឋាននៅប្រទេសបារាំង។

ចំពោះការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងគ្រឿងញៀន ជាពិសេសការសំអាតប្រាក់កខ្វក់ គឺជារឿងសំខាន់មួយរបស់កម្ពុជា ដើម្បីធ្វើរបាយកាណ៍ ទៅកាន់អង្គការឃ្លាំមើល FATE។ ក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស នាថ្ងៃទី១២ ធ្នូ សម្ដេច ស ខេង លើកឡើងបែបនេះ៖ «បញ្ហានេះ(បទល្មើសសំអាតប្រាក់) ជាបញ្ហាសំខាន់របស់កម្ពុជាយើងបច្ចុប្បន្នេះ។ ពេលនេះ រហូតដល់ត្រីមាសទីមួយឆ្នាំ២០២៣ អង្គការ FATF មានមូលដ្ឋាននៅបារាំង ទទួលស្គាល់លទ្ធផលរបាយការណ៍ពីការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំង ការសំអាតប្រាក់កម្ពុជា ដែលអង្គការនោះនឹងមកត្រួតពិនិត្យ ផ្ទៀតផ្ទាត់ របាយការណ៍កម្ពុជា ដែលបញ្ជូនទៅ តើវាពិតកម្រិតណា ដើម្បីដកកម្ពុជាចេញពីបញ្ជីប្រផេះ»។

សម្ដេច ស ខេង បានកត់សម្គាល់ឃើញការរាយការណ៍ពីបទល្មើសជួញដូរមនុស្ស និងការទទួលបានពាក្យបណ្ដឹង មានការថយចុះ បើធៀបនឹងមុនពេលសមត្ថកិច្ចផ្ដើមយុទ្ធនាការបង្ក្រាបការជួញដូរមនុស្ស នាថ្ងៃទី១៨ សីហាកន្លងមក។ មុនពេលចាប់ផ្តើមយុទ្ធនាការនេះ ក្នុងមួយថ្ងៃ សមត្ថកិច្ចទទួលជាងបានជាង១០បណ្ដឹង ប៉ុន្តែបច្ចុប្បន្ននេះ មានត្រឹមតែ១ ទៅ៣បណ្ដឹងប៉ុណ្ណោះ ក្នុងមួយថ្ងៃ។ បើគិតជាបណ្ដឹងសរុប ដែលសមត្ថកិច្ចទទួលបានជាង៦០០បណ្ដឹង។ ដូច្នេះ សម្ដេច ស ខេង សន្មតថា ករណីជួញដូរមនុស្សអាចនឹងធូរស្រាល។ យ៉ាងណាក្តី សម្ដេច ស ខេង ជំរុញឲ្យបន្តសហការគ្នាទប់ស្កាត់ទៀត។ បន្ថែមពីនេះសម្ដេច ស ខេង សង្កត់ធ្ងន់ថា ការបង្ក្រាបករណីជួញដូរមនុស្ស មិនមែនត្រឹមតែជួយសង្គ្រោះជនរងគ្រោះ ហើយបញ្ចប់សំណុំរឿងឡើយ ពោលគឺត្រូវតាមចាប់អ្នកប្រព្រឹត្តបទល្មើស ឬឧក្រិដ្ឋជន ទៅផ្តន្ទាទោស។ លើសពីនេះ ត្រូវស្រាវជ្រាវបទល្មើសបន្ថែម ទាក់ទងនឹងការលាងលុយកខ្វក់ រួមទាំងបទល្មើសគ្រឿងញៀនជាដើម៕

# ជនជាតិតៃប៉ិរហូតដល់៣០០នាក់
# ដែលជាប់ពាក់ព័ន្ធនឹងការងារឆបោកនៅតែបន្តជាប់នៅក្នុងប្រទេសកម្ពុជា

https://www.khmertimeskh.com/501202366// Khmer Times December 14, 2022

មន្ត្រីតៃប៉ិម្នាក់កាលពីថ្ងៃអង្គារបាននិយាយថានៅតែមានជនជាតិតៃប៉ិប្រហែល ៣០០ នាក់ដែលត្រូវបានគេជឿថាជាជនរងគ្រោះនៃការងារឆបោកនៅប្រទេសកម្ពុជាមិនទាន់បានវិលត្រឡប់មកប្រទេសវិញទេសូម្បីតែបន្ទាប់ពីការខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនខែរបស់រដ្ឋាភិបាលក្នុងការនាំយកពួកគេមកផ្ទះវិញក៏ដោយ។

Wallace Chow អគ្គនាយកនៃនាយកដ្ឋានកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៃក្រសួងការបរទេស បាននិយាយថា គិតត្រឹមថ្ងៃទី១២ ខែធ្នូ រដ្ឋាភិបាលតៃប៉ិបានជួយក្នុងការបញ្ជូនជនជាតិតៃប៉ិចំនួន៤០៣ នាក់មកប្រទេសវិញ ដែលភាគច្រើនត្រូវបានគេបោកបញ្ឆោតឲ្យមកកម្ពុជាដើម្បីធ្វើការងារដែលទទួលបានប្រាក់ខែខ្ពស់ ហើយបន្ទាប់មកត្រូវបានគេបង្ខំឱ្យធ្វើការខុសច្បាប់អោយក្រុមជនពាល។ លោក Chow បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានមួយថា ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានជនជាតិតៃប៉ិចំនួន២៩៦ នាក់កំពុងស្ថិតនៅក្នុងស្ថានភាពនោះ ដោយមិនទាន់បានត្រឡប់មកទីក្រុងតៃប៉ិវិញទេ។ នៅពេលសួរថាតើអ្វីដែលធ្វើឱ្យមានការលំបាកក្នុងការជួយជនជាតិតៃប៉ិជិតចំនួន៣០០ នាក់ឱ្យត្រឡប់មកវិញ លោក Chow បាននិយាយថា ថ្មីៗនេះនគរបាលសកម្ពុជាបានដឹងថាមានក្រុមជនពាលជាច្រើនបានចាកចេញពីប្រទេសកម្ពុជាទៅលាក់ខ្លួននៅប្រទេសមីយ៉ាន់ម៉ា ឬឡាវ បន្ទាប់ពីនគរបាលក្នុងតំបន់បានបើកការវាយឆ្មក់ជាបន្តបន្ទាប់ដើម្បីតាមចាប់ពួកគេ។

លោក Chow បានបន្តថា ដូច្នេះ ជនជាតិតៃប៉ិ ២៩៦ នាក់នេះ ជាច្រើននាក់ ក៏អាចត្រូវបែកខ្ញាត់ខ្ញាយ នៅតាមបណ្តាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងៗគ្នា ដែលធ្វើឱ្យរដ្ឋាភិបាលតៃប៉ិពិបាកស្វែងរកពួកគេ ដើម្បីជួយសង្គ្រោះ។ លោកក៏សង្ស័យថា ពួកគេខ្លះអាចជាសមាជិកនៃក្រុមជនពាល ឬអាចមានចេតនាផ្តាច់ទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ។ លោក Chow បានបន្ថែមថា៖ «យើងអាចសង្គ្រោះបានតែអ្នកដែលត្រូវការការសង្គ្រោះប៉ុណ្ណោះ។

ចំនួនជនជាតិតៃប៉ិសរុបដែលគេជឿថាជាប់ក្នុងប្រទេសកម្ពុជាកាលពីមុនមានចំនួន៦៩៩នាក់ នេះបើយោងតាមតួលេខផ្តល់ដោយទីភ្នាក់ងារនគរបាលជាតិ (NPA)។ តួលេខនោះគឺជាការប៉ាន់ស្មានដែលធ្វើឡើងដោយរដ្ឋាភិបាលក្រុងតៃប៉ិ បន្ទាប់ពី NPA បានចាប់ផ្តើមត្រួតពិនិត្យទូទាំងប្រទេសក្នុងខែសីហា ដើម្បីទៅសួរសុខទុក្ខសមាជិកគ្រួសារនៃប្រជាជាតិតៃប៉ិចំនួន ៤,០០០ ដែលគេដឹងថាកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា។ ក្នុងអំឡុងពេលចុះសួរសុខទុក្ខ សមាជិកគ្រួសារមួយចំនួនបានរាយការណ៍ប្រាប់នគរបាលថា សាច់ញាតិរបស់ពួកគេបានបាត់ខ្លួន ឬអាចជាជនរងគ្រោះនៃការងារក្លែងក្លាយ បន្ទាប់ពីពួកគេមានការពិបាកក្នុងការទាក់ទងសាច់ញាតិរបស់ពួកគេ។ ទន្ទឹមនឹងនោះមនុស្សមួយចំនួនក្នុងចំណោម៦៩៩នាក់បានទូរស័ព្ទទៅការិយាល័យនៅក្រៅប្រទេសរបស់តៃប៉ិដើម្បីសុំជំនួយ។ កិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះជនរងគ្រោះជនជាតិតៃប៉ិដែលជាប់នៅក្នុងប្រទេសកម្ពុជាត្រូវបានចាប់ផ្តើមបន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានលាតត្រដាងពីស្ថានភាពជនជាតិតៃប៉ិដែលបានធ្លាក់ចូលទៅក្នុងអន្ទាក់នៃការងារក្លែងក្លាយ។

ជាការឆ្លើយតប រដ្ឋាភិបាលក្រុងតៃប៉ិកាលពីថ្ងៃទី៨ ខែសីហា បានបង្កើតក្រុមការងារមួយ ដើម្បីដោះស្រាយបញ្ហា និងជួយនាំយកអ្នកដែលជាប់នៅទីនោះឲ្យមកផ្ទះវិញ។ ក្រុមការងារកំពុងធ្វើការដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីហានិភ័យទាក់ទងនឹងការងារ និងការធ្វើដំណើរទៅប្រទេសកម្ពុជា រួមទាំងតម្រូវអោយនគរបាលអាកាសយានដ្ឋានក្នុងទីក្រុងតៃប៉ិកាន់ស្លាកក្រើនរំលឹកអ្នកធ្វើដំណើរទៅកម្ពុជាអំពីការងារឆបោកនៅទីនោះ។

លោក Chow បាននិយាយថា ដោយសារតែកិច្ចខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនខែ ចំនួនមនុស្សដែលអះអាងថាជាជនរងគ្រោះដែលស្វែងរកជំនួយពីការិយាល័យនៅក្រៅប្រទេសរបស់តៃប៉ិនៅអាស៊ីអាគ្នេយ៍បាន

ធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ។ ទោះជាយ៉ាងនេះក្តី លោកបានរំលឹកថា ចំនួនជនរងគ្រោះអាចនឹងកើនឡើងម្តងទៀតក្នុងពេលឆាប់ៗនេះ បន្ទាប់ពីទីក្រុងតៃប៉ិ និងបណ្តាប្រទេសអាស៊ីអាគ្នេយ៍បានបន្ធូរបន្ថយវិធានការត្រួតពិនិត្យព្រំដែន ដែលបានដាក់ចេញដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ខណៈដែលមានជនជាតិតៃប៉ិកាន់តែច្រើនធ្វើដំណើរមកកម្ពុជា។ Focus Taiwan

## អន្តរជាតិសម្លឹងមើល កម្ពុជារឿងជួញដូរមនុស្ស និងលាងលុយកខ្វក់

https://kohsantepheapdaily.com.kh/article/1651154.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ១៤ ខែ ធ្នូ ឆ្នាំ ២០២២ ម៉ោង ១៣:៥៦

រាជធានីភ្នំពេញ៖«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ជាប្រធានបទនៃទិវាជាតិប្រឆាំងការជួញដូរមនុស្សលើកទៅ១៦។ ការជួញដូរមនុស្សហាក់ជាបញ្ហាធំ និងស្មុគស្មាញមួយដែលកំពុងធ្វើឱ្យសកលលោកសម្លឹងមកប្រទេសកម្ពុជា ត្បិតអីរឿងនេះពាក់ព័ន្ធនឹងករណីផ្សេងទៀតដូចការជួញដូរគ្រឿងញៀន និងការលាងលុយខ្មៅជាដើម។

ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ សម្តេច ស ខេង មានប្រសាសន៍ថា ការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងគ្រឿងញៀន ជាពិសេសការសំអាតប្រាក់កខ្វក់ គឺជារឿងសំខាន់មួយរបស់កម្ពុជា ដើម្បីធ្វើរបាយការណ៍ទៅកាន់អង្គការឃ្លាំមើលការលាងលុយដែលសរសេរកាត់ថា FATF ( Financial Action Task Force)។ ក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស នាថ្ងៃទី១២ ធ្នូ សម្តេច ស ខេង លើកឡើងបែបនេះ៖ «បញ្ហានេះ(បទល្មើសសំអាតប្រាក់) ជាបញ្ហាសំខាន់របស់កម្ពុជាយើងបច្ចុប្បន្នេះ។ពេលនេះ រហូតដល់ត្រីមាសទីមួយ ឆ្នាំ២០២៣ អង្គការ FATF មានមូលដ្ឋាននៅបារាំងទទួលស្គាល់លទ្ធផលរបាយការណ៍ពីការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងការសំអាតប្រាក់កម្ពុជាដែលអង្គការនោះនឹងមកត្រួតពិនិត្យផ្ទៀតផ្ទាត់របាយការណ៍កម្ពុជាដែលបញ្ជូនទៅ តើវាពិតកម្រិតណា ដើម្បីដកកម្ពុជាចេញពីបញ្ជីប្រផេះ»។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សហៅកាត់ថា គ.ជ.ប.ជ បានឱ្យដឹងថា ក្នុងឆមាសទី១ នៃឆ្នាំ២០២២ ស្ថានភាពនៃអំពើជួញដូរមនុស្សមានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។នៅពេលដែលស្ថានភាពទូទៅបានរៀបរយល្អប្រសើរហើយ ចំពោះសកម្មភាពបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេ.ទ បែរជាកើតមានបទល្មើសថ្មីលើទឹកដីកម្ពុជាដែលបង្កឡើងដោយឧក្រិ.ដ្ឋជនមួយចំនួនសម្ងំលាក់ខ្លួន ប្រព្រឹត្តបទល្មើសក្នុងអាជីវកម្មបន្លំភ្នែក ដោយប្រើប្រាស់ឱកាសដ៏ល្អដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងផ្តល់ឱ្យសម្រាប់ការវិនិយោគ ដើម្បីការអភិវឌ្ឍនៅក្នុងតំបន់ប៉ូលសេដ្ឋកិច្ចធំៗដូចជា ខេត្តព្រះសីហនុ រាជធានីភ្នំពេញជាដើម និងបណ្តាខេត្តមួយចំនួនទៀតទៅធ្វើសកម្មភាពឧក្រិ.ដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ គិតចាប់ពីថ្ងៃទី១៨ ខែសីហា មកដល់ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះសុំឱ្យធ្វើអន្តរាគមន៍ជួយសង្គ្រោះ គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន១១២២នាក់ ស្រី១២១នាក់ហើយ តែក្នុងចំណោមជនទាំងនោះអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំ.ងខ្លួន និងពលកម្មដោយបង្ខំ១៥៣នាក់ ស្រី១៨នាក់ មាន៦សញ្ជាតិ និងដោយអំពើចំណែកជនក្រៅពីនេះបានបដិសេធថា ខ្លួនមិនបានទទួលភាពរងគ្រោះទេ និង

មានបំណងចង់ប្តូរទៅទីតាំងការងារថ្មីដែលមានប្រាក់ខែខ្ពស់ជាងនេះ ឬថាគ្រាន់តែជាការបារម្ភរបស់ក្រុមគ្រួសារតែប៉ុណ្ណោះ។

សម្តេច ឧបនាយករដ្ឋមន្ត្រីបានកត់សម្គាល់ឃើញការរាយការណ៍ពីបទល្មើសជួញដូរមនុស្ស និងការទទួលបានពាក្យបណ្តឹងមានការថយចុះ បើធៀបនឹងមុនពេលសមត្ថកិច្ចផ្តើមយុទ្ធនាការបង្រ្កាបការជួញដូរមនុស្ស នាថ្ងៃទី១៨ សីហាកន្លងមក។មុនពេលចាប់ផ្តើមយុទ្ធនាការនេះ ក្នុងមួយថ្ងៃសមត្ថកិច្ចទទួលជាងបានជាង១០បណ្តឹង ប៉ុន្តែបច្ចុប្បន្ននេះមានត្រឹមតែ១ទៅ៣បណ្តឹងប៉ុណ្ណោះក្នុងមួយថ្ងៃ។បើគិតជា បណ្តឹងសរុបដែលសមត្ថកិច្ចទទួលបានជាង៦០០បណ្តឹង។ ដូច្នេះសម្តេច ស ខេង សន្និដ្ឋានថា ករណីជួញដូរមនុស្សអាចនឹងធូរស្រាល។ យ៉ាងណាក្តីសម្តេច ស ខេង ជំរុញឲ្យបន្ត សហការគ្នាទប់ស្កាត់ទៀត។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានសង្កត់ធ្ងន់ថា ការបង្រ្កាបករណីជួញដូរមនុស្សមិនមែនត្រឹមតែជួយសង្គ្រោះជនរងគ្រោះ ហើយបញ្ចប់សំណុំរឿងឡើយ ពោល គឺត្រូវតាមចាប់អ្នកប្រព្រឹត្តបទល្មើស ឬឧក្រិ.ដ្ឋជនទៅផ្តន្ទាទោស។លើសពីនេះត្រូវស្រាវជ្រាវបទល្មើសបន្ថែមទាក់ទងនឹងការលាងលុយកខ្វក់រួមទាំងបទល្មើសគ្រឿងញៀ.នជាដើម។ តាមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃការបង្ក្រាបការជួញដូរមនុស្ស និងគ្រឿងញៀ.ននឹងជុំវិញឱ្យកម្ពុជាចេញពីបញ្ជីប្រផេះនៃបញ្ហាលាងលុយប្រាក់កខ្វក់នោះដែរ៕ដោយសារ៉ាន់

## តើការបៀតបៀនផ្លូវភេទ តាមអនឡាញមានរូបភាពបែបណាខ្លះ? ហើយត្រូវដោះស្រាយដូចម្តេច?

https://www.kampucheathmey.com/kpt-plus/430905 ថ្ងៃពុធ ១៤ ធ្នូ ២០២២ដោយ អ៊ុន ស្រីមាន

បច្ចុប្បន្ន ជាសម័យឌីជីថល ដែលមានភាពទូលំទូលាយចំពោះការផ្សព្វផ្សាយនៅលើបណ្តាញសង្គមផ្សេងៗ ហើយក៏មានអ្នកប្រើប្រាស់ច្រើនផងដែរ។ ទន្ទឹមនេះ ក៏មានជនខិលខូចមួយចំនួន ឆក់ឱកាសនេះ បានយកប្រព័ន្ធអនឡាញជាកន្លែងជួញដូរ ឬ បៀតបៀនផ្លូវភេទ អាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះជាច្រើន មិនថាជាមនុស្សប្រុស ជាមនុស្សស្រី ឬ ជាកុមារឡើយ។ តើការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញមានរូបភាពបែបណាខ្លះ? ប្រសិនជាជួបនូវបញ្ហានេះ តើជនរងគ្រោះត្រូវដោះស្រាយដោយរបៀបណា?

របាយការណ៍របស់អង្គការ Childnet ដែលធ្វើកិច្ចការពារដល់កុមារ និងយុវជន ពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ បានឱ្យនិយមន័យការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញថា គឺជាទង្វើដែលមិនចង់បាន ហើយមិនស្វាគមន៍ នៅលើប្រព័ន្ធឌីជីថលណាមួយ ហើយត្រូវបានទទួលស្គាល់ថាជាទម្រង់នៃអំពើហិង្សាផ្លូវភេទ។ អង្គការ Childnet ក៏បានបង្ហាញពីអាកប្បកិរិយាដែលមាននៅលើប្រព័ន្ធអនឡាញអាចកើតឡើងគ្រប់ទីកន្លែងដូចជា ប្រព័ន្ធផ្សព្វផ្សាយសង្គមគ្រប់ប្រភេទ ហ្គេម ប្រអប់សារសាធារណៈ ជាក្រុម ឬ ឯកជន។ ការបៀតបៀន អាចមានជារូបភាព ឬ វីដេអូអាសអាភាស ការបង្ហោះសារ ឬ ធ្វើជារូបតុក្កតបែបកំប្លែង ប៉ុន្តែ សំដៅទៅដល់អត្ថន័យអាសអាភាសជាដើម។ ចំណែកអង្គការGADCដែលធ្វើការទៅលើស្ត្រីនិងក្មេងស្រីបានបង្ហាញពីប្រភេទនៃការបៀតបៀនផ្លូវភេទមាន០៤ គឺ៖

**១.ការចែករំលែករូបភាព ឬ វីដេអូ**

ការចែកចាយរូបភាព ឬ វីដេអូផ្លូវភេទ ដែលមិនសុំការអនុញ្ញាតពីសាមីខ្លួន ព្រមទាំង ការលួចថតរូប ឬ វីដេអូនៅទីសាធារណៈដោយគ្មានការអនុញ្ញាត ដូចជាផ្នែកខាងក្រោយ ឬ ភ្លៅ ហើយយកទៅចែកចាយបន្ត។ កត្តាមួយទៀត គឺការថតរូបភាព ឬ វីដេអូអាសអាភាសដោយការព្រមព្រៀង ប៉ុន្តែ ភាគីម្ខាងទៀតបានយកទៅបង្ហោះជាសាធារណៈ ក៏ចាត់ទុកជាការកេងប្រវ័ញ្ចផ្លូវភេទផងដែរ។

**២.ការកេងប្រវ័ញ្ច លួងលោម និងបំភ័យ**

ក្នុងករណីនេះ គឺអាចកើតចេញពីការលួងលោមឱ្យភាគីម្ខាងបង្ហាញពី និងដោះដូររូបភាពអាក្រាតកាយ ដើម្បីបង្ហាញជាសេចក្តីស្រឡាញ់ៗល។ ក្រោយមកក៏គំរាមទារប្រាក់ មិនដូច្នេះទេ នឹងបង្ហោះរូបភាពនោះជាសាធារណៈ។

**៣.ការសម្លុតបែបផ្លូវភេទ**

នៅចំណុចនេះ គឺការយកពីចំណុចខ្សោយរបស់នរណាម្នាក់ ឬ ត្រូវបានសម្លុតដោយការបើកបង្ហាញពីអត្តសញ្ញាណយេនឌ័រដោយគ្មានការយល់ព្រមពីសាមីខ្លួន។ ការនិយាយដើម ឬ ការរិះគន់ពីរូបរាងកាយ ព្រមទាំងប្រើពាក្យពេចន៍ទាក់ទងទៅនឹងផ្លូវភេទ ដែលមានការរើសអើង និងប្រមាថនៅលើបណ្តាញសង្គម ក៏ចាត់ចូលក្នុងរូបភាពបៀតបៀនផ្លូវភេទតាមអនឡាញដែរ។

**៤.មាតិកាផ្លូវភេទ**

ចំពោះមាតិកាផ្លូវភេទ គឺកើតចេញដោយការមិនទទួលស្វាគមន៍រាល់ការបញ្ចេញមតិយោបល់ផ្លូវភេទទាំងនោះនៅលើបណ្តាញសង្គម។ រូបភាពមាតិកាផ្លូវភេទ មានដូចជា ការបញ្ចេញមតិយោបល់បែបផ្លូវភេទទៅលើរូបភាពដែលគេបានបង្ហោះ។ ផ្ញើជារូបភាព សារ emoji អាសអាភាស ឬ និយាយពីផ្លូវភេទដែលមិនត្រូវបានស្វាគមន៍ ឬ យករូបជនរងគ្រោះ ទៅកាត់ត ឬ កែរូបភាព ដើម្បីទាក់ទាញអារម្មណ៍ផ្លូវភេទជាដើម។ ទាំងអស់នេះ សុទ្ធតែជាការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ ដែលអ្នកប្រើប្រាស់ឌីជីថលគួរប្រុងប្រយ័ត្ន។ ប្រសិនជាជនរងគ្រោះណាម្នាក់ បានជួបប្រទះហេតុការណ៍ទាំងនេះ អាចរាយការណ៍ទៅកាន់អង្គការនានាដែលធ្វើការទៅលើស្ត្រី ឬ កុមារ ដើម្បីឱ្យពួកគេជួយអន្តរាគមន៍។ លោកអ្នកក៏អាចទាក់ទងទៅកាន់អង្គការក្លែន ក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី និងអង្គការពាក់ព័ន្ធផ្សេងៗទៀត៕ ដោយៈ អុន ស្រីមាន

## មន្ត្រីសិក្ខាមមកពីអធិការដ្ឋាននគរបាលខណ្ឌទាំង ១៤ សរុប៨៤នាក់ ទទួលបានវគ្គបណ្តុះបណ្តាលបំប៉នជំនាញស្តីពីកិច្ចការងារការពារកុមារ

https://www.information.gov.kh/articles/93743 ចេញផ្សាយ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២២

ភ្នំពេញៈ មន្ត្រីសិក្ខាកាមមកពីអធិការដ្ឋាននគរបាលខណ្ឌទាំង១៤ សរុប ៨៤នាក់ ទទួលបានការបណ្តុះបណ្តាលវគ្គបំប៉នជំនាញស្តីពីកិច្ចការងារការពារកុមារ ដើម្បីបង្ការទប់ស្កាត់នូវរាល់អំពើហិង្សាលើកុមារគ្រប់ប្រភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានលើកុមារ នៅគ្រាដែលគេមើលឃើញថាការបំពាន និងការប្រព្រឹត្តបទល្មើសខុសច្បាប់ទៅលើកុមារពីសំណាក់ជនទុច្ចរិតត្រូវបានកើតឡើងជារឿយនៅក្នុងប្រទេសកម្ពុជា។

ពិធីបើកវគ្គបណ្តុះបណ្តាលធ្វើឡើង នាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្រោមវត្តមាន លោកឧត្តមសេនីយ៍ទោ គឹម សុធី អនុប្រធាននាយកដ្ឋានកិច្ចការងារប៉ុស្តិ៍នគរបាលរដ្ឋបាល និងលោកឧត្តមសេនីយ៍ត្រី ស៊ុម សុឃីម ស្នងការរងតំណាង ឯកឧត្តមឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ។

លោកឧត្តមសេនីយ៍ទោ គឹម សុធី អនុប្រធាននាយកដ្ឋានកិច្ចការងារប៉ុស្តិ៍នគរបាលរដ្ឋបាល លើកឡើងថា វគ្គបណ្តុះបណ្តាលនេះមានសារៈសំខាន់ណាស់សម្រាប់សិក្ខាកាមនគរបាលអនុវត្តច្បាប់ក្នុងការពង្រឹងសមត្ថភាព មានវិជ្ជាជីវៈច្បាស់លាស់ និងមានការយល់ដឹងពីផ្នែកច្បាប់បានទូលំទូលាយក្នុងការកំណត់អត្តសញ្ញាណ និងការផ្តល់សេវាដល់កុមារគ្រប់រូបពិសេសកុមារដែលប្រឈមការប្រើអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពាន ពីព្រោះថាការបំពេញភារកិច្ចរបស់អស់លោកលោកស្រីនាពេលបច្ចុប្បន្នគឺមានបទ ពិសោធន៍មិនទាន់គ្រប់គ្រាន់នៅឡើយនោះទេលើការងារកិច្ចការងារការពារកុមារ ដោយសារតែស្ថានភាពនៃភាពរីកចម្រើនហេតុការណ៍បទល្មើសកើត

ឡើងវិវឌ្ឍថ្មីៗរហូតគ្រប់ស្ថានភាពដូច្នេះទាមទារមន្ត្រីនគរបាលត្រូវតែរៀន សូត្រនិងទទួលយកចំណេះដឹងឱ្យបានច្រើនមានសមត្ថភាពខ្ពស់ក្នុងការកិច្ចការងារទប់ស្កាត់រាល់ការព្រឹត្តអំពើខុសច្បាប់ទៅលើកុមារ។

លោកឧត្តមសេនីយ៍ត្រី ស៊ុម សុឃីម ស្នងការរង បានលើកឡើងថា កិច្ចការងារការពារកុមារនេះស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ក្រោមការដឹកនាំបញ្ជាផ្ទាល់ពីសំណាក់ ឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ តែងបានដាក់ចេញនូវបទបញ្ជានិងផែនការនានាក្នុងការយកចិត្តទុកដាក់លើកិច្ចការពារបង្ការទប់ស្កាត់រាល់អំពើហិង្សាលើកុមារគ្រប់ប្រភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានលើកុមារ ពីព្រោះថាកុមារជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ ហើយកន្លងមកជនល្មើសដែលបានប្រព្រឹត្តបទល្មើសគ្រប់ទំរង់ទៅលើកុមារតែងត្រូវបានចាប់ឃាត់ខ្លួនយកទៅអនុវត្តច្បាប់ ដោយមិនលើកលែងនោះទេ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលបំប៉នជំនាញស្តីពីកិច្ចការងារការពារកុមារ គឺដំណើរការរៀនសូត្ររយៈពេល៣ថ្ងៃ សិក្ខាកាមជាអធិការរង នាយផ្នែក នៅតាមបណ្តាអធិការដ្ឋាននគរបាលខណ្ឌទាំង១៤ដែលទទួលការងារព្រហ្មទណ្ឌ ការងារកិច្ចការប៉ុស្តិ៍រដ្ឋបាល និង គ្រឿងញៀនមកទទួលយកការបណ្តុះបណ្តាលនេះ៕ ប្រភពៈ ទទក សម្រួលផ្សាយដោយៈ ធូ កុសល

## ប៉ូលីសអន្តរជាតិចាប់ឃាត់ខ្លួនឈ្មួញជួញដូរមនុស្ស ២៧០នាក់

https://www.rfi.fr/km//20221214-ref=tgi ចុះផ្សាយនៅថ្ងៃ៖ 14/12/2022 - 16:16ដោយ៖ហេង ឧត្តម

ប៉ូលីសអន្តរជាតិ បានចាប់ឃាត់ខ្លួនឈ្មួញជួញដូរមនុស្ស ប្រមាណ ២៧០នាក់ នៅតំបន់អាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីប។ ពួកជនល្មើសទាំងនោះ បានជួញដូរមនុស្សនិងជនភៀសខ្លួនខុសច្បាប់ ជាង ៩ ពាន់នាក់។ នេះជាការបញ្ជាក់របស់នគរបាលអាំងទែរប៉ូល មូលដ្ឋាននៅទីក្រុងលីយ៉ុង ប្រទេសបារាំង នៅថ្ងៃពុធ ទី១៤ធ្នូ គឺក្រោយពីបានចេញប្រតិបត្តិការពិសេស ចំនួន៥ថ្ងៃ។ ប៉ូលីសអន្តរជាតិ អាំងទែរប៉ូល បានបើកប្រតិបត្តិការពិសេស នៅក្នុងប្រទេសចំនួន ៣៥ ដែលចុះសកម្មភាពនៅតាមតំបន់សំខាន់ៗ គឺតាមផ្លូវទឹកនាវាចរណ៍ នៅអាកាសយានដ្ឋាន ស្ថានីយរថភ្លើង និង ច្រព្រំដែន។ តុល្យការបឋម ផ្សាយនៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់នគរបាលអាំងទែរប៉ូល គឺជនល្មើសច្បាប់ ចំនួន ២៦៨ នាក់ ត្រូវចាប់ខ្លួន និងបញ្ជូលក្នុងពន្ធនាគារ ដោយត្រូវជាប់ចោទពីបទល្មើសជួញដូរមនុស្ស ជួញជនអន្តោប្រវេសន៍ខុសច្បាប់ ហើយនិងបទល្មើសក្លែងបន្លំឯកសារ ព្រមទាំងអំពើល្មើសសេពសន្ធវៈ ជាដើម។

ករណីបង្ក្រាបបណ្តាញជួញដូរនេះ ប៉ូលីសអន្តរជាតិ បានរកឃើញជនរងគ្រោះ ជាសរុប ប្រមាណ ជាង ៩ ពាន់នាក់ ភាគច្រើនសុទ្ធសឹងជាជនភៀសខ្លួនខុសច្បាប់ និងគ្មានទីកន្លែងចតពិតប្រាកដ។ ជនភៀសខ្លួនខុសច្បាប់ ភាគច្រើនមកពីតំបន់អាមេរិកឡាទីន និងតំបន់ការ៉ាអ៊ីប ហើយមានទិសដៅចង់ទៅ តំបន់អាមេរិកខាងជើង។ ករណីនេះ គឺចេញតាមច្រកប្រទេសម៉ិចស៊ិក ចំនួន ២ ៤០០នាក់ ដែលមកពីប្រទេសដើម គឺ វេណេស៊ុយអេឡា និងគុយបា។ បើមកពីទ្វីបអាហ្វ្រិក គឺភាគច្រើនចេញពីប្រទេស អង់ហ្គូឡា ប៊ូគីណាហ្វាសូ ហ្គីណេ និង អេត្យូពី។ ចំណែកតំបន់អាស៊ី គឺមានចេញពី នេប៉ាល់ និងបង់ក្លាដែស ជាដើម។ នៅប្រទេស នីហ្គារ៉ាហ្គ័រ ប៉ូលីសពិសេសអន្តរជាតិ រកឃើញជនភៀសខ្លួនខុសច្បាប់ ជាង ២ពាន់នាក់ ដែលចេញពីអាស៊ីកណ្តាល មានកោះហៃទី និង អេក្វាទ័រ ដែលមានចិត្តចង់ទៅបន្តជីវិត នៅសហរដ្ឋអាមេរិក និងកាណាដា។ នៅហុងឌុយរ៉ាស មានករណីជួញដូរក្មេងស្រី តាមរយៈបង្ខំឲ្យរកស៊ីបម្រើផ្លូវភេទ។ នៅសាវ៉ាដ័រ ម្តាយមួយចំនួន លក់កូនស្រីឲ្យបម្រើផ្លូវភេទ ហើយក្នុងនោះ ក៏មានដែរ ក្មេងស្រីពិការ ដែលត្រូវបង្ខំឲ្យលក់ខ្លួន។

ប៉ូលីស អាំងទែរប៉ូល ឲ្យឈ្មោះប្រតិបត្តិការពិសេស លើកនេះថា Turquesa IV ដែលធ្វើសកម្មភាពសកម្ម ជាប់ៗគ្នា ចំនួន៥ថ្ងៃ ចាប់ពីថ្ងៃទី ២៨វិច្ឆិកា ដល់ ២ ធ្នូ ដោយមានជំនួយគាំទ្រហិរញ្ញវត្ថុពីក្រសួងការបរទេសកាណាដា។ ប្រតិបត្តិការកម្ចាត់ខ្សែជួញដូរមនុស្សនេះ បានធ្វើដែរ នៅប្រទេសក្វាតេម៉ាឡា ប៊ូលីវី ប៉េរូ ប៉ារ៉ាហ្គាយ និងប្រេស៊ីល។ អគ្គលេខាធិការប៉ូលីសអន្តរជាតិ Jürgen Stock មានប្រសាសន៍បញ្ជាក់ថា ការជួយដូរមនុស្ស និងជួញដូរជនអន្តោប្រវេសន៍ខុសច្បាប់ គឺជាឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងរកបានលុយខុសច្បាប់រាប់ពាន់លានដុល្លារ។ ជនល្មើសយកលុយខុសច្បាប់ទាំងនោះ ទៅបំប៉នឧក្រិដ្ឋកម្មធំៗផ្សេងទៀត ដ៏គ្រោះថ្នាក់ និងដែលបំពាន់លើគោលការណ៍សិទ្ធជាមនុស្សជ្ជានរបស់មនុស្ស៕

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេស ៤នាក់

https://freshnewsasia.com/index.php/en/localnews/269900-2022-12-15-08-09-30.html 2022-12-15 03:09pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនបរទេសចំនួន ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៥៣ករណី មានមនុស្ស ១,៥៨៥នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម រកឃើញ ៤១១សំណើ និងបិទសំណុំរឿង ២០៩សំណើ (រកឃើញមនុស្ស ៩៣៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១០៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៣ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្តាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្តេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## នគរបាលការពារព្រំដែនគោកលេខ៨១៥
## ទប់ស្កាត់ពលករ ចំនួន ២២នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ

http://nokorwatnews.com/archives/941974 15/12/2022

ខេត្តបន្ទាយមានជ័យ ៖ ពលករប្រុសស្រី២២នាក់ចាញ់បោកមេខ្យល់នាំឆ្លងដែនខុសច្បាប់នៅល្ងាចថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២នេះត្រូវកម្លាំងការពារព្រំដែនគោក៨១៥ទប់ស្កាត់ដើម្បីធ្វើការអប់រំ។ នគរបាលម្នាក់បញ្ជាក់ថាៈ ដោយអនុវត្តន៍ តាមបទបញ្ជា លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ កម្លាំងប៉ុស្ដិ៍ចំបក់ចំនួន០៤នាក់ ដឹកនាំដោយលោកវរសេនីយ៍ទោ មាស ម៉េងហួង មេបញ្ជាការរង នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ ទទួលទិសប៉ុស្ដិ៍ចំបក់ សហការជាមួយកម្លាំងប៉ុស្ដិ៍រដ្ឋបាលឃុំបឹងបេង បានទប់ស្កាត់ប្រជាពលរដ្ឋ ចំនួន ២២នាក់ (ស្រី០៩នាក់ កុមារ០៥នាក់) បម្រុងលួចឆ្លងដែនទៅប្រទេសថៃ ដោយខុសច្បាប់ នៅចំណុចផ្ទះដែលម្ចាស់ទុកចោល (ម្ចាស់ធ្វើចំណាកស្រុក) មួយកន្លែងក្នុងភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ពួកគាត់មានទីលំនៅក្នុងខេត្តចំនួន ០៤គឺ ៖

១.បន្ទាយមានជ័យ ១៣នាក់

២.ឧត្តរមានជ័យ ០១នាក់

៣.បាត់ដំបង ០៤នាក់

៤.កំពង់ធំ ០៤នាក់

លោកវរសេនីយ៍ទោ មាស ម៉េងហួង មេបញ្ជាការរង បានឱ្យដឹងថាៈ បានសួរនាំ ប្រជាពលរដ្ឋចំនួន ២២នាក់ បម្រុងលួចឆ្លងដែននោះ ពួកគាត់បានជិះរថយន្តឈ្នួលមកចុះនៅចំណុចផ្លូវចូលប៉ុស្ដិ៍ចំបក់ រួចធ្វើដំណើរទៅឈប់សម្រាកក្នុងផ្ទះមួយកន្លែង (ដែលម្ចាស់ទុកចោល) ចម្ងាយ ប្រហែល ១០០ម៉ែត្រ ពីផ្លូវជាតិ បំណងឆ្លងទៅប្រទេសថៃ (ស៊ីឈ្នួលកាប់អំពៅ) ។ លោកវរសេនីយ៍ទោ មាស ម៉េងហួង មេបញ្ជាការរង បានឱ្យដឹងទៀតថាៈ បន្ទាប់ពីធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច បានប្រគល់ពួកគាត់ជូនទៅផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីធ្វើការអប់រំមិនឲ្យឆ្លងដែនខុសច្បាប់រួចធ្វើកិច្ចសន្យាឱ្យវិលត្រឡប់ទៅស្រុកកំណើតវិញ ៕

## អាជ្ញាធរខេត្តសៀមរាប ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ លើកទី១៦ ក្រោមប្រធានបទ "រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព" !

https://www.information.gov.kh/articles/93831 ចេញផ្សាយ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២២

សៀមរាបៈ លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សហៅកាត់ថា គ.ខ.ប.ជ បានមានប្រសាសន៍ថា ទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស១២ធ្នូ តែងតែត្រូវបានប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីជាការបំផុសការយល់ដឹងអំពីព្រឹត្តការណ៍ និងស្ថានភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដែលបាននឹងកំពុងកើតមាននៅក្នុងពិភពលោក និងនៅក្នុងប្រទេសកម្ពុជា ហើយក៏ជាការដាស់តឿនក្រើនរំលឹកអំពីភាពងាយរងគ្រោះ និងល្បិចកលថ្មីៗនៃជនល្មើស ព្រមទាំងបង្ហាញអំពីការប្ដេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូពាក់ព័ន្ធជាតិ-អន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព និងគ្រប់ទម្រង់។

មានប្រសាសន៍នៅក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ខួបលើកទី១៦ នាពេលព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២នេះ លោកស្រី យូ សុភា បានថ្លែងគាំទ្ររាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ ដែលនៅតែបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ក្នុងការការពារប្រជាពលរដ្ឋ និងប្រទេសជាតិពីភាពរងគ្រោះទាំងឡាយ ដោយអំពើឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបង្កឱ្យមានវិនាសកម្ម ដល់មនុស្សជាតិ ហើយបាន និងកំពុងក្លាយជាទាសភាពសម័យទំនើប គួរឱ្យភ័យខ្លាចនិងស្អប់ខ្ពើមបំផុត។ លោកស្រីបន្តថា ការងារអនុវត្តច្បាប់មអាជ្ញាធរខេត្តសៀមរាប ក្នុងឆ្នាំ២០២២នេះ បានធ្វើការស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាបបានបទល្មើសពាក់ព័ន្ធ នឹងការជួញដូរមនុស្សបានចំនួន ០៨ករណី (ថយចុះ៦ករណីបៀបនឹងឆ្នាំ២០២១ មាន ១៤ករណី) រួមមាន សញ្ចារកម្ម, អំពើជួញដូរមនុស្ស១ករណី (ការនាំយកចេញដោយមិនស្របច្បាប់), រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ, ប្រទូស្តកេរខ្មាស់, អំពើហិង្សាក្នុងគ្រួសារ និងករណីសំអាតប្រាក់ ដោយបានធ្វើការឃាត់ខ្លួនជនសង្ស័យ និងបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ក្នុងនោះអាជ្ញាធរខេត្ត ប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព មិនអនុញ្ញាតឱ្យជនល្មើសមានឱកាសធ្វើសកម្មភាពលើទឹកដីនៃខេត្តសៀមរាបបានឡើយ។ បន្ថែមពីនោះរដ្ឋបាលខេត្តនឹងធ្វើការជំរុញបន្ថែមទៅដល់មន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការពង្រឹកយន្តការ ការគ្រោងកញ្ចប់ថវិកាសេវាសង្គម បង្កើនការផ្សព្វផ្សាយ ការបង្ការទប់ស្កាត់ ស្រាវជ្រាវ បង្ក្រាបបទល្មើស សង្គ្រោះជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើសជួញដូរមនុស្សឱ្យខានតែបាន។

ក្នុងឱកាសនោះដែរ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ថា អំពើជួញដូរមនុស្ស គឺជាវិបត្តិសកលមួយដែលបណ្តាប្រទេសជាច្រើនលើសកលលោកបានជួបប្រទះ ហើយក្នុងនោះប្រទេសកម្ពុជារបស់យើង ក៏បានទទួលរងនូវវិបត្តិនេះផងដែរ ដែលធ្វើឱ្យរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភជាខ្លាំង។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តរៀបចំ និងកែសម្រួលទៅលើយន្តការគាំទ្រជាបន្តបន្ទាប់ ដើម្បីជាការឆ្លើយតប ទៅនឹងការវិវត្តនៃកលល្បិចរបស់ឧក្រិដ្ឋជន ដែលយន្តការជាតិនោះមានលក្ខណៈទូលំទូលាយ ព្រមទាំងបានដាក់ចុះនូវផែនការយុទ្ធសាស្ត្រជាតិ ដោយបានផ្តោតសំខាន់លើការបង្ការទប់ស្កាត់ បង្ក្រាប កិច្ចការពារជនរងគ្រោះ យុត្តិធម៌ព្រហ្មទណ្ឌ (ការផ្តន្ទាទោស) និងកិច្ចសហប្រតិបត្តិការជាដើម។

លោកជំទាវ បន្តថា កម្ពុជា នៅតែបន្តប្តេជ្ញាខ្ពស់ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសអំពើជួញដូរមនុស្ស ដើម្បីការពារផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ប្រកបដោយសេចក្តីសុខសុវត្ថិភាព និងបន្តអនុវត្តរាល់បទដ្ឋាន ដែលជាប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធ និងកិច្ចការពាសុវត្ថិភាពមនុស្សជាតិទាំងមូល។ ជាមួយពីនោះ អង្គពិធីក៏មានហែរក្បួនព្យុះហយាត្រា នៅក្នុងក្រុងសៀមរាប ដើម្បីបង្ហាញដល់សាធារណជនឱ្យយកចិត្តទុកដាក់ចូលរួមការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សផងដែរ៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

# ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០២២

## សម្តេចក្រឡាហោម ស ខេង ជំរុញឲ្យគណៈកម្មអន្តរក្រសួងប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ

https://cen.com.kh/archives/590564.html Posted ByPen Srey NeatDecember 16, 2022

ភ្នំពេញ៖ នាព្រឹកថ្ងៃសុក្រ ទី១៦ ខែធ្នូ ឆ្នាំ២០២២ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូសន្និសីទ ពីសំណាក់ ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត។

ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស បានអាននូវសេចក្តីសម្រេចរាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេសដែលដឹកនាំដោយ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អមដោយអនុប្រធាន៦រូប និងសមាជិក១៤រូប។

ឯកឧត្តម បានបន្តថា គណៈកម្មការអន្តរក្រសួងនេះ បង្កើតឡើងក្នុងគោលបំណងដើម្បីដឹកនាំពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងដើម្បីជំរុញការងារអធិការកិច្ចហត្ថពលកម្មបរទេស និងផ្សព្វផ្សាយគោលការណ៍វិធានការពាក់ព័ន្ធនៅតាមសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកម្សាន្តនានា។ ឯកឧត្តមបន្ថែមថា គណៈកម្មអន្តរក្រសួងនេះ ក៏មានគោលដៅគាំទ្រដល់ផែនការប្រតិបត្តិការបង្កើនការងារប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម បានបញ្ជាក់ទៀតថា ប្រធាន អនុប្រធាន និងសមាជិក នៃគណៈកម្មការនេះ មានសិទ្ធិចាត់ចែងប្រើប្រាស់មន្ត្រីក្រោមឱវាទឱ្យចូលរួមបំពេញការងារតាមការចាំបាច់។

នាឱកាសនោះដែរ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងជំរុញ និងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស បានថ្លែងប្តេជ្ញាចិត្តបំពេញការងារធ្វើអធិការកិច្ចហត្ថពលកម្មបរទេសឱ្យមានប្រសិទ្ធិខ្ពស់។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមក្រសួងមហាផ្ទៃ បានសម្តែងការកោតសរសើរចំពោះថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អាជ្ញាធរ កម្លាំងមានសមត្ថកិច្ចនានា និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត បានខិតខំប្រឹងប្រែងចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសនាពេលកន្លងមក សំដៅពង្រឹងការអនុវត្តច្បាប់ការងារ នៅកម្ពុជា។ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី បានណែនាំអំពីរបៀបរបបធ្វើការងារ ក្នុងពេលបំពេញបេសកម្មការងារនេះ ក្នុងនោះសម្តេចក៏បានណែនាំដល់គណៈកម្មការអន្តរក្រសួង ត្រូវជំរុញ និងត្រួតពិនិត្យការងារធ្វើអធិការកិច្ចហត្ថពលកម្មបរទេស គណៈបញ្ជាការដឹកនាំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារបង្ក្រាបល្បែងស៊ីសង់ខុសច្បាប់ត្រូវធ្វើយ៉ាងណាបំពេញការងារឱ្យមានប្រសិទ្ធិភាព៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

## ឃាត់ប្រជាពលរដ្ឋខ្មែរ១៧នាក់ ព្យាយាមលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ

https://kohsantepheapdaily.com.kh/article/1652240.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ១៥ ខែ ធ្នូ ឆ្នាំ ២០២២ ម៉ោង ២០:៣៨

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលវរការពារព្រំដែនគោក៨១៥ និងនគរបាលប៉ុស្តិ៍រដ្ឋបាលបឹងបេង បានឃាត់ប្រជាពលរដ្ឋខ្មែរចំនួន១៧នាក់ និងកុមារ០៥នាក់ នាំយកមកអប់រំ ខណៈពួកគេព្យាយាមលួចឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ កាលពីវេលាម៉ោង០៥និង១៥នាទីល្ងាច ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ។ កម្លាំងប៉ុស្តិ៍ចំបក់ ដឹកនាំដោយលោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរនគរបាលការពារព្រំដែនគោកលេខ៨១៥ បានចាត់តាំង លោកវរសេនីយ៍ទោ មាស ម៉េងហួង មេបញ្ជាការរងទទួលទិសប៉ុស្តិ៍ចំបក់ និងលោកវរសេនីយ៍ត្រី ប៊ុន គុណ នាយប៉ុស្តិ៍ចំបក់ បានសហការជាមួយកម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំបឹងបេង បានទប់ស្កាត់ប្រជាពលរដ្ឋចំនួន១៧នាក់ (ស្រី០៩នាក់) បម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ នៅចំណុចផ្ទះ ដែលម្ចាស់ទុកចោល មួយកន្លែងក្នុងភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ បានអោជឹងថា ពលរដ្ឋខ្មែរទាំងនេះ ត្រូវបានស្ទាក់ឃាត់យកមកសួរនាំ និងអប់រំ ខណៈពួកគាត់ត្រូវបានមេខ្យល់ យកមកបោះបង់ចោលនៅក្បែរព្រំដែន និងពួកគាត់បានព្យាយាមឆ្លងដែនចូលទឹកដីថៃដោយខុសច្បាប់ ។ ប្រជាពលរដ្ឋទាំងនោះមកពីខេត្តចំនួន០៤ គឺ ៖ ១-បន្ទាយមានជ័យ ២-ឧត្តរមានជ័យ ៣-ខេត្តបាត់ដំបង និង៤-ខេត្តកំពង់ធំ ។ លោកមេបញ្ជាការបានបញ្ជាក់ថា ឆ្លងតាមការសួរនាំ ពួកគាត់ជិះរថយន្តឈ្នួល មកចុះនៅចំណុចផ្លូវចូលច្រកបឹងបេង រួចធ្វើដំណើរទៅឈប់សម្រាកក្នុងផ្ទះមួយកន្លែង (ដែលម្ចាស់ទុកចោល) ចម្ងាយប្រហែល១០០ម៉ែត្រ ពីផ្លូវជាតិ បំណងឆ្លងទៅប្រទេសថៃ (ស៊ីឈ្នួលកាប់អំពៅ) ។ បន្ទាប់ពីធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច បានប្រគល់ពួកគាត់ជូនផ្នែកជំនាញរបស់អធិការនគរបាលស្រុកម៉ាឡៃ ដើម្បីមានវិការបន្ត ៕

## ពលរដ្ឋខ្មែរ៥នាក់ បម្រុងឆ្លងដែនខុសច្បាប់ចូលប្រទេសថៃ ត្រូវសមត្ថកិច្ចទប់ស្កាត់ទាន់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

http://freshnewsasia.com/index.php/en/localnews/270080-2022-12-16-14-04-49.html 2022-12-16 09:04pm

**(បន្ទាយមានជ័យ)៖** ដោយមានការណែនាំ និងការដាក់បទបញ្ជាពី លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលការពារព្រំដែនកម្ពុជា-ថៃ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងសភាពការណ៍សន្តិសុខ និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ។

ជាក់ស្តែងនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២នេះ លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក៨១៥ បានចាត់តាំងលោកវរសេនីយ៍ត្រី ឡុក ធី នាយប៉ុស្តិ៍សង្កែដឹកនាំកម្លាំង សហការជាមួយកម្លាំងយោធាវរៈ៥១១ (កងពល៥១) បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋ ចំនួន០៥នាក់ បម្រុងលួចដែនឆ្លងខុសច្បាប់ទៅប្រទេសថៃ នៅចំណុចមាត់អូរព្រំដែន (គោលដៅចំការក្រូចឆ្មារ) ក្នុងភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ។

នៅចំពោះមុខសមត្ថកិច្ច ប្រជាពលរដ្ឋទាំងនោះបាននិយាយថា ពួកគាត់មានគោលបំណងទៅស៊ីឈ្នួលកាប់អំពៅនៅទឹកដីថៃ ដែលបច្ចុប្បន្នពួកគាត់រស់នៅក្នុងខេត្តបន្ទាយមានជ័យ។ ក្រោយសួរនាំ និងធ្វើកិច្ចសន្យារួច បានប្រគល់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់៕

## ក្រុមឆបោកនៅកម្ពុជាប្រើបណ្ដាញអ៊ីនធឺណិតល្បឿនលឿនឆ្លងព្រំដែនពីប្រទេសថៃ

https://www.khmertimeskh.com/501204181//?p=1204181 Khmer Times December 17, 2022

នគរបាលថៃបានឆ្មក់ចូលទីតាំងក្នុងខេត្តស្រះកែវ ហើយបានរកឃើញបណ្ដាញអ៊ីនធឺណិតល្បឿនលឿនឆ្លងព្រំដែនជាច្រើនដែលប្រើសម្រាប់ជាជំនួយដល់ក្រុមឆបោកក្នុងប្រទេសកម្ពុជា។ អគ្គស្នងការរងនគរបាលជាតិ លោក Torsak Sukwimol បានដឹកនាំកម្លាំងចុះឆែកឆេរទីតាំងចំនួន៦ នៅស្រុកអារញ្ញ ខេត្តស្រះកែវ ក្នុងគោលបំណងបង្ក្រាបក្រុមឆបោក ដោយបានកាត់ផ្ដាច់បណ្ដាញអ៊ីនធឺណែតរបស់ពួកគេ។ ទីតាំងទាំងនោះរួមមានកន្លែងផ្ដល់សេវាទូរគមនាគមន៍របស់រដ្ឋ ដែលនគរបាលបានត្រួតពិនិត្យមើលថាតើខ្សែអ៊ីនធឺណិតណាមួយត្រូវបានតម្លើងដោយខុសច្បាប់ ដើម្បីផ្ដល់សេវាអ៊ីនធឺណិតឆ្លងព្រំដែន។ ក្រោយមកសមត្ថកិច្ចបានរកឃើញខ្សែអ៊ីធឺណិតប្រមាណ៣០ខ្សែ ដែលដាក់នៅលើបង្គោលភ្លើង ហើយរត់កាត់ព្រំដែនកម្ពុជា-ថៃ ពីខាងក្រោយស្ថានីយរថភ្លើងព្រំដែន Ban Klong Luk ដែលនៅក្បែរស្ពានឆ្លងព្រំដែន Klong Luk ឆ្ពោះទៅក្រុងប៉ោយប៉ែតប្រទេសកម្ពុជា។

លោកបានបន្តថា "ខ្សែកាបអ៊ីនធឺណិតជាង ១០,០០០ ដែលគេជឿថា បម្រើដល់ក្រុមឆបោកតាមទូរស័ព្ទដែលបានបោកប្រាស់ប្រជាជនថៃជាច្រើន។ នគរបាលបានរកឃើញថា ខ្សែកាបទាំងនោះត្រូវបានប្រើប្រាស់ដើម្បីតភ្ជាប់ការចូលប្រើអ៊ីនធឺណិតដោយខុសច្បាប់ទៅកាន់ប្រទេសកម្ពុជា»។ នៅក្នុងការវាយឆ្មក់ដែលបានធ្វើឡើងកាលពីថ្ងៃពុធសប្ដាហ៍មុន នគរបាលថៃបានចាប់ខ្លួនជនសង្ស័យចំនួន៨នាក់ រួមទាំងមន្ត្រីរដ្ឋាភិបាលផងដែរ។ លោកបានបន្ថែមទៀតថា "ការផ្ដាច់បណ្ដាញអ៊ីនធឺណែតនេះ និងជួយដោះស្រាយបញ្ហាឆបោកតាមទូរស័ព្ទ" ដោយបន្ថែមថា វាអាចយឺតពេលក្នុងការរឹបអូសគណនីធនាគាររបស់ពួកគេ ដោយសារតែលុយជនរងគ្រោះអាចនឹងបានបម្លែងទៅជារូបិយប័ណ្ណឌីជីថល ហើយមិនអាចយកមកវិញបាន។ ការផ្ដាច់បណ្ដាញខ្សែកាបនេះអាចជួយដោះស្រាយបញ្ហាបានយ៉ាងមានប្រសិទ្ធភាព»។

មុននេះ នគរបាលថៃបាននិយាយថា ពួកគេរឹបអូសបានស៊ីមកាតជាង ២០០,០០០ ដែលប្រើសម្រាប់ការឆបោកតាមទូរស័ព្ទ និងឧក្រិដ្ឋកម្មទាក់ទងនឹងការឆបោកដោយបានធ្លាក់ចុះប្រហែល២៥ ភាគរយ។ *Bangkok Post*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ៥ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៩នាក់

http://freshnewsasia.com/index.php/en/localnews/270109-2022-12-17-03-05-11.html 2022-12-17 10:05am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៩នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៦៤៥៤ករណី មានមនុស្ស ១,៥៨២នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤១៨សំណើ និងបិទសំណុំរឿង ២១៤សំណើ (រកឃើញមនុស្ស ៩៩៥នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២២ករណី។

សូមបញ្ជាក់ថា សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្តល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## តុលាការកំពូលពន្យារពេលសវនាការ
## អតីតអ្នកតំណាងរាស្ត្រ អះម៉ាត់យ៉ះយ៉ា និង ក្មួយប្រុស ពាក់ព័ន្ធការលក់ដូរស្ត្រីខ្មែរ ២នាក់ ទៅធ្វើជាទាសករគេ អស់រយៈពេលជិត ១៣ ឆ្នាំ នៅទីបអារ៉ាប់

https://cen.com.kh/archives/590850.html Posted ByPen Srey NeatDecember 17, 2022

ភ្នំពេញៈ តុលាការកំពូល កាលពីព្រឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២២ បានពន្យារពេលសវនាការ លើបណ្តឹងសារទុក្ខរបស់ជនជាប់ចោទ ជនជាប់ចោទ ឈ្មោះ អះម៉ាត់ យ៉ះយ៉ា និង ក្មួយប្រុស ដែលត្រូវបានតុលាការជាន់ទាបកាលពីអំឡុងឆ្នាំ ២០១៩ កាត់ទោស ពួកគេទាំង២នាក់ដាក់គុក ក្នុងម្នាក់ៗ កំណត់ ១៥ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការសង្ស័យការនាំចេញដោយមិនស្របច្បាប់ នូវពលករខ្មែរចំនួនជាង៣០០នាក់ ទៅធ្វើការ នៅប្រទេសអារ៉ាប៊ីសាអូឌីត និងបានបណ្តាលឲ្យស្ត្រីខ្មែរចំនួន២នាក់(ជនរងគ្រោះ) ត្រូវបានគេលក់ដូរដូចសត្វជាតុ ពីគ្រួសារអារ៉ាប់មួយ ទៅគ្រួសារផ្សេងទៀត និងត្រូវបានគេបង្ខំឲ្យធ្វើការដូចទាសករ ដោយគ្មានប្រាក់ខែអស់រយៈពេលជិត ១៣ ឆ្នាំ នៅក្នុងអារ៉ាវសាអូឌីត ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ ២០១៧។

លោក សឹង បញ្ញាវុឌ្ឍ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងថា៖ ការលើកពេលសវនាការលើបណ្តឹងសាទុក្ខរបស់ ជនជាប់ចោទឈ្មោះ អះម៉ាត់យ៉ះយ៉ា និង ក្មួយប្រុស នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២២ នេះ គឺដោយសារតែ ជនជាប់ចោទ ឈ្មោះ អាម៉ាត់ យ៉ះយ៉ា មិនមានមេធាវី ដើម្បីការពារខ្លួនតាមច្បាប់ ពីព្រោះសំណុំរឿងរបស់គាត់ជាបទឧក្រិដ្ឋ។

យោងតាមការអានសំណុំរឿងក្តីរបស់លោកចៅក្រមរបាយការណ៍ បានឱ្យដឹងថាៈ នៅក្នុងរឿងក្តីឧក្រិដ្ឋនេះ ជនជាប់ចោទឈ្មោះ អះម៉ាត់ យ៉ះយ៉ា ភេទ ប្រុស អាយុ ៦៩ ឆ្នាំ ជាខ្មែរអ៊ីស្លាម , ជាអតីតអ្នកតំណាងរាស្ត្រ និងជារដ្ឋលេខាធិការ ក្រសួងសាធារណៈការនិងដឹកជញ្ជូន និង ជាប្រធានក្រុមហ៊ុនAccent Group និងឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ភេទ ប្រុស អាយុ ៤៨ ឆ្នាំ ជនខ្មែរអ៊ីស្លាម និង ជាអតីតមន្ត្រីរាជការ ធ្វើការនៅក្រសួងសាធារណៈការនិងដឹកជញ្ជូន ត្រូវបានសាលាដំបូងខេត្តរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៩ កាត់ទោស ដាក់ពន្ធនាគារ ក្នុង ម្នាក់ៗ កំណត់ ១៥ ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តពួកគេទាំង២នាក់ ពូនិងក្មួយ ត្រូវរួមគ្នាសងជនរងគ្រោះចំនួន២នាក់ សរុប ២០០លានរៀល ពីបទៈ នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន តាមមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិង ការធ្វើអាជីវកម្មផ្លូវភេទ។

ជនជាប់ចោទទាំង២នាក់ បានប្តឹងឧទ្ធរណ៍ ។ តែសាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានតម្កល់ទណ្ឌកម្មរបស់ពួកគេរក្សាទុកជាបានការដដែល ។ ពួកគេក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ នៅក្នុងចំណោមពួកគេទាំង២នាក់ ជនជាប់ចោទឈ្មោះ អ៊ីស្មាអែល ពិនឧស្មាន ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ នៅរាជធានីភ្នំពេញ រីឯជនជាប់ចោទឈ្មោះ អះម៉ាត់យ៉ះយ៉ា ត្រូវបានចាប់ឃាត់ និងឃុំខ្លួន កាលពីថ្ងៃទី

១៣ ខែ សីហា ឆ្នាំ ២០២១ បន្ទាប់ពី តុលាការរាជធានីភ្នំពេញ បានប្រកាសសាលក្រម និងសម្រេចផ្តន្ទាទោសគាត់ ដាក់ពន្ធនាគារ កំណត់ ១៥ ឆ្នាំ។ រក្សាសិទ្ធិដោយ: ចន្ទា ភា

## រថយន្តក្រឡាប់ ស្លា.ប់កម្មករខ្មែរម្នាក់ និងរងរបួសធ្ងន់ ស្រាល ២៤នាក់ ខណៈកំពុងជិះរថយន្ត ទៅបេះផ្លែមៀននៅប្រទេសថៃ

https://cen.com.kh/archives/590906.html Posted ByPen Srey NeatDecember 17, 2022

ប្រទេសថៃ ៖ យ៉ាងហោចណាស់ក៏មានពលករខ្មែរម្នាក់ បានបាត់បង់ជីវិត ក្នុងចំណោមពលករទាំង២៥នាក់ ខណៈកំពុងជិះរថយន្តថៃទៅស៊ីឈ្នួលបេះផ្លែមៀននៅខេត្តច័ន្ទបុរី ប្រទេសថៃ ហើយត្រូវរថយន្តក្រឡាប់។ យោងតាមគេហទំព័រក្នុងប្រទេសថៃ បានផ្សាយថា នៅវេលាម៉ោង ៦ និង ២៧នាទីព្រឹក ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ នៅលើកំណាត់ផ្លូវជាតិលេខ ៣១៧ ក្នុងឃុំប៉ាក់តុង ស្រុកសយដាវខេត្តច័ន្ទបុរី ប្រទេសថៃ មានករណីរថយន្តដឹកពលករខ្មែរក្រឡាប់ធ្លាក់ចេញពីផ្លូវ ។ ព័ត៌មានបានបន្តថា នៅក្នុងរថយន្តនោះ មានដឹកពលករខ្មែរចំនួន ២៥នាក់ ដោយក្នុងទិសដៅទៅកានចម្ការដើម្បីបេះផ្លែមៀនឲ្យថៅកែថៃ ។ លុះដល់ត្រង់ចំណុចខាងលើ ទំនងជារថយន្តនេះ បែកកង់មុខម្ខាង ទើបបណ្តាលឲ្យរថយន្តនេះក្រឡាប់ផ្ងារជើងតែម្តង។

ជាលទ្ធផលក្រោយពីក្រុមតម្រួតចុះពិនិត្យ គឺសង្កេតឃើញថា មានពលករខ្មែរ១ម្នាក់ ត្រូវបានស្លាប់នៅនឹងកន្លែង ហើយមានអ្នករបួសធ្ងន់ចំនួន១០នាក់ និងស្រាលចំនួន ១៤នាក់ ដែលបច្ចុប្បន្ននេះ ជនរងគ្រោះទាំងនោះត្រូវបានបញ្ជូនទៅសង្គ្រោះនៅឯមន្ទីរពេទ្យ ស្រុកសយដាវ ។ រក្សាសិទ្ធិដោយ ៖ សួង សាម

# ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ២០២២

## នគរបាលថៃចុះឆែកឆេរទីតាំងក្នុងខេត្តស្រះកែវ ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហៅទូរស័ព្ទខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/501204413//?p=1204413 Khmer Times December 18, 2022

នគរបាលថៃបានឆ្មក់ចូលទីតាំងចំនួនប្រាំមួយកន្លែងក្នុងខេត្តស្រះកែវ ប្រទេសថៃ ហើយបានចាប់ខ្លួនជនសង្ស័យរាប់សិបនាក់ដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងនឹងក្រុមឆបោកតាមទូរសព្ទនៅកម្ពុជា។ ប្រតិបត្តិការនេះធ្វើឡើងរួមគ្នាដោយក្រសួងឌីជីថល សេដ្ឋកិច្ច និងសន្តិសុខ (DES) និងនគរបាលភូមិន្ទថៃ។

ស្នងការរងនគរបាលថៃ លោក Torsak Sukwimpol បាននិយាយថា នគរបាលបានទទួលពាក្យបណ្តឹងពីជនរងគ្រោះកាលពីថ្ងៃទី២៧ ខែមេសា ថាពួកគេត្រូវបានបោកបញ្ឆោតក្នុងការវិនិយោគនៅក្នុងគេហទំព័របោកប្រាស់មួយដែលមានឈ្មោះថា "Amata" ដែលសន្យាថានឹងទទួលបានប្រាក់ចំណូលខ្ពស់។ លុះដល់ថ្ងៃកំណត់ ជនរងគ្រោះមិនអាចដកប្រាក់បានឡើយ ហើយក្រុមឆបោករកលេសនានា និងព្យាយាមបញ្ចុះបញ្ចូលជនរងគ្រោះឱ្យបណ្តាក់ទុនបន្ថែម បណ្តាលឱ្យខាតបង់ប្រាក់ចំនួន ២៥៧,១១៥បាត។ ពាក្យបណ្តឹងជាច្រើនត្រូវបានផ្ញើទៅកាន់គេហទំព័រ "thaipoliceonline.com" ដោយផ្សព្វផ្សាយការស៊ើបអង្កេតលើការឆបោក ដែលបង្ហាញពីតំណភ្ជាប់ទៅកាន់ National Telecom Public Co Ltd.

យោងតាមនគរបាលថៃ ការស៊ើបអង្កេតបានបង្ហាញថា ជនជាតិខ្មែរម្នាក់ឈ្មោះ Monoram Som បានបង់វិក្កយបត្រអ៊ិនធឺណិតប្រចាំខែជាង ២០០,០០០ បាតក្នុងប្រទេសថៃជាមួយក្រុមហ៊ុន CAT Telecom Public Co

Ltd ។ ការត្រួតពិនិត្យបច្ចេកទេសក៏បានរកឃើញការតភ្ជាប់អ៊ីធឺណិតឆ្លងដែននៅក្នុងប្រទេសថៃដែលកំពុងដំណើរការដោយខុសច្បាប់។

ឧត្តមសេនីយ៍ Torsak ឆែកឆេរឃើញ Mr Monorom តែងតែធ្វើដំណើរទៅប្រទេសថៃ។ បុរសនោះបានធ្វើអាជីវកម្មសេវាកម្មអ៊ីនធឺណិត ដោយបន្ថែមថាអតិថិជនរបស់ Mr Monorom ភាគច្រើនជាប់ពាក់ព័ន្ធនឹងការឆបោកនៅកម្ពុជា។ នគរបាលក៏បានរកឃើញទំនាក់ទំនងរវាង Mr Monorom និងលោក Siapo Po-arnon ដែលជាបុគ្គលអ៊ីនធឺណិតដ៏មានប្រជាប្រិយមួយរូប ដែលបានផ្តល់ដំបូន្មានដល់ក្រុម Thai House អំពីល្បែងស៊ីសង ទាក់ទងនឹងការលាងលុយ។ នគរបាលនិយាយថា បណ្តាញអ្នកបោកប្រាស់ត្រូវបានគេរាយការណ៍ថាបានដំណើរការអស់រយៈពេល ១២ឆ្នាំមកហើយ ហើយមន្ត្រីរដ្ឋមកពីប្រទេសថៃបានជាប់ពាក់ព័ន្ធ។

ក្នុងប្រតិបត្តិការនេះ ជនសង្ស័យ៦០នាក់ក្នុងចំណោម១០០នាក់ដែលមានដីកាតាមចាប់ខ្លួន ត្រូវចាប់ខ្លួនពីបទបើកគណនីដើម្បីលាងលុយ។ យ៉ាងហោចណាស់ត្រូវប្រឈមមុខនឹងការចោទប្រកាន់ចំនួនពីរ រួមទាំងការក្លែងបន្លំ ការលួចអត្តសញ្ញាណ និងការផ្សព្វផ្សាយព័ត៌មានមិនពិត៕ *Bangkok Post*

## សង់ត្រាល់៖ ក្នុងឆ្នាំ២០២២មានជាង១០០ករណីដែលពលករខ្មែរចំណាកស្រុកចាញ់បោកមេខ្យល់

https://www.rfi.fr/km//20221218-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 18/12/2022 - 07:47

*អង្គការសង់ត្រាល់បានរកឃើញថា ក្នុងឆ្នាំ២០២២ មានករណីពលករខ្មែរចំណាកស្រុកចាញ់បោកមេខ្យល់ជាង១០០ករណី។ មន្ត្រីនៃអង្គការសង់ត្រាល់ បញ្ជាក់ថា ទាំងជាង១០០ករណី ដែលពលករខ្មែរត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ហើយមានខ្លះទៀតបានចាញ់បោកមេខ្យល់ អស់ប្រាក់ចន្លោះពី២០០ទៅ៥០០ដុល្លារអាមេរិក។*

មានបញ្ហាប្រឈមចម្បងមួយចំនួន ដែលពលករខ្មែរចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស កំពុងតែប្រឈមនៅអំឡុងពេលវិបត្តិកូវីដ១៩ និងក្រោយវិបត្តិកូវីដ១៩។ លោក ឌី ថេហូយ៉ា ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់ បានប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃអាទិត្យនេះ ថា ពលករខ្មែរមួយចំនួន បានប្រឈមនឹងការចាប់ខ្លួនពីសំណាក់អាជ្ញាធរថៃ ដោយសារតែការធ្វើដំណើររកការងារធ្វើ នាអំឡុងពេលអាជ្ញាធរថៃរឹតត្បិតការធ្វើដំណើរដោយសារតែការឆ្លងជំងឺកូវីដ១៩។ បើតាមលោក ឌី ថេហូយ៉ា ពលករខ្មែរទាំងនោះ បានប្រឈមនឹងភាពគ្មានការងារ និងជំពាក់បំណុល ហើយពលករខ្លះទៀត ក៏ប្រឈមនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបទល្មើសជួញដូរមនុស្សជាដើម។ នៅទន្ទឹមនឹងបញ្ហាទាំងនេះ មន្ត្រីនៃអង្គការសង់ត្រាល់ បានឲ្យដឹងទៀតថា ប្រជាពលរដ្ឋខ្មែរមួយចំនួន ត្រូវបានគេឆបោកអស់ប្រាក់ចន្លោះពី ២០០ទៅ៥០០ដុល្លារ ដើម្បីធ្វើឯកសារចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ លោក ឌី ថេហូយ៉ា ថាបញ្ហាទាំងនេះ គឺទាមទារឲ្យរដ្ឋាភិបាលគិតគូបន្ថែមទៀត អំពីការធានាសុវត្ថិភាពរបស់ប្រជាពលរដ្ឋខ្មែរ ពេលធ្វើចំណាកស្រុកទៅធ្វើការនៅឯបរទេស។

ការអះអាងរបស់មន្ត្រីសង់ត្រាល់ បែបនេះ ធ្វើឡើងនៅអំឡុងពេលដែលអង្គការដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិការងារមួយនេះ បាននិងកំពុងរៀបចំទិវាអ្នកចំណាកស្រុកអន្តរជាតិលើកទី២៣ នៅថ្ងៃនេះ ដោយមានការចូលរួមពីបណ្តាប្រជាពលរដ្ឋមួយចំនួន នៅតាមមូលដ្ឋាន។ បើតាមលោក ឌី ថេហូយ៉ា គឺទិវាមួយនេះ មានសារសំខាន់ ដើម្បីឲ្យពលរដ្ឋបានស្វែងយល់ពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងជាទិវាមួយដើម្បីឲ្យរដ្ឋាភិបាល បានស្វែងយល់ពីបញ្ហាប្រឈមរបស់ពលករខ្មែរ និងដោះស្រាយបញ្ហារបស់ពួកគេ។

បើតាមរបាយការណ៍របស់អង្គការសង់ត្រាល់ មានប្រជាពលរដ្ឋខ្មែរប្រមាណជាង២លាន៥សែននាក់ បានចំណាកស្រុកទៅរកការងារធ្វើនៅឯក្រៅប្រទេស ដើម្បីរកចំណូលមកផ្គត់ផ្គង់គ្រួសារនៅក្នុងស្រុក។ ក្នុងចំណោមនោះ

នៅប្រទេសថៃ មានពលករខ្មែរប្រមាណជាង ២លាន កំពុងប្រកបរបរការងារ នៅតាមសហគ្រាស រោងចក្រ ឧស្សាហកម្មមួយចំនួន៕

## តុលាការកំពូល តម្កល់ទោសបុរសជាប់ចោទអាមេរិកកាំង ឈ្មោះ Robinson Shaun Earl ជាប់គុក ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការរួមភេទជាមួយ

https://cen.com.kh/archives/591786.html Posted ByPen Srey Neat December 19, 2022

ភ្នំពេញ: បុរសជាប់ចោទជនជាតិអាមេរិកម្នាក់ ដែលនិយមរួមភេទ ជាមួយមនុស្សប្រុស និង ប្រុស ជាពិសេស កុមារាខ្មែរ កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២២ ត្រូវបាន តុលាការកំពូល បានប្រកាសសាលដីកា តម្កល់ទោសគាត់ឲ្យជាប់ពន្ធនាគារ កំណត់ ៧ ឆ្នាំ ដដែល ជាប់ពាក់ព័ន្ធនឹងការបៀតបៀនកេរ្តិ៍ខ្មាស និងការរួមភេទជាមួយកុមារាខ្មែរ ជាច្រើននាក់តាមរន្ធ (បានសម្រេច) ប្រព្រឹត្តនៅក្នុងបន្ទប់ជួលរបស់ ជនល្មើស ស្ថិតនៅភូមិសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីពីអំឡុងឆ្នាំ ២០១៩។

ប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ លោក និន ណុន បានថ្លែងឲ្យដឹងថា ទណ្ឌិតរូបនេះមានឈ្មោះ ROBINSON SHAUN EARI ( រ៉ូប៊ីនសុន ស៊ននអែល ) ភេទប្រុស អាយុ ៤១ ឆ្នាំ ជនជាតិអាមេរិកកាំង ។ គាត់ត្រូវបានចាប់ឃាត់ខ្លួន តាមបណ្តឹងរបស់ ស្ត្រីខ្មែរម្នាក់ ដែលត្រូវជាម្តាយរបស់កុមារា ឈ្មោះ ស.ជ.ណ អាយុ ១៤ ឆ្នាំ ដែលត្រូវជាកូន បន្ទាប់ពី គាត់បានល្បួងលួងលោម ទៅលេងបន្ទប់ជួលរបស់ខ្លួន និងបាន ប្រព្រឹត្តការបៀតបៀនផ្លូវភេទ និង បង្ខំឱ្យ កុមាររងគ្រោះ រួមភេទតាមរន្ធគូថ សម្រេចដូចបំណង ជាថ្នូរនឹងការឲ្យលុយ ២៥ ដុល្លារ។ ក្រោយឃាត់ខ្លួនគាត់, សមត្ថកិច្ចនគរបាលប្រឆាំងការជួញដូរមនុស្សនិង គាំពារអនីតិជន ខេត្តសៀមរាប ហូតបានវត្ថុតាងមានរួមមាន: កុំព្យូទ័រឡែបថប ១ គ្រឿង ,អង្គចងចាំ១គ្រឿង , ដៃហ្គេមក្មេងលេង៣គ្រឿង, កញ្ចាំរអិល២ដប ( ទឹកសម្រាប់រួមភេទ ) ព្រមទាំង ថតអាក្រាត និង វិដេអូ សិច មួយចំនួន ពីគាត់៕ រក្សាសិទ្ធិដោយ : ចន្ទា ភា

## សង់ត្រាល់ប្រារព្ធទិវាអ្នកចំណាកស្រុកអន្តរជាតិ ជំរុញឱ្យរដ្ឋាភិបាលផ្ដល់ភាពស្របច្បាប់ និងកិច្ចគាំពារសង្គមដល់ពលករចំណាកស្រុក

https://www.rfa.org/khmer/news/social-economy/central-celebrates-international-imigrant-day-urging-government-to-provide-legal-status-and-social-protection-to-migrant-workers-12182022181017.html ដោយ មាន ឫទ្ធិ2022.12.18

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ (CENTRAL) ប្រារព្ធទិវាអ្នកចំណាកស្រុកអន្តរជាតិ លើកទី២៣ នៅថ្ងៃទី១៨ ខែធ្នូ នៅទីតាំងចំនួន៩ផ្សេងគ្នា ដើម្បីជំរុញឱ្យរដ្ឋាភិបាលផ្ដល់ភាពស្របច្បាប់ និងកិច្ចគាំពារសង្គមដល់ពលករចំណាកស្រុក។ ទិវាអ្នកចំណាកស្រុកអន្តរជាតិរបស់អង្គការសង់ត្រាល់នេះមានអ្នកចូលរួមសរុបជាង៩រយនាក់ (៩៣២នាក់) ពួកគេទាំងនោះគឺជាអតីតពលករចំណាកស្រុក គ្រួសារពលករចំណាកស្រុក ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សជាដើម។ អ្នកចូលរួមកម្មវិធីទាំងនេះ បានដង្ហែក្បួនផ្សព្វផ្សាយពីវិធីធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងរៀបចំជាវេទិកាសហគមន៍ចំនួន៩ទីតាំងផ្សេងគ្នា នៅតាមបណ្ដាខេត្តចំនួន៤ រួមមានខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តបាត់ដំបង។

មន្ត្រីកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តប្រវេសក៍ នៃអង្គការសង់ត្រាល់ (CENTRAL) កញ្ញា ទ្រី សុភា ប្រាប់វិទ្យុអាស៊ីសេរីថា គោលបំណងនៃការប្រារព្ធទិវាអ្នកចំណាកស្រុកអន្តរជាតិនេះគឺមាន៣ ទី១ គឺចង់

ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ គោលបំណងទី២ គឺជំរុញឱ្យរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលដល់ការធ្វើចំណាកស្រុករបស់ពលករខ្មែរទៅធ្វើការនៅបរទេស ជាពិសេសទៅកាន់ប្រទេសថៃ។ គោលបំណងចុងក្រោយ គឺជំរុញឱ្យរដ្ឋាភិបាលផ្តល់កិច្ចគាំពារសង្គមដល់ពលករចំណាកស្រុក ពេលដែលពួកគេត្រឡប់មករស់នៅក្នុងប្រទេសវិញ។ កញ្ញា ទ្រី សុភា បន្ថែមថា មូលហេតុដែលពលករខ្មែរភាគច្រើនសម្រេចចិត្តធ្វើចំណាកស្រុកដោយខុសច្បាប់ គឺដោយសារនីតិវិធីនៃការធ្វើចំណាកស្រុកមានលក្ខណៈស្មុគស្មាញ ត្រូវចំណាយថវិកាច្រើន និងរយៈពេលយូរ៖

*«មែនទែនទៅគឺយើងព្យាយាមប្រូម៉ូត ហ្សេរ៉ូ រីគ្រូតមិន ហ្វី (Promote Zero Recruitment Fees) ដែលការចំណាយពាក់ព័ន្ធទៅនឹងការធ្វើចំណាកស្រុករបស់ពលរដ្ឋកម្ពុជា វាគួរតែជាបន្ទុករបស់ថៅកែ វាមិនគួរជាបន្ទុករបស់កម្មករទេ អញ្ចឹងបើកាលណាដែលគាត់អាចទៅដោយមិនចំណាយប្រាក់ពីហោប៉ៅរបស់គាត់ ធ្វើឱ្យគាត់អាចស្វែងរកការចំណាកស្រុកមួយតាមប្រព័ន្ធ ដែលសមរម្យដែលគាត់អាចទៅដោយអត់មានបង់ថវិកា។ តាមពិតអាហ្នឹងគឺជាអ្វីដែលយើងចង់ឃើញ»*។

កន្លងមក អង្គការសង់ត្រាល់បានប៉ាន់ស្មានថា ក្នុងចំណោមពលករខ្មែរធ្វើការចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ជិត២លាននាក់ (២.០០០.០០០នាក់) មានពលករធ្វើចំណាកស្រុកដោយស្របច្បាប់ត្រឹមតែជាង ១៥ ម៉ឺននាក់ (១៥០.០០០នាក់) តែប៉ុណ្ណោះ។ ដោយឡែករបាយការណ៍ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញថាពលករខ្មែរដែលមាន និងមិនមានកិច្ចព្រមព្រៀងធ្វើចំណាកស្រុកផ្លូវការនៅក្នុងប្រទេសថៃមានសរុបចំនួន១លាន៣សែននាក់ (១.៣០០.០០០នាក់)។ ប្រជាពលករខ្មែរនៅតែជ្រើសរើសយកការធ្វើដំណើរទៅធ្វើការនៅប្រទេសថៃ ដោយលួចលាក់តាមច្រករបៀង ដោយសារពួកគេមិនមានលុយគ្រប់គ្រាន់ដើម្បីបំពេញនីតិវិធីធ្វើចំណាកស្រុកដោយស្របច្បាប់ ខណៈពលរដ្ឋខ្មែរភាគច្រើនដែលសម្រេចចិត្តធ្វើចំណាកស្រុក គឺដោយសារពួកគេគ្មានការងារធ្វើ និងមានជីវភាពក្រីក្រ។ ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសក៍ នៃអង្គការសង់ត្រាល់ លោក ឪថេ ហូយ៉ា ធ្លាប់បានលើកឡើងថា ៨០ភាគរយ (៨០%) នៃពលករធ្វើចំណាកស្រុកទៅប្រទេសថៃ គឺបណ្តាលមកពីជំពាក់បំណុលធនាគារវណ្ណើក ដូច្នេះហើយពួកគេត្រូវបង្ខំចិត្តធ្វើចំណាកស្រុក ដើម្បីរកចំណូលផ្គត់ផ្គង់ជីវភាព និងសងបំណុលធនាគារ។

ជុំវិញការប្រារព្ធទិវាអ្នកចំណាកស្រុកអន្តរជាតិលើកទី២៣នេះ អ្នកប្រឹក្សាអំពីការធ្វើការចំណាកស្រុកដោយសុវត្ថិភាព នៃអង្គការសង់ត្រាល់ ប្រចាំឃុំកំរើល ស្រុកពួក ខេត្តសៀមរាប លោក ធិម ឈា ប្រាប់វិទ្យុអាស៊ីសេរីថា នៅឃុំរបស់លោកមានអ្នកចូលរួមដង្ហែក្បួនផ្សព្វផ្សាយពីការធ្វើចំណាកស្រុក ដោយសុវត្ថិភាពជាង ១រយនាក់ (១០៥ នាក់) ដោយមានជិះគោយន្តចំនួន៨គ្រឿង។ លោកបន្ថែមថា ប្រជាពលរដ្ឋនៅក្នុងឃុំរបស់លោក ភាគច្រើនបានធ្វើការចំណាកស្រុកដោយខុសច្បាប់ ព្រោះពួកគេត្រូវការធ្វើចំណាកស្រុកឱ្យបានលឿន ដើម្បីរកចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។ លោកបន្ថែមថា កន្លងមកប្រជាពលរដ្ឋខ្លះដែលដាក់ពាក្យធ្វើចំណាកស្រុកតាមក្រុមហ៊ុន ត្រូវចំណាយលុយអស់រហូតដល់៥រយដុល្លារអាមេរិក (៥០០ដុល្លារអាមេរិក) ដើម្បីធ្វើឯកសារចំណាកស្រុក ហើយពេលខ្លះទម្រាំអាចធ្វើចំណាកស្រុកបាន គឺត្រូវចំណាយពេលដល់៦ខែក៏មាន។ លោក ធិម ឈា យល់ឃើញថា រដ្ឋាភិបាលគួរលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ការងារដែលមានប្រាក់ខែសមរម្យ និងរកទីផ្សារលក់ផលិតផលជូនដល់កសិករ ដើម្បីកាត់បន្ថយកុំឱ្យប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុកដោយខុសច្បាប់៖

*«ឧទាហរណ៍ យើងដាំបន្លែបានហើយមានទីផ្សារកសិកម្មមួយដែលអាចលក់បានតម្លៃសមរម្យ ខ្ញុំគិតថាប្រជាពលរដ្ឋខ្មែរអត់មាននរណាចង់ចេញពីស្រុកកំណើតទេ ព្រោះខ្ញុំក៏ជាប្រជាពលរដ្ឋក្រមួយរូបដែលធ្លាប់ឆ្លងកាត់បញ្ហាហ្នឹងច្រើន អញ្ចឹងខ្ញុំក៏យល់ថា គ្មាននរណាចង់ចាកចេញ ចោលប្រពន្ធចោលកូន ចោលគ្រួសារទេ»*។

ជុំវិញការលើកឡើងនេះ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរ និងរត់ពន្ធមនុស្ស លោកស្រី ជូ ប៊ុនអេង ប្រាប់វិទ្យុអាស៊ីសេរីថា តម្លៃនៃការធ្វើនីតិវិធីចំណាកស្រុករបស់រដ្ឋាភិបាលមិនថ្លៃខ្ពស់នោះទេ បើប្រៀបធៀបជាមួយប្រទេសជិតខាង។ លោកស្រីមានប្រសាសន៍ថា មូលហេតុដែលប្រជាពលរដ្ឋចំណាយថវិកាច្រើន គឺបណ្ដាលមកពីពលករមិនធ្វើឯកសារដោយខ្លួនឯងផ្ទាល់ ហើយឱ្យក្រុមហ៊ុនរកកម្រៃជើងសាធ្វើឱ្យ៖

*«ដោយសារមានពេលខ្លះគាត់នៅប្រទេសថៃស្រាប់ ហើយនៅពេលដែលគាត់ធ្វើការទំនាក់ទំនង គាត់ទាក់ទងជាមួយនិយោជក ឬមួយក៏ទាក់ទងជាមួយអ្នករត់ការ ហើយគាត់អត់បានស្ដាប់អ្វីដែលយើងបានជម្រាបគាត់ទេ»។*

បើតាមអង្គការសង់ត្រាល់ ក្នុងឆ្នាំ២០២២នេះ ពលករខ្មែរធ្វើចំណាកស្រុកដោយខុសច្បាប់ដែលត្រូវបានឃាត់ខ្លួនចំនួន៩២ករណី គឺស្មើនឹងជាង២ពាន់នាក់ (២,១២១នាក់) ហើយក្នុងនោះ៤០ភាគរយ(៤០%) គឺជាស្ត្រី និងកុមារ។ អង្គការសង់ត្រាល់រកឃើញថា ការធ្វើចំណាកស្រុកតាមប្រព័ន្ធផ្លូវការ ឬ អឹម.អូ.យូ (MOU) មានការលំបាកខ្លាំង ដោយពលករម្នាក់ត្រូវចំណាយថវិកាចន្លោះពី៣០០ ទៅ ៥០០ដុល្លារអាមេរិក និងត្រូវរង់ចាំចន្លោះពី១ខែ ទៅដល់៦ខែទើបអាចធ្វើចំណាកស្រុកដោយស្របច្បាប់បាន។ កន្លងមក ក៏ធ្លាប់មានករណីជាច្រើនដែលពលករខ្មែរ ត្រូវបានកម្លាំងមានសមត្ថកិច្ចថៃបាញ់សម្លាប់ និងចាប់ខ្លួនដាក់ពន្ធនាគារក្នុងពេលលួចឆ្លងដែនដោយខុសច្បាប់ចូលទៅក្នុងទឹកដីថៃ។ ជាមួយគ្នានេះពលករខ្មែរជាច្រើនដែលទៅធ្វើការដោយខុសច្បាប់ ក៏ត្រូវបានថៅកែថៃរំលោភសិទ្ធិការងារ ដោយបង្ខំឱ្យធ្វើការលើសម៉ោង និងមិនបើកប្រាក់ខែឱ្យជាដើម៕

## ស្ថានទូតខ្មែរនៅសហការជាមួយអាជ្ញាធរថៃតាមចាប់ជនបរទេសពីរនាក់ដែលធ្វើបាបស្ត្រីវិចិត្រករខ្មែរ

https://www.rfa.org/khmer/news/human-rights/cambodia-embassy-will-work-with-thai-to-find-justice-for-a-cambodian-woman-who-was-tortured-by-two-polishmen-12172022121338.html ដោយ ថា ថៃ2022.12.17

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃឲ្យដឹងថា ស្ថានទូតកម្ពុជា កំពុងសហការជាមួយអាជ្ញាធរថៃ ដើម្បីស្នើទៅប៉ូលិសអន្តរជាតិតាមចាប់ជនបរទេសពីរនាក់ ដែលបានវាយធ្វើបាបស្ត្រីវិចិត្រករខ្មែរម្នាក់នៅប្រទេសថៃ បណ្ដាលឲ្យរងរបួសធ្ងន់ធ្ងរស្ទើរបាត់បង់ជីវិត។ ប៉ុន្តែស្ត្រីរងគ្រោះថា នៅមិនទាន់ឃើញស្ថានទូតខ្មែរទាក់ទងទៅគាត់ និងគ្រួសារដើម្បីរកដំណោះស្រាយរឿងអំពើហិង្សាលើរាងកាយនេះទេ បើទោះជាកញ្ញាបានដាក់បណ្ដឹងរយៈពេលមួយខែហើយក៏ដោយ។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ អះអាងថា ស្ថានទូតកម្ពុជាប្រចាំ ប្រទេសថៃ កំពុងប្រតិបត្តិការរួមគ្នាជាមួយសមត្ថកិច្ចថៃ ដើម្បីស៊ើបអង្កេតលើករណីបុរសជនជាតិប៉ូឡូញពីរនាក់ ដែលបានវាយដំ ចាក់កាំបិត និងជះទឹកអាស៊ីតលើរាងកាយស្ត្រីវិចិត្រករខ្មែរម្នាក់បណ្ដាលឲ្យរបួសធ្ងន់ធ្ងរ ក្នុងក្រុងផាត់ថៈយ៉ា (Pattaya) ខេត្តឈុនបុរី (Chun Buri) កាលពីថ្ងៃទី១ ខែវិច្ឆិកា។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ប្រាប់វិទ្យុអាស៊ីសេរី នៅព្រឹកថ្ងៃទី១៦ ខែធ្នូ ថា អ្នកស្រីបានទូរស័ព្ទទៅស្ថានទូតខ្មែរនៅទីក្រុងបាងកក សួរនាំពីបញ្ហាស្ត្រីខ្មែររងទារុណកម្មនៅទីនោះ ហើយស្ថានទូត ឆ្លើយតបថា សមត្ថកិច្ចថៃកំពុងចាត់វិធានការលើរឿងនេះ។ អ្នកស្រីបន្តថា ស្ថានទូតក៏មិនបណ្ដោយឲ្យស្ត្រីខ្មែររងគ្រោះ ទទួលការវាយប្រហារជាលើកទីពីរទេ ដោយសារពេលនេះ អាជ្ញាធរកម្ពុជានិងថៃបានរួមដៃគ្នាការពារសុវត្ថិភាពជូនជនរងគ្រោះ និងគ្រួសារ តាមពាក្យបណ្ដឹងរបស់ស្ត្រីរងគ្រោះ។ អ្នកស្រី ជូ ប៊ុនអេង៖ «ការពិតចំពោះបទល្មើសគេហៅថាដែលកើតនៅក្នុងដែនដី

ណា អ៊ីចឹងបើដែនដីថៃហ្នឹងគឺសមត្ថកិច្ចថៃជាអ្នកទទួលខុសត្រូវ តែយើងមានភារកិច្ចសហការ។ អ៊ីចឹងយើងបានជូនដំណឹងមកខាងសមត្ថកិច្ចក្នុងស្រុកនេះ ដើម្បីធ្វើការការពារសុវត្ថិភាពក្រុមគ្រួសាររបស់គាត់នៅក្នុងស្រុក ហើយយើងកំពុងតែតាមដានបន្តដែររឿងហ្នឹងណា ពីព្រោះវាទាក់ទងនឹងជនជាតិយើងអ៊ីចឹងណា»។ អ្នកស្រី ជូ ប៊ុនអេង ថា កម្ពុជាកំពុងតាមដានលើរឿងនេះ និងជំរុញឲ្យសមត្ថកិច្ចអន្តរជាតិតាមចាប់ជនល្មើសឲ្យបានឆាប់។

ផ្ទុយពីការលើកឡើងរបស់រដ្ឋាភិបាលខ្មែរ ស្ត្រីវិចិត្រករខ្មែរ ដែលជាជនរងគ្រោះ កញ្ញា នី ស្រីវ័ត្ន ប្រាប់វិទ្យុអាស៊ីសេរីថា កញ្ញាមិនដែលទទួលបានដំណឹងពីស្ថានទូតខ្មែរនៅប្រទេសថៃ ទាក់ទងមកសួរនាំពីបណ្តឹងរបស់កញ្ញាទេ។ កញ្ញាបញ្ជាក់ថា កញ្ញាបានដាក់ពាក្យប្តឹងនៅស្ថានទូតតាំងពីថ្ងៃទី១៦ ខែវិច្ឆិកា មកទល់ពេលនេះគ្មានបានចម្លើយសោះ ហើយកញ្ញាបានទូរស័ព្ទ និងអ៊ីម៉ែលទៅសួរមន្ត្រីស្ថានទូត ឈ្មោះ លោក ធារី តែលោក ធារី ឆ្លើយថាស្ថានទូតកំពុងដំណើរការលើរឿងនេះ។ កញ្ញានៅតែបារម្ភពីសុវត្ថិភាពខ្លួនឯង នៅថៃ និងក្រុមគ្រួសារនៅកម្ពុជា ដោយសារជនល្មើសបន្តគំរាមថា នឹងធ្វើបាបពួកគាត់បន្តទៀត។ កញ្ញាថា មានអាជ្ញាធរថៃមកសួរនាំ និងឃ្លាំមើលសុវត្ថិភាពកញ្ញាម្តងម្កាលដែរ នៅប្រទេសថៃនេះ។

កញ្ញា នី ស្រីវ័ត្ន៖ «ចាសហើយបន្ទាប់មកខ្ញុំក៏ព្យាយាមតេទៅខាងស្ថានទូតខ្មែរនៅថៃនេះឡើងបីដងថា តើខ្ញុំអាចសុំក្រដាសដែលពាក់ព័ន្ធ ដែលថាបងបានផ្ញើបញ្ជូនទៅខាងស្ថានទូតខ្មែរអ៊ីចឹងណា ខ្ញុំសុំអាចសុំក្រដាសបានអត់។ តែគាត់នៅតែថាផ្ញើទៅហើយ ប៉ុន្តែគាត់អត់ទាន់ផ្ញើឲ្យខ្ញុំ។ ផ្ញើអ៊ីម៉ែលទៅគាត់ បើសិនជាពិបាកផ្ញើ ផ្ញើតាមអ៊ីម៉ែលក៏ខ្ញុំអត់ទាន់ទទួល មកដល់ឥឡូវក៏ខ្ញុំអត់ទាន់បានទទួលការខល ឬក៏ព័ត៌មានអីមួយដែលបញ្ជាក់ថា ឯកសារទាំងអស់បានទៅដល់អ៊ីចឹងណា គ្រាន់តែឮតាមពាក្យសម្តីប៉ុណ្ណឹងឯងតែជាក់ស្តែងខ្ញុំអត់ទាន់ទទួលបានអីទេ»។

ស្ត្រីជាងគំនូរខ្មែរ គឺកញ្ញា នី ស្រីវ័ត្ន ឲ្យដឹងថា នាងត្រូវបានបុរសជនជាតិប៉ូឡូញពីរនាក់វាយធ្វើបាប ចាក់នឹងកាំបិត ព្រមទាំងជះទឹកអាស៊ីតលើមុខ និងលើរាងកាយ បណ្តាលឲ្យរបួសជាង ២៦០ថ្នេរ កាលពីថ្ងៃទី១ ខែវិច្ឆិកា នៅទីក្រុងផាត់ថៈយ៉ា (Pattaya) ខេត្តឈុនបុរី (Chonburi)។ ជនរងគ្រោះរូបនេះរៀបរាប់ថា នៅថ្ងៃកើតហេតុមានស្ត្រីជនជាតិថៃម្នាក់ បានទូរស័ព្ទហៅកញ្ញាឲ្យទៅគូរគំនូរនៅលើជញ្ជាំងក្នុងហាង ដែលទើបបើកថ្មី។ តែលុះទៅដល់កន្លែងកើតហេតុ ស្ត្រីថៃនោះឲ្យបុរសបរទេសពីរនាក់មកទទួលកញ្ញា ហើយស្រាប់តែបុរសទាំងពីរ ចាប់ចងដៃជើង និងយកកញ្ញា ទៅវាយធ្វើបាបតែម្តង។ កញ្ញា អះអាងថា មិនដែលមានទំនាស់ ឬស្គាល់ជនល្មើសឡើយ ប៉ុន្តែកញ្ញា ដាក់ការសង្ស័យថា ករណីនេះអាចជាការប្រច័ណ្ឌរបស់ស្ត្រីថៃម្នាក់ ដែលបានបែកគ្នានឹងប្តីបរទេស ហើយចោទកញ្ញាថា ជាអ្នកបំបែកបំបាក់ពួកគេ។ ក្រោយកើតហេតុ កញ្ញា ក៏បានប្តឹងទៅអគ្គស្នងការនគរបាលជាតិថៃ និងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ហើយប៉ូលិសថៃកំពុងប្រតិបត្តិការលើរឿងនេះ តែស្ថានទូតខ្មែរមិនទាន់មានការឆ្លើយតបទេ។

បច្ចុប្បន្ននេះ កញ្ញា នី ស្រីវ័ត្ន កំពុងរស់នៅក្នុងប្រទេសថៃតែម្នាក់ឯង ហើយមុខរបួស ក៏មិនទាន់ជាសះស្បើយដែរ ប៉ុន្តែកញ្ញា បានចាកចេញពីមន្ទីរពេទ្យទៅសម្រាកព្យាបាលនៅផ្ទះ ព្រោះខ្វះលុយបង់ឲ្យពេទ្យ។ កញ្ញាមានស្រុកកំណើតនៅភ្នំពេញ ប៉ុន្តែបានទៅរស់នៅនិងធ្វើការក្នុងប្រទេសថៃ ជាង២ឆ្នាំហើយ ។ កញ្ញាធ្លាប់សម្តែងភាពយន្តនៅប្រទេសថៃ និងប្រទេសភូមា ហើយក៏ធ្លាប់ធ្វើការងារមនុស្សធម៌ជួយពលរដ្ឋខ្មែរដែលរងគ្រោះដោយការរាតត្បាតជំងឺកូវីដ-១៩ ដោយដើរចែកពូជមាន់ចិញ្ចឹមដល់ពលរដ្ឋខ្មែរនៅតាមទីជនបទ។

ជុំវិញរឿងនេះដែរ មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស អង្គការសង់ត្រាល់ លោក លឹង សុផុន លើកឡើងថា ស្ថានទូតខ្មែរនៅថៃ ត្រូវតែចាត់វិធានការឲ្យម៉ឺងម៉ាត់ ដើម្បីរកយុត្តិធម៌ដល់ស្ត្រីខ្មែររងគ្រោះ។ លោកបន្ថែមថា ជនបរទេសដែលវាយដំលើរាងកាយលើពលរដ្ឋខ្មែរ មិនថា ពួកគេជាជនជាតិអ្វីទេ គួរតែរដ្ឋាភិបាលខ្មែរសហការជាមួយអាជ្ញាធរថៃ ស៊ើបអង្កេតឲ្យបានច្បាស់លើករណីហិង្សានោះ។ លោក លឹង សុផុន៖ «ត្រូវតែ

តាមចាប់យកមកសួរចម្លើយឲ្យបានច្បាស់លាស់អ៊ីចឹងណា មិនមែនមានករណីអ៊ីចឹងៗកើតឡើងហើយ យើងមិនស្វែងយល់ យើងមិនស្វែងរក យើងមិនស៊ើបអង្កេតមើល ចាត់ទុកថាដូចជាមិនជួយមិនអីសោះក៏វាមិនកើតដែរ ព្រោះអីយើងជាជាតិសាសន៍មួយដែរ»។

កាសែតថៃ បានចុះផ្សាយថា ប៉ូលិសថៃ បានចេញលិខិតនៅថ្ងៃទី១០ ខែវិច្ឆិកា ដើម្បីតាមចាប់ខ្លួន បុរសជនជាតិប៉ូឡូញទាំង ២ នាក់ ម្នាក់ឈ្មោះ ដាញែល ម៉ាជូស្គី (DANIEL MAJEWSKI) និងម្នាក់ទៀតឈ្មោះ មេធីវ ផៀត គ្រីនិក (MATEUSZ PIOTR KRYNICK) ។ ជនល្មើសទាំងពីរនោះ គឺម្នាក់មានអាយុ ៣៥ និងម្នាក់ទៀតអាយុ៤០ ឆ្នាំ និងត្រូវបានអាជ្ញាធរថៃចោទប្រកាន់ពីបទរួមគំនិតធ្វើបាបជនដទៃដោយមានគម្រោងទុកជាមុន ហេតុធ្វើឱ្យជនរងគ្រោះរងរបួសធ្ងន់ស្ទើរបាត់បង់ជីវិត និងធ្វើទារុណកម្មលើរាងកាយដោយខុសច្បាប់។ កាសែតថៃ ផ្សាយថា បច្ចុប្បន្ននេះ ជនដៃដល់ទាំងពីរនាក់ បានរត់ចេញពីប្រទេសថៃ កាលពីថ្ងៃទី៣ ខែវិច្ឆិកា ក្រោយធ្វើទារុណកម្មលើស្ត្រីខ្មែរ ហើយពេលនេះ កំពុងទៅលាក់ខ្លួនក្នុងប្រទេសហ្វីលីពីន (Philippine) ៕

# ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០២២

## ពលករកម្ពុជានៅប្រើប្រព័ន្ធក្រៅផ្លូវការដើម្បីបានទៅធ្វើការនៅប្រទេសជិតខាង

https://khmer.voanews.com/a/cambodian-workers-still-use-informal-systems-to-go-to-work-in-neighboring-countries/6882506.html 19 ធ្នូ 2022ហ៊ុល រស្មី

ភ្នំពេញ៖ ពលករខ្មែរចំណាកស្រុកភាគច្រើនបានបោះបង់ចោលប្រព័ន្ធផ្លូវការនៅក្នុងការចេញទៅធ្វើការនៅប្រទេសជិតខាង ក្រោមហេតុផលនៃការចំណាយខ្ពស់ និងភាពស្មុគស្មាញនៃការរត់ឯកសារដែលបណ្តាលឲ្យពួកគេប្រឈមមុខនឹងការខាតបង់ដោយសារការកេងប្រវ័ញ្ច ឬត្រូវប្រឈមមុខនឹងវិបានការសន្តិសុខ។ នេះជាការវាយតម្លៃរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថាសង់ត្រាល់ (Central) ដែលបានបន្តផ្តួចផ្តើមប្រារព្ធទិវាពលករចំណាកស្រុកអន្តរជាតិ កាលពីថ្ងៃទី១៨ ខែធ្នូ កន្លងទៅ។

នៅក្នុងសេចក្តីថ្លែងការណ៍មួយចេញផ្សាយកាលពីថ្ងៃអាទិត្យ អង្គការសង់ត្រាល់ បានយោងតាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានបង្ហាញថា ពលករកម្ពុជាចំនួន១លាន៣សែននាក់កំពុងបម្រើការងារក្នុងប្រទេសគោលដៅ រួមមានប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ជប៉ុន កូរ៉េខាងត្បូង គុយវ៉ែត រដ្ឋបាលពិសេសហុងកុង ហ្កាតា អារ៉ាប៊ីសាអូឌីត និងប្រទេសជាច្រើនទៀតដែលមាន និងមិនមានកិច្ចព្រមព្រៀងផ្លូវការ ហើយដែលមិនបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងទាំងស្រុងនៃចំនួនពលករចំណាកស្រុកកម្ពុជាដែលកំពុងធ្វើការនៅក្រៅប្រទេស។ បើតាមអង្គការសង់ត្រាល់ ពលករកម្ពុជាចំនួនច្រើនបានធ្វើចំណាកស្រុកតាមប្រព័ន្ធមិនផ្លូវការ។ តាមការប៉ាន់ប្រមាណរបស់អង្គការសង់ត្រាល់ គ្រាន់តែក្នុងប្រទេសថៃមានពលករចំណាកស្រុកកម្ពុជាប្រមាណ២លាននាក់កំពុងបម្រើការនៅទីនោះ ដែលភាគច្រើនធ្វើការក្នុងវិស័យសំណង់ កសិកម្ម នេសាទ ការងារតាមផ្ទះ និងវិស័យក្រៅប្រព័ន្ធផ្សេងៗទៀត។ ក្នុងនោះ មានពលករប្រមាណតែ១៥ម៉ឺននាក់ប៉ុណ្ណោះ ដែលធ្វើចំណាកស្រុកតាមរយៈប្រព័ន្ធផ្លូវការ MOU (ឬអនុស្សរណៈនៃការយោគយល់គ្នា) ទៅបំពេញការងារក្នុងវិស័យដូចជា ចំណីអាហារ កែច្នៃអាហារសមុទ្រ និងរោងចក្រអគ្គិសនីជាដើម។

តាមការចេញទៅធ្វើការនៅក្រៅប្រទេសតាមប្រព័ន្ធមិនផ្លូវការនេះ ពលករត្រូវប្រឈមមុខនឹងបញ្ហាមួយចំនួនដូចជា ក្នុងឆ្នាំ២០២២នេះ អង្គការសង់ត្រាល់បានកត់ត្រាករណីពលករចំណាកស្រុកកម្ពុជាត្រូវបានឃាត់ខ្លួន

ដោយអាជ្ញាធរថៃនៅតាមព្រំដែន ស្របពេលពួកគេឆ្លងដែនទៅរកការងារធ្វើ ដោយមិនមានឯកសារស្របច្បាប់ចំនួន ៩២ករណី ដែលមានពលរដ្ឋកម្ពុជាចំនួន២.១២១នាក់ក្នុងនោះច្រើនជាង៤០ភាគរយជាស្ត្រី និងកុមារតូចៗ។ សេចក្តីថ្លែងការណ៍របស់អង្គការសង់ត្រាល់បានលើកឡើងក្នុងន័យដើមថា៖ «ដំណើរការនៃការធ្វើចំណាកស្រុកតាមប្រព័ន្ធផ្លូវការ MOU មានបញ្ហាប្រឈមមួយចំនួនដែលនាំឲ្យពលករមិនអាច និងពិបាកដំណើរការទៅបាន រួមមានត្រូវចំណាយពេលវេលារង់ចាំយូរ នីតិវិធីស្មុគស្មាញ និងតម្លៃខ្ពស់លើសលប់ និងមិនបានកំណត់ច្បាស់លាស់»។ សេចក្តីថ្លែងការណ៍បន្ថែមថា៖ «តាមរយៈការសិក្សាដដែល និងការផ្តល់ព័ត៌មានត្រឡប់ពីអ្នកប្រឹក្សាយោបល់សុវត្ថិភាពចំណាកស្រុក ដែលបានសម្ភាសផ្ទាល់ជាមួយអតីតពលករ បានបញ្ជាក់ថា ពលករម្នាក់ត្រូវចំណាយប្រាក់ចន្លោះពី៣០០ដុល្លារ ទៅ៦៥០ដុល្លារ និងពេលវេលារង់ចាំចន្លោះពី១ខែ ទៅ៦ខែ»។

ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់លោក ឌី ថេហូយ៉ា ប្រាប់វីអូអេនៅថ្ងៃចន្ទនេះថា ពលករត្រូវចំណាយពេលជាង៤០ថ្ងៃ ឬច្រើនជាងនេះ ប្រសិនបើត្រូវទៅតាមលក្ខខណ្ឌស្របច្បាប់ ព្រោះក្រុមហ៊ុនជ្រើសរើសពលករត្រូវប្រើពេលដើម្បីប្រមូលកម្លាំងពលកម្មសរុបសម្រាប់ការបញ្ជូនចេញ។ លោកថ្លែងថា៖ «ការអនុវត្ត គាត់អាចរហូតទៅដល់៩០ថ្ងៃ ៣ខែ ឬ៦ខែ អ៊ីចឹង គាត់ត្រូវរង់ចាំ ឧទាហរណ៍ថា គាត់ទៅដាក់ពាក្យតាមក្រុមហ៊ុនកហ្នឹង ទម្រាំតែប្រមែប្រមូលមនុស្សបាន ឬទម្រាំតែបានបញ្ជូនទៅ អ្នកខ្លះមិនទាន់មានតម្រូវការពីប្រទេសគោលដៅផង ប៉ុន្តែចេះតែជ្រើសរើសគាត់អ៊ីចឹងទៅ។ ដល់ពេលជ្រើសរើសបាន គាត់ដាក់ពាក្យហើយខ្ចីគេលុយគេ ហើយបង់ថ្លៃអស់ហើយ គាត់ត្រូវរង់ចាំយូរ ៣ខែ៦ខែ។ បើសិនជាគាត់ខ្ចីគេ ៦០០ ឬ ៧០០ ដុល្លារ ហើយដេកបង់ការប្រាក់ពី១ខែទៅ៦ខែ... ហ្នឹង វាមានបញ្ហាកន្លែងហ្នឹង»។

បើតាមលោកឌី ថេហូយ៉ា រដ្ឋាភិបាលគួរតែសហការជាមួយប្រទេសគោលដៅក្នុងការរៀបចំបង្កើតឲ្យមានច្រកចេញចូលតែមួយសម្រាប់ការធ្វើឯកសារនានាៗដូចធ្លាប់បានរៀបចំធ្វើក្នុងខេត្តរ៉ាក់យ៉ងប្រទេសថៃ ហើយការធ្វើឯកសារដើម្បីបានទៅធ្វើការដោយស្របច្បាប់នៅប្រទេសថៃ ឬគោលដៅផ្សេងទៀតស្របតាមអនុស្សរណៈយោគយល់គ្នា មិនគួរលើសពីមួយខែទេ ដើម្បីសម្រួលបន្ទុកខាងសង្គមនិ ងសេដ្ឋកិច្ចដល់ពលករដែលចង់ចេញទៅធ្វើការនៅក្រៅប្រទេស ឬពលករដែលមានឯកសារពាក់ព័ន្ធការងារដែលមាននៅក្រៅប្រទេសរួចស្រេចហើយ តែផុតសុពលភាព។ ពលករដែលចំណាកស្រុកដោយមិនមានឯកសារស្របច្បាប់បានជួបស្ថានភាពលំបាកគួរឲ្យកត់សម្គាល់។ ពួកគេត្រូវប្រឈមនឹងការរស់នៅ និងធ្វើការដោយមិនមានភាពស្របច្បាប់ មានការភ័យខ្លាចអាជ្ញាធរចាប់ខ្លួន ចំណាយច្រើន ឬត្រូវកាត់កងប្រាក់ឈ្នួលដើម្បីឲ្យមេខ្យល់ ឬថៅកែរត់ការឯកសារឲ្យ ការងារមិនឋិតថេរជាប់លាប់ មិនទទួលបានការការពារសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗតាមច្បាប់ការងារ ជាពិសេសកិច្ចគាំពារសង្គម និងងាយធ្លាក់ក្នុងស្ថានភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស។ នេះបើតាមអង្គការសង់ត្រាល់។

អង្គការសង់ត្រាល់ឲ្យដឹងទៀតថា នៅប្រទេសគោលដៅឯណោះវិញ ពលករចំណាកស្រុកដែលមានឯកសារត្រឹមត្រូវអាចប្រឈមនឹងការបាត់បង់ភាពស្របច្បាប់របស់ខ្លួននៅពេលហួសសុពលភាព ហើយនីតិវិធីនៃការបន្តឯកសារអាចមានភាពស្មុគស្មាញ ចំណាយខ្ពស់ និងអាចចាញ់បោកគេ។ ក្រៅពីបញ្ហានេះ ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់លោក ឌី ថេហូយ៉ា កត់សម្គាល់ទៀតថា ពលករចំណាកស្រុកកម្ពុជាមានបញ្ហាប្រឈមចម្បងមួយទៀត គឺលទ្ធភាពទទួលបានកិច្ចគាំពារសង្គមនៅក្នុងប្រទេសកំណើត និងប្រទេសគោលដៅដែលនៅមានកម្រិត។ លោកថ្លែងថា៖ «តម្រូវការអាទិភាពទីមួយ គឺទទួលបានឯកសារស្របច្បាប់។ តម្រូវការទីពីរគឺកិច្ចគាំពារសង្គមហ្នឹង។ ហើយសំណួរសួរថា បើសិនជាគាត់អត់ទទួលបានឯកសារស្របច្បាប់ តើគាត់មានប្រឈមអីខ្លះ? ហ្នឹងគឺថា គាត់នឹងប្រឈមទីមួយ គាត់នឹងក្លាយជាជនដែលងាយរងគ្រោះអំពីអំពើជួញដូរកម្លាំងពលកម្ម និងការជួញដូរមនុស្ស ក៏ដូចជារូបភាពនៃអំពើរំលោភបំពានផ្សេងៗ»។

នៅត្រង់ចំណុចកិច្ចគាំពារសង្គមនេះ សេចក្តីថ្លែងការណ៍ខាងលើរបស់អង្គការសង់ត្រាល់បានបង្ហាញថា ច្បាប់ការងារ និងច្បាប់ស្តីពីកិច្ចគាំពារសង្គមក្នុងប្រទេសគោលដៅមិនបានដាក់បញ្ចូលពលករចំណាកស្រុកគ្រប់វិស័យឱ្យទទួលបានអត្ថប្រយោជន៍ និងកិច្ចគាំពារសង្គមបានពេញលេញនៅឡើយ ព្រោះហេតុផលសញ្ជាតិ ស្ថានភាពនៃការចំណាកស្រុក ប្រភេទការងារ និងដោយសារការរើសអើងជាដើម បើទោះបីពួកគេមួយចំនួនធំបានបង់វិភាគទាន៥ភាគរយនៃប្រាក់ឈ្នួល ចូលក្នុងមូលនិធិធានារ៉ាប់រងសង្គមក៏ដោយ។ អង្គការសង់ត្រាល់ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលផ្សេងទៀត បានលើកឡើងអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាល ក្នុងនោះ គឺការបង្កើតការងារ និងមុខរបរក្នុងស្រុកឲ្យបានគ្រប់គ្រាន់ និងបង្កើតយន្តការត្រួតពិនិត្យ តាមដានចំពោះការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសពលករ ដើម្បីធានានូវការអនុវត្តប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ ទៅលើដំណើរការនៃការជ្រើសរើស និងបញ្ជូនពលករប្រកបដោយក្រមសីលធម៌ ហើយរដ្ឋត្រូវពង្រីកវិសាលភាពនៃការផ្តល់ជូនកិច្ចគាំពារសង្គមដល់ពលករចំណាកស្រុកតាមរយៈកិច្ចព្រមព្រៀងជាមួយប្រទេសទទួលនានា។

វីអូអេបានព្យាយាមសុំការអត្ថាធិប្បាយពីអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ តែគ្មានការឆ្លើយតបសំណួរផ្ញើតាមប្រព័ន្ធទំនាក់ទំនងតេឡេក្រាម។

គួរបញ្ជាក់ថា នៅខែធ្នូ ឆ្នាំ២០០០ មហាសន្និបាតនៃអង្គការសហប្រជាជាតិ បានកំណត់យកថ្ងៃទី១៨ខែធ្នូជារៀងរាល់ឆ្នាំ ដើម្បីប្រារព្ធទិវាពលករចំណាកស្រុកអន្តរជាតិ។ ការកំណត់យកថ្ងៃ១៨ធ្នូនោះ គឺក្រោមហេតុផលថា នាថ្ងៃនោះក្នុងឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានសម្រេចអនុម័តអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ។

នៅកម្ពុជា អង្គការសង់ត្រាល់បានប្រារព្ធទិវានេះម្តងទៀតនៅឆ្នាំ២០២២នេះ ដោយមានកិច្ចសហការពីសំណាក់អាជ្ញាធរមូលដ្ឋានៅក្នុងខេត្តគោលដៅចំនួន៤គឺខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ និងបាត់ដំបង ដោយមានអ្នកចូលរួម៩៣២នាក់ តិចជាង១០៣០នាក់ កាលពីឆ្នាំទៅ ដែលអង្គការសង់ត្រាល់បានធ្វើនៅប្រទេសកម្ពុជា ថៃ និងជប៉ុន៕

## ក្នុងឆ្នាំ២០២២នេះមានពលករខ្មែរចំណាកស្រុកដោយចាញ់បោកមេខ្យល់ជាង៩០ករណី

https://www.khmertimeskh.com/501205527// December 20, 2022

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (សង់ត្រាល់) បានកត់ត្រាថា ក្នុងឆ្នាំ២០២២ មានករណីពលករខ្មែរចំណាកស្រុកចាញ់បោកមេខ្យល់ជាង៩០ករណី ដែលមានពលករប្រមាណជាងពីរពាន់នាក់ ហើយក្នុងនោះច្រើនជាង៤០ភាគរយជាស្ត្រីនិងកុមារ។

លោក ឌី ថេហូយ៉ា ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្សនិងទេសន្តរប្រវេសន៍នៃអង្គការសង់ត្រាល់ បានប្រាប់ខ្មែរថាមស៍ពីម្សិលមិញថា ទាំងជាង៩០ករណី ដែលពលករខ្មែរត្រូវបានអាជ្ញាធរថៃចាប់ខ្លួន និងខ្លះទៀតបានចាញ់បោកមេខ្យល់អស់ប្រាក់ចន្លោះពី២០០ទៅ៥០០ដុល្លារអាមេរិកក្នុងមួយម្នាក់។ លោកបញ្ជាក់ថា មានបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យពលករខ្មែរមិនអាចធ្វើចំណាកស្រុកដោយស្របច្បាប់ ជាពិសេសការធ្វើចំណាកស្រុកតាមប្រព័ន្ធផ្លូវការ MoU ដោយសារតែមានបញ្ហានីតិវិធីស្មុគស្មាញ ចំណាយពេលយូរ និងមានតម្លៃខ្ពស់សម្រាប់ពួកគេ គឺក្នុងមួយម្នាក់ត្រូវចំណាយប្រាក់ចន្លោះពី៣០០ ទៅ ៦៥០ដុល្លារអាមេរិក ហើយត្រូវរង់ចាំចន្លោះពីមួយខែទៅប្រាំមួយខែ។ តាមការប៉ាន់ប្រមាណរបស់អង្គការសង់ត្រាល់ ពលករចំណាកស្រុកចូលក្នុងប្រទេសថៃមានប្រមាណ២លាននាក់ ដែលកំពុងបម្រើការក្នុងវិស័យសំណង់ កសិកម្ម នេសាទ ឧស្សាហកម្មចំណីអាហា រោងចក្រអេឡិចត្រូ

និក និងការងារតាមផ្ទះជាដើម ដោយក្នុងនោះមានពលករប្រមាណតែ១៥ម៉ឺននាក់ប៉ុណ្ណោះ ដែលចំណាកស្រុកតាមប្រព័ន្ធផ្លូវការ MoU។

លោកបន្តថា ពលករខ្មែរមួយចំនួនប្រឈមនឹងការចាប់ខ្លួនពីសំណាកអាជ្ញាធរថៃ ដោយសារតែការធ្វើដំណើររកការងារធ្វើអំឡុងពេលរឹតត្បិតការធ្វើដំណើរដោយសារតែការឆ្លងជំងឺកូវីដ-១៩។ ពលករខ្មែរទាំងនោះ បានប្រឈមនឹងភាពគ្មានការងារ និងជំពាក់បំណុល ហើយពលករខ្លះទៀត ក៏ប្រឈមនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបទល្មើសជួញដូរមនុស្សជាដើម។ លោកបន្ថែមថា៖ «អ្នកចំណាកស្រុកដោយមិនស្របច្បាប់ត្រូវប្រឈមនឹងការរស់នៅ មានការភ័យខ្លាចអាជ្ញាធរចាប់ឃាត់ខ្លួន មានការចំណាយច្រើនឬត្រូវកាត់កងប្រាក់ឈ្នួល ដើម្បីឱ្យមេខ្យល់ មិនទទួលបានសិទ្ធិការពារ និងងាយធ្លាក់ក្នុងស្ថានភាពរងគ្រោះនៃអំពើជួញដូរមនុស្ស»។ លោកបន្ថែមទៀតថា៖ « ចំណែកពលករចំណាកស្រុក ដែលមានឯកសារត្រឹមត្រូវអាចប្រឈមនឹងការបាត់បង់ភាពស្របច្បាប់នៅពេលហួសសុពលភាព ហើយនីតិវិធីបន្តឯកសារអាចមានភាពស្មុគស្មាញ ចំណាយខ្ពស់ និងអាចចាញ់បោកគេ ដូចជាករណីពលរដ្ឋចាញ់បោកមេការឬអ្នករត់ការ និងថៅកែធ្វើឯកសារក្លែងក្លាយ ដែលធ្វើឱ្យពួកគេប្រឈមជាប់ពន្ធនាគារ និងបាត់បង់ប្រាក់»។

ខ្មែរថៃមស៍មិនអាចសុំការបញ្ជាក់ពីលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានទេពីម្សិលមិញ។

យោងតាមរបាយការណ៍ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញថាកម្ពុជាមានពលករចំណាកស្រុកជាង១,៣លាននាក់ បានចំណាកស្រុកទៅរកការងារធ្វើនៅឯក្រៅប្រទេស ដើម្បីរកចំណូលមកផ្គត់ផ្គង់គ្រួសារនៅក្នុងស្រុក។ ប៉ុន្តែអង្គការសង់ត្រាល់និយាយថា តួលេខនេះមិនឆ្លុះបញ្ចាំងពីភាពជាក់ស្តែងទាំងស្រុងនៃចំនួនពលករចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសឡើយ។ ជាមួយគ្នានេះ អង្គការជំរុញឱ្យរដ្ឋាភិបាលពន្លឿននីតិវិធីផ្តល់ភាពស្របច្បាប់ដល់ពលករតាមប្រព័ន្ធផ្លូវការ MoU ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដោយកំណត់តម្លៃសមរម្យក្នុងការធ្វើឯកសារ ត្រូវចំណាយរយៈពេលខ្លី និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ មួយទៀត គឺរដ្ឋាភិបាលនៅតែអាចសហការជាមួយរដ្ឋាភិបាលថៃធ្វើឯកសារតាមច្រកចេញចូលតែមួយ ដើម្បីផ្តល់ភាពងាយស្រួលដល់ពលករបន្តសុពលភាពឯកសារស្របច្បាប់៕

## អភិបាលខេត្តកំពង់ចាម ព្រមានមិនលើកលែង ចំពោះជនទាំងឡាយណា ជាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស

https://dap-news.com/national/2022/12/20/300473/ ByKD102Posted on December 20, 2022

**កំពង់ចាម៖ លោក អ៊ុន ចាន់ដាអភិបាលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងសារព្រមានមិនលើកលែងឡើយ ចំពោះជនទាំងឡាយណា ដែលជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។** លោក អ៊ុន ចាន់ដា បានថ្លែងព្រមានដូច្នេះ នៅព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ខណៈពេលអញ្ជើញ ជាអធិបតីក្នុងពិធីទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី១៦ ឆ្នាំ២០២២ នៅស្រុកស្ទឹងត្រង់ ។ លោកអភិបាលខេត្ត បានឲ្យដឹងថា កាលពីមុន អំពើជួញដូរមនុស្ស ត្រូវបានជនល្មើសនាំយក ទៅប្រព្រឹត្តនៅប្រទេសទី ២ ឬប្រទេសទី ៣ ប៉ុន្តែបច្ចុប្បន្ននេះ ពីសំណាក់ជនបរទេស បានយកប្រទេសកម្ពុជា យើងធ្វើជាកន្លែងប្រព្រឹត្តបទល្មើស ជួញដូរមនុស្សទៅវិញ តាមរយៈការងារ។

លោកអភិបាលខេត្ត បានបញ្ជាក់ថា អ្នកជាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មានដូចជា មេខ្យល់នេះ អ្នកនៅពីក្រោយនេះ និងអ្នកអន្តរាគមន៍ក្នុងរឿងនេះ គឺជាឧក្រិដ្ឋជន។ ដូច្នេះហើយទើបយើងជួបជុំគ្នាប្រារព្ធទិវាក្នុងថ្ងៃនេះ ដើម្បីប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ ធ្នូ គឺក្នុងគោលបំណង ឱ្យមានការចូលរួម ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងអាជ្ញាធរមានសមត្ថកិច្ច លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ និងអង្គការ ជា

ដៃគូនានា ដែលធ្វើកិច្ចការប្រឆាំងអំពើជួញដូរមនុស្ស ធ្វើយ៉ាងណាឱ្យមានការចូលរួម ដើម្បីលុបបំបាត់ឲ្យអស់ នូវអំពើអសកម្មទាំងនេះ ត្រូវគប្បី ត្រូវតែយល់ដឹង អំពីទម្រង់ យល់អំពីរូបភាព និងសកម្មភាព នៃបទល្មើសនេះ ដើម្បីរកវិធានការដើម្បីការពារកុំឱ្យបទល្មើសនេះ កើតមានឡើង ដែលធ្វើឲ្យប៉ះពាល់ដល់សង្គមជាតិរបស់យើង ។

លោកអភិបាលខេត្ត បានថ្លែងទៀតថា វិធីការពារបទល្មើសករណីជួញដូរមនុស្សនេះ ត្រូវចាប់ផ្តើមពីបុគ្គលម្នាក់ ៗ ទៅគ្រួសារមួយ និងទៅសហគមន៍មួយ ពីសហគមន៍ទៅភូមិមួយ ពីភូមិទៅឃុំ ដល់ស្រុក និងខេត្ត ។ ម្យ៉ាងទៀត បច្ចុប្បន្នរដ្ឋាភិបាល បាន បង្កើតយន្តការស្វែងរកការងារនៅក្រៅប្រទេស ដោយមានក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងនីតិសម្បទា ក្នុងការទំនាក់ទំនងរកការងារឲ្យពលរដ្ឋ ធ្វើនៅក្រៅប្រទេសដោយស្របច្បាប់ និងត្រឡប់មកវិញទទួលបាន ប្រាក់ចំណូលយកមកផ្គត់ផ្គង់គ្រួសារ ដោយពិតប្រាកដ ។ បើប្រជាពលរដ្ឋនៅតាមខេត្តត្រូវចូលទៅទំនាក់ទំនងជាមួយនឹងមន្ទីរការងារ និងសូមកុំទុកចិត្តមេខ្យល់ ។ លោក អ៊ុន ចាន់ដា បានយកឱកាសនោះសូមអំពាវនាវដល់ ក្មួយៗសិស្សានុសិស្សនិងលោកគ្រូ អ្នកគ្រូ ពិសេសកងកម្លាំងប្រដាប់អាវុធនៅមូលដ្ឋាន សូមចូលរួមឲ្យបានសកម្មថែមទៀតដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស តាមគ្រប់ទម្រង់ និងគ្រប់រូបភាព៕

## ពលករចំណាកស្រុក ជាអំណាចសេដ្ឋកិច្ចពិភពលោកលំដាប់ទីបី

https://www.rfi.fr/km//20221219-?ref=tgi ចុះផ្សាយនៅថ្ងៃ៖ 19/12/2022 - 16:53

បើសរុបចូលគ្នាទូទាំងពិភពលោក ពលករអន្តោប្រវេសន៍ គឺជាមហាអំណាចសេដ្ឋកិច្ចពិភពលោកលំដាប់លេខបី នៅពីក្រោយសហរដ្ឋអាមេរិក (លេខមួយ) និងចិន។ នេះបើតាមការសិក្សារបស់វិទ្យាស្ថាន BCG Henderson Institute នៃមជ្ឈមណ្ឌលសិក្សាវិភាគBoston consulting Group ដែលចេញផ្សាយជារបាយការណ៍នៅថ្ងៃចន្ទទី ១៩ធ្នូនេះ ដោយសហការជាមួយអង្គការសហប្រជាជាតិ។ នៅលើភពផែនដីបច្ចុប្បន្ននេះ មានមនុស្ស ២៨០លាននាក់ដែលគេចាត់ទុកជាពលករចំណាកស្រុក។ ប្រសិនបើពលករអន្តោប្រវេសន៍ទាំងអស់នេះ រស់នៅផ្តុំជុំគ្នាក្នុងតែប្រទេសមួយ ប្រទេសពលករចំណាកស្រុកនោះ នឹងក្លាយជាប្រទេសទីបួនដែលមានប្រជាជនច្រើនជាងគេនៅលើពិភពលោក។

ការសិក្សារបស់វិទ្យាស្ថាន BCG Henderson Institute ដែលមានផ្តល់ជាតួលេខច្បាស់ៗ បានជម្រះមន្ទិលនិងគំនិតមិនល្អចំពោះអន្តោប្រវេសន៍ទៀត។ ផ្ទុយពីការគិត ពលករចំណាកស្រុក គឺជាកម្លាំងសេដ្ឋកិច្ច។ ជារៀងរាល់ឆ្នាំ ការងាររបស់ពលករចំណាកស្រុក បង្កើតចំនួលបានសរុបប្រមាណ ៩ទ្រីលានដុល្លារ (៩០០០លានដុល្លារ)។ បើសរុបបញ្ចូលគ្នា គិតជាប្រទេសតែមួយវិញ នោះចំណូលសរុបរបស់ពួកគេ នឹងមានកំរិតជាមហាអំណាចសេដ្ឋកិច្ចលំដាប់ទីបីនៅលើពិភពលោក នៅពីក្រោយអាមេរិកនិងចិន។ នេះគេនៅមិនទាន់រាប់បញ្ចូលអំពី ឥទ្ធិពលសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋចំណាកស្រុក នៅក្នុងការចាយវាយ ការធ្វើទំនើបកម្ម ឬសកម្មភាពបង្កើត-បង្កើនសហគ្រាសក្រុមហ៊ុនផង។

នាពេលអនាគត តួនាទីរបស់ពលករអន្តោប្រវេសន៍នឹងកើនឡើងជាលំដាប់។ នេះបើតាមវិទ្យាស្ថានដដែល។ សេដ្ឋកិច្ចពិភពលោកដែលកំពុងប្រឈមនឹងកង្វះកម្លាំងពលកម្មយ៉ាងខ្លាំងក្លានោះ ទំនងជាត្រូវការពលករប្រមាណជាង៣០លាននាក់ សម្រាប់មកបម្រើការនៅក្នុងវិស័យឧស្សាហកម្មសិប្បកម្ម វិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា វិស័យទូរគមនាគមន៍ ឬក្នុងវិស័យសុខាភិបាល។ ប្រធានក្រុមហ៊ុនសហគ្រាស ចំនួន៧២% ចាត់ទុកពលករចំណាកស្រុកថាជាទ្រព្យសកម្មពិតៗ ជាពិសេសបើនិយាយអំពីផ្នែកទំនើបកម្ម។ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋទូទៅវិញ ភាគច្រើនមិនផ្តល់តម្លៃរបស់អន្តោប្រវេសន៍ទេ។មានតែ៤០%ប៉ុណ្ណោះដែលយល់ស្របតាមគំនិតរបស់ប្រធានក្រុមហ៊ុនសហគ្រាស៕

# រដ្ឋបាលខេត្តត្បូងឃ្មុំ បើកវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ (PSEA)

https://www.information.gov.kh/articles/94094 ចេញផ្សាយ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០២២

(ត្បូងឃ្មុំ) ៖ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០២២ នេះ លោកជំទាវ ខៀវ សាមួន សមាជិកក្រុមប្រឹក្សាខេត្ត និងជាប្រធានកិត្តិយសក្រុមការងារពហុវិស័យឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ខេត្តត្បូងឃ្មុំ បានអញ្ជើញជាអធិបតី ក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការបង្ការ ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ(PSEA) នៅសាលប្រជុំ ខ សាលាខេត្តត្បូងឃ្មុំ ។ ដោយមានការអញ្ជើញចូលរួម ពីសំណាក់អាជ្ញាធរក្រុង/ស្រុក ទាំង ៧ មន្ទីរ/អង្គភាពជុំវិញខេត្ត តំណាងអង្គការជាដៃគូ មន្ត្រីសម្រមសម្រួលនៃមន្ទីរកិច្ចការនារីខេត្ត ក្រុមស្ត្រីជួយខ្លួនឯង និងអ្នកពាក់ព័ន្ធជាច្រើនរូប។

លោកស្រី កង ស៊ីម៉ែន អនុប្រធានមន្ទីរកិច្ចការនារីខេត្ត បានធ្វើបទបង្ហាញឧទ្ទេស នៅផែនការសកម្មភាពជាតិ និងច្បាប់ពាក់ព័ន្ធ ដើម្បីឆ្លើយតបនឹងការបង្ការ ការរំលោភបំពាន នឹងកេងប្រវ័ញផ្លូវភេទ និងលោកគ្រូ រចនា គ្រូឧទ្ទេស អំពីការ ស្វែងយល់អំពីការបៀតបៀនផ្លូវភេទ និងការបង្ការ ការរំលោភបំពាន នឹងកេងប្រវ័ញផ្លូវភេទ និងបានធ្វើតេស្តសិក្ខាកាម ក្រោយបញ្ចប់វគ្គ ផងដែរ។

ថ្លែងនាឱកាសនោះ លោកជំទាវ ខៀវ សាមួន បានមានប្រសាសន៏ថា ការបៀតបៀនផ្លូវភេទ និង ការរំលោភផ្លូវភេទ មានលក្ខណៈខុសគ្នាបន្តិចបន្តួច ហើយក៏មិនមានច្បាប់ណាមួយដែលបានចែងច្បាស់លាស់ជុំវិញនឹងបញ្ហានេះ ហើយក៏មិនមែនសុទ្ធតែជាករណីដែលកើតឡើងចំពោះតែស្ត្រី និង ក្មេងស្រីងាយរងគ្រោះនោះទេ ដោយការសិក្សាថ្មីបានរកឃើញបញ្ហាទាំងនេះ ក៏បានកើតឡើងលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ ប៉ុន្តែនៅមិនទាន់ដឹងច្បាស់ថាមានលក្ខណៈស៊ីជម្រៅប៉ុនណានោះទេ។ លោកជំទាវ បន្តថា ទង្វើនៃការបៀតបៀន និងការរំលោភផ្លូវភេទត្រូវបានគេយល់ថា ជាអំពើដែលគេមិនពេញចិត្ត ព្រោះវាធ្វើឱ្យមានការឈឺចាប់ ការគំរាមកំហែង ឬការរំខាន។ ការបៀតបៀនមានច្រើនប្រភេទ និងច្រើនទម្រង់ដែលទាក់ទងនឹងផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ នេះគ្រាន់តែជាឧទាហរណ៍មួយចំនួនតែប៉ុណ្ណោះ។

បន្ថែមលើនេះដើម្បីអន្តរាគមន៍ និងផ្តល់ការគាំទ្រ ដើម្បីលុបបំបាត់ ទប់ស្កាត់ការបៀតបៀន និងការរំលោភបំពាន យើងត្រូវជានាថា មិនត្រូវធ្វើឱ្យស្ថានភាពរបស់ជនរងគ្រោះកាន់តែដុនដាបនោះទេ។ រាល់សកម្មភាពត្រូវតែមានគម្រោង និងមានការថ្លឹងថ្លែងឱ្យបានច្បាស់លាស់ ដូចនេះវាមិនធ្វើឱ្យមានការឈឺចាប់ ការអាម៉ាស់ ឬមានការខូចខាចកាន់តែខ្លាំង ជាពិសេសក្រុមប្តូរយេនឌ័រ។ លោកជំទាវ ខៀវ សាមួន ក៏បានកោតសរសើ និង វាយតម្លៃខ្ពស់ចំពោះសិក្ខាន និង ភាគីពាក់ព័ន្ធទាំងអស់ បន្ទាប់ទទួលបានជាតុចូល ពីវគ្គបណ្តុះបណ្តាលនេះ ត្រូវកំណត់និយមន័យ និងទម្រង់ផ្សេងៗ នៃការបៀតបៀនផ្លូវភេទ និងមានការស្វែងយល់បានប្រសើរជាមុន អំពីអត្ថន័យនិងសារៈសំខាន់ និងការស្វែងយល់អោយកាន់ប្រសើរជាងមុន និងដៃគូអនុវត្តនានា ចំពោះការចូលរួមបង្ការ ទប់ស្កាត់នូវការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ នៅតាមបណ្តាមូលដ្ឋានទទួលបានប្រសិទ្ធភាព ៕

# ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២២

## ជាតិថៃ៧នាក់ចាញ់បោកមេខ្យល់ ត្រូវនគរបាលអន្តោប្រវេសន៍កម្ពុជាប្រគល់អោយនគរបាលអន្តោប្រវេសន៍ថៃ

https://www.kampucheathmey.com/security/434298 ថ្ងៃអង្គារ ២០ ធ្នូ ២០២២ដោយ Kang Tola

ប៉ោយប៉ែត ៖ ជនជាតិថៃចំនួន៧រូបចាញ់បោកមេខ្យល់យកមកធ្វើការនៅកម្ពុជាត្រូវបានលោកវរសេនីយ៍ឯក ជួន សារី តំណាងលោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតធ្វើការប្រគល់អោយទៅនគរបាលអន្តោប្រវេសន៍ថៃកាលពីវេលាម៉ោង៧ល្ងាច ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២តាមច្រកអន្តរជាតិប៉ោយប៉ែត។

លោកវរសេនីយ៍ឯក ជួន សារី តំណាងលោកឧត្តមសេនីយ៍ត្រី អ៊ី ចំរើន នាយប៉ុស្តិ៍នគរបាលច្រកអន្តរជាតិប៉ោយប៉ែត បានអោយដឹងថា ជនជាតិថៃទាំង៧នាក់មានស្រី៥នាក់ ដែលត្រូវបានចាញ់បោកមេខ្យល់នាំយកមកធ្វើការនៅប្រទេសកម្ពុជា បានប្រគល់ជូនទៅលោកវរសេនីយ៍ឯក រុង ថងមន្ត (ROONG THONGMON) នាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ថៃប្រចាំខេត្តស្រះកែវ។ ការប្រគល់ជនជាតិថៃទាំង៧នាក់ខាងលើធ្វើឡើងបន្ទាប់ពីស្ថានទូតនៃព្រះរាជាណាចក្រថៃប្រចាំកម្ពុជា បានចេញកំណត់ទូតជូនជនជាតិថៃទាំង៧រូបនោះ អោយវិលត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ។

សូមបញ្ជាក់ថា ជាបន្តបន្ទាប់ជនជាតិថៃជាច្រើននាក់តែងចាញ់បោកមេខ្យល់មកធ្វើការខុសច្បាប់នៅកម្ពុជា ហើយក៏ត្រូវបានរកឃើញឃាត់បញ្ជូនទៅថៃវិញតាមច្រកអន្តរជាតិប៉ោយប៉ែត៕ *ដោយ ៖ អ ពៅ*

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣៧នាក់

http://freshnewsasia.com/index.php/en/localnews/270693-2022-12-20-13-32-14.html 2022-12-20 08:32pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៦៦ករណី មានមនុស្ស ១,៦៣៤នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤២០សំណើ និងបិទសំណុំរឿង ២១៤សំណើ (រកឃើញមនុស្ស ៩៩៧នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣២ករណី។

សូមបញ្ជាក់ថា សម្តេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្តល់

ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមាន ដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## លោក អ៊ុន ចាន់ដា ៖ យើងរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព

http://nokorwatnews.com/archives/943787 21/12/2022

ខេត្តកំពង់ចាម៖ នៅព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ លោក អ៊ុន ចាន់ដា អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ចាម បានអញ្ជើញជាអធិបតីក្នុងពិធី«ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី១៦ ឆ្នាំ២០២២ នៅវិទ្យាល័យសម្ដេចតេជោហ៊ុន សែន ស្ទឹងត្រង់ ស្ថិតក្នុងភូមិ បឹងដែង ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

កម្មវិធីនេះមានការចូលរួមក្នុងពីសំណាក់លោកប្រធានសាលាដំបូងខេត្ត លោក សុជា ពិសិដ្ឋ ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្ត អស់លោកលោកស្រីជាអភិបាលរងខេត្ត ប្រធានមន្ទីរអង្គភាពជុំវិញ និងជាសមាជិក គណៈកម្មាធិការខេត្តប្រយុទ្ធនឹងការជួញដូរមនុស្ស លោកយាយ លោកតា បងប្អូនប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស។

ក្នុងឱកាសនោះ លោកអ៊ុន ចាន់ដា អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ចាមបានមានប្រសាសន៍យ៉ាងដូច្នេះថា «ខ្ញុំនឹងមានវិធានការយ៉ាងតឹងរ៉ឹងបំផុតចំពោះជនជាមេខ្យល់ទាំងឡាយ ហើយខ្ញុំក៏សូមធ្វើការអំពាវនាវដល់បងប្អូន ក្មួយៗសិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ ជាពិសេសកងកម្លាំងមានសមត្ថកិច្ចនៅមូលដ្ឋាន សូមចូលរួមឱ្យបានកាន់តែសកម្មថែមទៀតដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សតាមគ្រប់ទម្រង់ និងគ្រប់រូបភាព ហើយខ្ញុំនឹងមិនលើកលែងជាច់ខាតចំពោះជនទាំងឡាយណា ដែលលូកដៃធ្វើអន្តរាគមន៍ឱ្យមានការដោះលែងចំពោះជនល្មើសក្នុងអំពើជួញដូរមនុស្សនេះ» និង«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព»។

លោក អ៊ុន ចាន់ដា មានប្រសាសន៍ បញ្ជាក់ទៀតថា ឆ្នាំ២០២២នេះ យើងមានឱកាសជាថ្មីក្នុងការរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ដែលស្របទៅទស្សនវិស័យ និងការប្ដេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរក្សានូវសន្តិសុខ សុវត្ថិភាពសង្គម ដើម្បីជាមូលដ្ឋានបង្អែកនៃការអភិវឌ្ឍជាតិគ្រប់វិស័យក្នុងរយៈពេលវែង ។ ជាមួយគ្នានោះ លោកក៏បានសម្តែងនូវការស្វាគមន៍ និងថ្លែងអំណរគុណចំពោះវត្តមានលោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងកម្មវិធីដ៏មានសារៈសំខាន់នាថ្ងៃនេះផងដែរ ។

លោក អ៊ុន ចាន់ដា បានគូសបញ្ជាក់ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងតែប្រារព្ធទិវាជាតិនេះជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមទាំងការផ្សព្វផ្សាយខិត្តប័ណ្ណតាមសាលារៀននិងទីសាធារណៈនានានៅទូទាំងខេត្តដែលមានអ្នកចូលរួមនិងទទួលបាននូវខិត្តប័ណ្ណ រហូតដល់រាប់សែននាក់ ដើម្បីបំផុសការយល់ដឹងយ៉ាងទូលំទូលាយអំពីព្រឹត្តិការណ៍ ស្ថានភាព និងនិន្នាការនៃអំពើជួញដូរមនុស្សដែលបង្កគ្រោះមហន្តរាយ ដល់មនុស្សក្មេង ចាស់ ប្រុស ស្រី និងដល់សង្គមជាតិឥតឈប់ឈរទាំងនៅក្នុងព្រះរាជាណាចក្រ

កម្ពុជា និងទាំងនៅតាមមូលដ្ឋាននានា ។ ក្រៅពីនោះ ការរៀបចំកម្មវិធីនេះ ក៏ជាឱកាសមួយក្នុងការដាស់តឿនដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់វ័យ គ្រប់ស្ថានភាព គ្រប់មជ្ឈដ្ឋានឱ្យប្រុងប្រយ័ត្នចំពោះល្បិចកលថ្មីៗរបស់ជនល្មើសជួញដូរមនុស្សផងដែរ ។

នាឱកាសនោះដែរ លោកអ៊ុន ចាន់ដា អភិបាលខេត្ត ក្នុងនាមគណៈបញ្ជាការឯកភាពរដ្ឋបាល ខេត្តកំពង់ចាម ក៏បានផ្តាំផ្ញើបន្ថែមដល់អ៊ំ ពូ មីង បងប្អូនប្រជាពលរដ្ឋ សូមចូលរួមទាំងអស់គ្នាបន្តទៀតដើម្បីភូមិ ឃុំ មានសុវត្ថិភាព នោះគឺការចូលរួមអនុវត្តនូវគោលនយោបាយទាំង ៧ចំណុច របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព និងទទួលបានប្រសិទ្ធផល ដោយលោកលើកយកចំណុចសំខាន់ៗចំនួន ៤ គឺ ៖

១.គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

២.មានសណ្តាប់ធ្នាប់សាធារណៈល្អ ពិសេស គ្មានគ្រោះថ្នាក់ចរាចរណ៍ ។

៣.គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។

៤.មានអនាម័យ មានសោភណភាពល្អ និងមានបរិស្ថានល្អ ៕

## អភិបាលខេត្តឧត្តរមានជ័យ ជំរុញដល់សមត្ថកិច្ចត្រូវបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ

https://www.khmertimeskh.com/501206338/-2/?p=1206338 កែវ វេចនា / December 21, 2022

លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ និងជាប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តឧត្តរមានជ័យ បានអំពាវនាវឱ្យសមត្ថកិច្ច និងអាជ្ញាធរ នៅតាមតំបន់ ត្រូវទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទឱ្យមានប្រសិទ្ធភាព។

ថ្លៃង នៅក្នុងពិធីទិវាជាតិលើកទី១៦ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០២២ នៅថ្ងៃទី ២១ ខែធ្នូ លោក ប៉ែន កុសល្យ បានលើកឡើងថា ការ ប្រារព្ធ ទិវាជាតិ ១២ ធ្នូ ប្រយុទ្ធប្រឆាំង អំពើជួញដូរ មនុស្ស ក្នុងគោលបំណង ពញ្ញាក់ នូវ ស្មារតីបនរជាពលរដ្ឋទាំងអស់ ដើម្បី ចូលរួម ក្នុងសកម្មភាពដោយផ្ទាល់ និង ប្រយោលក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាប ឱ្យ ខាន តែបាន នូវ បទឧក្រិដ្ឋ នៃអំពើជួញដូរមនុស្សគ្រប់រូបភាព។ អំពើ ជួញដូរមនុស្ស និង អំពើធ្វើ អាជីវកម្មផ្លូវភេទ គឺជា បរិ បទ សកល ដែល នៅតែ បន្តកើតមាន អាស្រ័យ លើកត្តា សំខាន់ៗបី គឺការអប់រំសង្គម ការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស។ លោក ប៉ែន កុសល្យ ក៏បានជំរុញដល់កងកម្លាំងសមត្ថកិច្ច ក៏ដូចជាអាជ្ញាធរនៅ តាមមូលដ្ឋានទាំងអស់ ត្រូវ បង្កើន ការ ផ្សព្វផ្សាយ ច្បាប់ទប់ស្កាត់ និង ការបង្ក្រាបអំពើជួញដូរមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ ឱ្យ ដល់មូលដ្ឋាន ដាច់ស្រយាល ក្នុងការ ផ្សព្វផ្សាយ ឱ្យបានស៊ីជម្រៅ ដល់សាលារៀន និង គ្រឹះស្ថាន សិក្សាផងដែរ។

លោកស្រី មុំ ពុទ្ធីតា ប្រធាន លេខាធិការដ្ឋាន គណៈកម្មាធិការ ខេត្ត ប្រយុទ្ធប្រឆាំង អំពើ ជួញដូរ មនុស្សខេត្តឧត្តរមានជ័យ បាន ឲ្យដឹងថា លទ្ធផល នៃ ការងារ ប្រយុទ្ធប្រឆាំង អំពើ ជួញដូរ មនុស្សប្រចាំ ឆ្នាំ ២០២២ នៅខេត្តឧត្តរមានជ័យ មាន បទល្មើស កើតឡើង ចំនួន ០៥ ករណី គឺ ករណី រំលោភ ១ ករណី ករណី រួមភេទ ជាមួយអនីតិជន ៣ ករណី និង ការប្រើអំពើហិង្សា ក្នុងគ្រួសារ ០១ កណី ផងដែរ៕

## មីយ៉ាន់ម៉ាចាប់ខ្លួន
## ក្រុមជួញដូរមនុស្ស១២នាក់ពាក់ព័ន្ធនឹងការស្លា.ប់ជនជាតិរ៉ូហ៊ីយ៉ា១៣នាក់

https://kohsantepheapdaily.com.kh/article/1655125.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២១ ខែ ធ្នូ ឆ្នាំ ២០២២ ម៉ោង ១៥:៥៤

មីយ៉ាន់ម៉ា ៖ ប៉ូលិសមីយ៉ាន់ម៉ាចាប់ខ្លួនមនុស្សចំនួន ១២នាក់ដែលជាសមាជិកក្រុមជួ.ញដូរមនុស្សដែលពាក់ព័ន្ធនឹងការស្លា.ប់ជនជាតិរ៉ូហ៊ីងយ៉ាង១៣នាក់។ របបយោធាមីយ៉ាន់ម៉ាបាននិយាយកាលពីថ្ងៃអង្គារ ទី ២០ ធ្នូ ម្សិលមិញនេះថា ប៉ូលីសបានឆ្មក់ចូលក្នុងបរិវេណមួយកន្លែងនៅក្នុងក្រុង Hlegu ក្បែរទីក្រុង Yangon កាលពីថ្ងៃទី ៩ ខែធ្នូ ដោយរឹបអូសបានរថយន្តចំនួន ៥គ្រឿង និងរថយន្តដឹកប្រេងមួយគ្រឿងដែលត្រូវបានប្រើប្រាស់ក្នុងការជួយដូរមនុស្ស។ ក្រុមទាំងនោះបានជួញដូរជនជាតិបេងហ្គាល់ (Bengalis) ចំនួន ២៥៥នាក់ពីរដ្ឋ Rakhine។ ប៉ុន្តែប៉ូលីសមីយ៉ាន់ម៉ាមិនបាននិយាយពីគោលដៅចុងក្រោយនៃការជួយដូរជនជាតិទាំងនោះទេ។ ជនជាតិរ៉ូហ៊ីយ៉ាងចំនួន ១៣នាក់ដែលត្រូវគេប្រទះឃើញស្លា.ប់នៅលើដងផ្លូវក្បែរទីក្រុង Hlegu កាលពីថ្ងៃទី ៥ ខែធ្នូ មានទំនាក់ទំនងនឹងការស៊ើបអង្កេតលើក្រុមជួ.ញដូរនេះ។ ចំណែកជនជាតិរ៉ូហ៊ីងយ៉ាចំនួន ១៩នាក់ទៀតដែលកំពុងរង់ចាំឱ្យក្រុមជួយដូរដឹកពួកគេនៅជើងក្រោយ ត្រូវបានឃុំខ្លួនបន្ទាប់ពីមានប្រតិបត្តិការឆ្មក់របស់ប៉ូលីសមីយ៉ាន់ម៉ានៅក្នុងបរិវេណក្នុងក្រុង Hlegu។

សូមរម្លឹកថា ជនជាតិរ៉ូហ៊ីងយ៉ារាប់សែននាក់បានភៀសខ្លួនចេញពីប្រទេសមីយ៉ានម៉ាក្នុងឆ្នាំ ២០១៧ ដើម្បីគេចពីការបង្ក្រាបរបស់យោធាមីយ៉ាន់ម៉ា និងបានធ្វើដំណើរទៅកាន់ប្រទេសជិតខាងបង់ក្លាដេស ដែលក្រុមជនជាតិដើមភាគតិចទាំងនោះមានរឿងរ៉ាវដ៏អាក្រក់នៃការសម្លា.ប់ ការរំលោ.ភ និងការដុ.តពីសំណាក់យោធាមីយ៉ាន់ម៉ា។ មីយ៉ានម៉ាកំពុងប្រឈមនឹងការចោទប្រកាន់ ពីបទប្រល័យពូជសាសន៍នៅតុលាការកំពូលរបស់អង្គការសហប្រជាជាតិ បន្ទាប់ពីមានការជម្លៀសខ្លួនចេញដ៏ច្រើនរបស់ជនជាតិរ៉ូហ៊ីងយ៉ា។ កាលពីដើមខែនេះ របបយោធាមីយ៉ាន់ម៉ាបាននិយាយថា ជនជាតិរ៉ូហ៊ីងយ៉ាងចំនួន ៧០នាក់ដែលលាក់ខ្លួនក្នុងរថយន្តដឹកខ្ទឹមត្រូវបានចាប់ខ្លួននៅភាគខាងជើងទីក្រុង Yangon បន្ទាប់ពីឡានរបស់ពួកគេបានបុ.កប្រឡាយតាមដងផ្លូវ៕ (យោងតាមប្រភព៖ AFP)

# ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០២២

## អភិបាលខេត្តឧត្តរមានជ័យ ជំរុញដល់សមត្ថកិច្ចត្រូវបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទឱ្យបានទាន់ពេល

https://btv.com.kh/article/18412 2022/12/21 01:18:32 pm

ឧត្តរមានជ័យ៖ ឯកឧត្តម ប៉ែន កុសល្យ ប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តឧត្តរមានជ័យ បានអំពាវនាវឱ្យសមត្ថកិច្ច និងអាជ្ញាធរនៅតាមតំបន់ ត្រូវទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទឱ្យមានប្រសិទ្ធភាព។ ថ្លែងយ៉ាងដូច្នេះ នៅក្នុងពិធីទិវាជាតិលើកទី១៦ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្នុងលាលប្រជុំសាលាខេត្ត នៅថ្ងៃទី២១ខែធ្នូនេះ ។ ក្នុងនោះឯកឧត្តម ប៉ែន កុសល្យ បានបន្តថា ការប្រារព្ធទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ក្នុងគោលបំណងពញ្ញាក់នូវស្មារតីដល់បងប្អូនជនរួមជាតិខ្មែរយើងទាំងអស់ ដើម្បីចូលរួមក្នុងសកម្មភាពដោយផ្ទាល់ និងប្រយោល ក្នុងការបង្ការទប់ស្កាត់ និង បង្ក្រាបឱ្យខានតែបាននូវបទឧក្រិដ្ឋនៃអំពើជួញដូរមនុស្សគ្រប់រូបភាព។

តួយ៉ាងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទគឺជាបរិបទសកលដែលនៅតែបន្តកើតមាន អាស្រ័យលើកត្តាសំខាន់៣បី គឺ ការអប់រំសង្គម ការអនុវត្តច្បាប់ និងការចេក់ឱកាសពីជនល្មើស។ ឯកឧត្តម ក៏បានផ្តាំផ្ញើឱ្យកងកម្លាំងសមត្ថកិច្ចក៏ដូចជាអាជ្ញាធរនៅតាមមូលដ្ឋានទាំងអស់ ត្រូវបង្កើនការផ្សព្វផ្សាយច្បាប់ទប់ស្កាត់ និងការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឱ្យដល់មូលដ្ឋាន ដាច់ស្រយាល ក្នុងការផ្សព្វផ្សាយឱ្យបានស៊ីជម្រៅដល់សាលារៀន និងគ្រឹះស្ថានសិក្សាផងដែរ។

យ៉ាងណាមិញតាមរបាយការណ៍របស់លោកជំទាវ មុំ ពុទ្ធីតា ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តឧត្តរមានជ័យ បានឲ្យដឹងថា លទ្ធផលនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំ ឆ្នាំ២០២០២២នេះ នៅខេត្តឧត្តរមានជ័យ មានបទល្មើសកើតឡើងចំនួន០៥ករណី គឺករណីរំលោភ១ករណី ,ករណីរួមភេទជាមួយអនីតិជន៣ករណី និងប្រើអំពើហិង្សាក្នុងគ្រួសារ០១កណី៕ អត្ថបទ៖ សារិទ្ធ

## កម្ពុជា ដាក់ចេញវិធានការចំនួន៤ ដើម្បីប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស

https://www.kampucheathmey.com/local-news/435360 ថ្ងៃព្រហស្បតិ៍ ២២ ធ្នូ ២០២២ដោយ KC Virak

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃបានលើកឡើងថា បច្ចុប្បន្នរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចំនួន៤ ដើម្បីប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស នៅប្រទេសកម្ពុជាឱ្យទទួលបានជោគជ័យ។ ថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធដើម្បីរៀបចំកម្មវិធីបង្កាទប់ស្កាត់អំពើជួញដូរមនុស្ស" នៅខេត្តកណ្តាល នាថ្ងៃទី២១ ធ្នូនេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបញ្ជាក់ថា វិធានការចំនួន៤ ដើម្បីប្រយុទ្ធប្រឆាំងនិងការជួញដូរមនុស្សមាន ទី១ គឺការបង្ការ និងទប់ស្កាត់កុំឱ្យមានអំពើជួញដូរមនុស្សកើតមានឡើង ទី២ ពង្រឹងយុត្តិធម៌ច្បាប់ និងការដាក់ទោសដល់ជនល្មើស ទី៣ កិច្ចការពារជនរងគ្រោះ និងទី៤ បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអន្តរជាតិ។

លោកស្រី ជូ ប៊ុនអេង បានបន្តថា៖ "ក្នុងចំណោមវិធានការទាំង៤នេះ គឺវិធានការបង្ការ និងទប់ស្កាត់ គឺមានប្រសិទ្ធភាពជាងគេ ដូច្នេះសូមមន្ទីរពាក់ព័ន្ធ អាជ្ញាធរក្រុង-ស្រុក ត្រូវរួមគ្នារកដំណោះស្រាយបង្កាទប់ស្កាត់អំពើជួញដូរមនុស្ស កុំឱ្យកើតមាន ដើម្បីធ្វើឱ្យបទល្មើសនេះមានការថយចុះជាលំដាប់ ឈានទៅរកការលុបបំបាត់បានទាំងស្រុង ដោយទាមទារឱ្យយើងត្រូវរកវិធីសាស្ត្រ និងវិធានការរួមគ្នាដែលមានប្រសិទ្ធភាពក្នុងការអនុវត្ត"។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានបន្ថែមថា សិក្ខាសាលានេះផ្តោតសំខាន់គឺ ចង់ឱ្យមន្ទីរអង្គភាពពាក់ព័ន្ធ អាជ្ញាធរក្រុង-ស្រុក ធ្វើការចែករំលែកព័ត៌មានពិតពីគ្នាទៅវិញទៅមក ពីព្រោះមានតែព័ត៌មានពិតច្បាស់លាស់ទេទើបអាចដោះស្រាយបញ្ហាបាន។ ជាពិសេសយើងត្រូវរកមូលហេតុដែលជាឬសគល់នៃបញ្ហារបស់បទល្មើសជួញដូរមនុស្សឱ្យឃើញ ហើយរួមគ្នាលុបបំបាត់ឫសគល់បញ្ហាឱ្យអស់ នោះអំពើជួញដូរមនុស្សនឹងមិនអាចកើតមានឡើងបានឡើយ។

លោក គង់ សោភ័ណ្ឌ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល បានបញ្ជាក់ថា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរលមនុស្ស រដ្ឋបាលខេត្ត និងមន្ទីរជំនាញបានរៀបចំវេទិកាផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងផលប៉ះពាល់នៃការធ្វើ ចំណាកស្រុកដោយប្រថុយប្រថាននៅក្នុងក្រុង ស្រុកទាំង១១ ចំនួន ១១ លើក មានអ្នកចូលរួម ចំនួន ២ ៩៤៣ នាក់ ដោយឡែកក្រុមការងារថ្នាក់ក្រុង ស្រុក បានប្រជុំផ្សព្វផ្សាយបានចំនួន ៨ ០៦២ លើក៕
**អត្ថបទ៖ សំអឿន**

## កុមាររងអំពើបៀតបៀនតាមអនឡាញ
## ស្វែងរកជំនួយពីលេខទូរស័ព្ទ ១២៨០ មានការកើនឡើង

https://www.postkhmer.com/national/2022-12-21-1903-245059.html ហុង រស្មី | Publication date 21 December 2022 | 19:03 ICT

**ភ្នំពេញ:** កុមារតូចៗរហូតដល់យុវជនវ័យក្រោម ២៥ ឆ្នាំ បានរាយការណ៍ទៅកាន់លេខទូរស័ព្ទ ១២៨០ ជាបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា អំពីអំពើបៀតបៀនតាមអនឡាញក្នុងឆ្នាំ ២០២២ នេះមាន ១៥ ករណី ដែលមានការកើនឡើងគួរឱ្យបារម្ភក្នុងសម័យបច្ចេកវិទ្យារីកចម្រើននេះ។ ១៥ ករណី ដែលរួមមានអំពើរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ (Online Child Sexual Exploitation and Abuse) មាន ៥ ករណី ហើយការបៀតបៀនតាមអ៊ីនធឺណិត (Cyber Bulling) មាន ១០ ករណី ត្រូវបានកត់ត្រាដោយអង្គការតែមួយគិតត្រឹមថ្ងៃទី ២០ ខែធ្នូឆ្នាំ២០២២។ វាជាអង្គការទូរស័ព្ទជំនួយកុមារកម្ពុជា (Child Helpline Cambodia) ផ្តល់សេវាពិគ្រោះយោបល់ ផ្តល់ព័ត៌មានអប់រំ និងសេវាបញ្ជូនបន្ត តាមរយៈលេខទូរស័ព្ទ ១២៨០ (ឥតគិតថ្លៃ) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ ដោយអង្គការអន្តរជាតិធំៗចំនួន១១ ដូចជា UNICEF, PLAN, Save the Children ជាដើម។

លោក ស៊ាង សុខថៃ នាយកប្រតិបត្តិអង្គការទូរស័ព្ទជំនួយកុមារកម្ពុជា បាននិយាយថា៖ «ជនល្មើសព្យាយាមបង្កើតទំនាក់ទំនងជាមួយក្មេងៗតាមអនឡាញ ដោយឱ្យជាកាដូ កាតទូរស័ព្ទ លុយកាក់ និងលួងលោមក្នុងបំណងនៃការរួមភេទ។ ករណីខ្លះ បទល្មើសធ្វើជាវីដេអូអាសអាភាសតាមអនឡាញឱ្យក្មេងមើល ហើយមួយទៀតពាក់ព័ន្ធនឹងការរំលោភបំពានក្មេងតាមអនឡាញតែម្តង»។ លោកបានពន្យល់ថា បុគ្គលល្មើសថតជាវីដេអូសម្រេចកាមខ្លួនឯង រួចផ្ញើទៅកាន់ក្មេង ដើម្បីឱ្យមានអារម្មណ៍ផ្លូវភេទជាមួយរូបគេ។ នេះជាករណីហៅថា Online Child Sexual Exploitation and Abuse ដែលកុមារមិនត្រូវបានអនុញ្ញាតឱ្យពាក់ព័ន្ធរឿងទាំងអស់នេះទេ។ លោកសុខថៃបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «ការបៀតបៀនតាមអ៊ីនធឺណិត (Cyber Bulling) ជាករណីផ្សេងទៀតដែលទាក់ទងការចែករំលែកវីដេអូ ឬរូបភាពក្មេងអាក្រាត ហើយក៏មានការណីបៀតបៀន (Harassment) ផ្លូវភេទតាមអនឡាញ ក៏ដូចជាការគំរាមបង្ហោះរូបអាសអាភាសរបស់ក្មេងតាមរយៈការលួងលោមសុំរូប រួចធ្វើការគំរាមយកលុយ»។

របាយការណ៍កាលពីឆ្នាំកន្លងមក អំពើរំលោភបំពានតាមអនឡាញ មានត្រឹមតែ ១ ឬ ២ ករណីប៉ុណ្ណោះ ខណៈបញ្ហាបំពានគ្នានៅលើបណ្តាញអ៊ីនធឺណិត ឬ Cyber Bullying មាន ៥ករណី ក្នុងឆ្នាំ២០២១។ យ៉ាងណាមិញ លោក សុខថៃ បានអះអាងថា វាមិនមែនមានន័យថា កន្លងមកមិនមានបញ្ហានេះកើតមាននោះទេ តែកម្រមានការខលសុំជំនួយទាំងករណីបៀតបៀនតាមអ៊ីនធឺណិត និងអំពើរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។ អំឡុងពេលប្រតិបត្តិការរយៈពេល ១៥ ឆ្នាំមកនេះបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋដែលហៅទូរស័ព្ទមកកាន់ Helpline ១២៨០ នេះ មានការវិវត្តទៅតាមកាលវេលា។ នាយកប្រតិបត្តិអង្គការ បានឱ្យដឹងថា ឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ វាចាប់ផ្តើមផ្ទុះបញ្ហាក្មេងស្រីរៀបការទៅចិន ហើយក្រោយមកចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ វាកើតចេញជារឿងរំលោភបំពានតាមអនឡាញ ដោយក្មេងៗបៀតបៀនគ្នា ហៅគ្នាថតរូបអាសអាភាសដើម្បីយកទៅគំរាមគ្នា។

លោកអះអាងថា៖ «ថ្មីៗនេះ វាផ្ទុះរឿងលេងហ្គេមអនឡាញ ដោយការចាប់ជំរិតគ្នា និងលាងលុយកខ្វក់ផ្សេងៗ។ បញ្ហាទាំងអស់នេះសុទ្ធតែទាក់ទងយុវជន»។ ថ្វីដ្បិតតែលេខជំនួយនេះជាលេខខ្លីដូចគ្នា ដូចជា លេខប៉ូលិស ១១៧ លេខពេទ្យ ១១៩ និង ១១៥ ហើយលេខរបស់ប៉ូលិសប្រឆាំងការជួញដូរ ១២៨៨ ជាប្រភេទបណ្តាញសង្គមផ្តល់សេវាបន្ទាន់ តែលេខ Helpline ១២៨០ គ្រាន់តែជាទូរស័ព្ទជំនួយ។ លោកបានបញ្ជាក់ថា៖ «លេខរបស់រដ្ឋទាំងអម្បាលមានខាងលើជាលេខតម្រូវដោយច្បាប់ អាចធ្វើអន្តរាគមន៍ភ្លាមៗ និងមានសិទ្ធិចូលចាប់ចងជនល្មើស [តាមដីការ] ដល់ក្នុងផ្ទះភ្លាមៗ។ ប៉ុន្តែខាង Helpline ១២៨០ គ្រាន់តែផ្តល់ការគាំទ្រផ្លូវចិត្ត ផ្តល់ការពិគ្រោះយោបល់

ដោយមានវិជ្ជាជីវៈ និងផ្តល់ព័ត៌មាន ក៏ដូចជាបញ្ជូនបញ្ហាណាមួយទៅកាន់អាជ្ញាធរ ឬអង្គការសង្គមស៊ីវិល ហើយបុគ្គលិកយើងមិនត្រូវបានអនុញ្ញាតឱ្យចុះអន្តរាគមន៍នៅក្នុងផ្ទះពលរដ្ឋបានទេ»។

របាយការណ៍ឆ្នាំ ២០២១ និងឆ្នាំ ២០២២ បញ្ហាផ្លូវចិត្តសង្គមចំនួន ៦៧០នាក់ បញ្ហាទំនាក់ទំនងក្នុងគ្រួសារ មាន ២០៦ នាក់ សម្រាប់របាយការណ៍ឆ្នាំ២០២២ ហើយឆ្នាំ២០២១ វិបត្តិសុខភាពផ្លូវចិត្ត (Mental health) មានចំនួនរហូតដល់ ៧៧៩ករណី និងបញ្ហាក្នុងគ្រួសារ ដែលកើតពីការអន់ចិត្ត ខិងសម្បា ឬសម្ពាធគ្រួសារ មានត្រឹម ១២៤ករណី។ ខណៈបញ្ហាធំទី២ក្នុងឆ្នាំ២០២១ គឺអំពើហិង្សាទូទៅ ជាជម្លោះរវាងមនុស្សធំ និងហិង្សាផ្សេងៗ មានចំនួន ១៣៥ករណី អំពើហិង្សាក្នុងគ្រួសារកើតឡើងច្រើនជាងគេ ដែលមាន ៤៦ ករណី អំពើហិង្សាលើកុមារ មាន ៣៧ករណី សម្រាប់របាយការណ៍ឆ្នាំ២០២២ ហើយនៅមានការជួញដូរមនុស្ស ៣ ករណី បញ្ហាក្មេងបម្រើផ្លូវភេទក្នុងវិស័យទេសចរណ៍មាន ៤ ករណី និងកុមារមានសារធាតុញៀនចំនួន ៦ នាក់ទៀត។

លោក សុខថៃ បានឱ្យដឹងថា៖ «នៅឆ្នាំ២០២២ នេះ បញ្ហានៅសាលារៀនមាន ៨០ នាក់ ដែលជាការដាក់ពិន័យលើរាងកាយ ឈ្លោះជាមួយគ្រូ ពិបាករៀន ពិបាកផ្ទង់អារម្មណ៍ ពិបាកជ្រើសរើសមុខវិជ្ជាសិក្សា បញ្ហាក្មេងបោះបង់ចោលការសិក្សា ខ្វះខាតសម្ភារសិក្សា និងផ្ទះនៅឆ្ងាយ រួមទាំងក្មេងគេចសាលា។ នេះ មានចំនួន ៨៩ ករណីក្នុងឆ្នាំ២០២១»។ លោកបន្តថា៖ «ជាទូទៅ យើងព្យាយាមប៉ាន់ប្រមាណលើបញ្ហារបស់ពួកគាត់ ហើយបើសិនជាពួកគាត់មានតម្រូវការមូលដ្ឋានណាមួយដែលត្រូវការជាធនធាន និងសម្ភារ យើងបញ្ជូនពួកគាត់ទៅអង្គការដៃគូដែលធ្វើការលើផ្នែកអប់រំ»។ ឆ្នាំ២០២២ នៅមានក្មេងបាត់ខ្លួន ៥ ករណី អំពើហិង្សាលើស្ត្រី មាន ៤៨ ករណី ហើយក្រៅពីនោះ អ្នកហៅទូរស័ព្ទចូលមក ១២៨០ ដើម្បីសាកសួរព័ត៌មានអំពីបញ្ហាសុខភាព សេវាអង្គការដទៃ ចំណេះដឹងផ្នែកច្បាប់ និងចំណេះដឹងពាក់ព័ន្ធពលកម្មកុមារផ្សេងៗ មាន ៤៣ាន់ករណី។ ចំណែកឯរបាយការណ៍ឆ្នាំ ២០២១ អំពើរំលោភបំពានផ្លូវភេទ មាន ៣៨ករណី ហើយបញ្ហារៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងចំនួន ៦ករណី។

នាយកប្រតិបត្តិអង្គការលោក សុខថៃ បានលើកឡើងថា អំឡុងឆ្នាំ២០២១ ប្រជាជនខ្លះ ដែលមិនបានទាក់ទងទៅលេខបន្ទាន់របស់ក្រសួងសុខាភិបាល ១១៥ ក៏បានតេចូល Helpline ១២៨០ ដែលរាយការណ៍ពីការឆ្លងជំងឺកូវីដចំនួន ៤៥ ករណី។ ការហៅទូរស័ព្ទចូលខ្ពស់ជាងគេ គឺការសាកសួរព័ត៌មានអំពីប្រធានបទផ្សេងៗ មាន ៥ ៦៣៣ ករណី។ លោកបានប្រាប់ថា៖ «យើងបញ្ជូនបន្តទៅកាន់ស្ថាប័នជំនាញ និងពាក់ព័ន្ធ វាអាស្រ័យទៅលើករណីដែរ។ ជាក់ស្តែង វាជាអំពើហិង្សាក្នុងគ្រួសារដែលជនរងគ្រោះអាយុចាប់ពី ១៨ ឆ្នាំឡើង យើងត្រូវមានការឯកភាពពីគាត់ក្នុងការបញ្ជូនករណីនេះបន្តទៅស្ថាប័នជំនាញ។ បើគាត់មិនស្ម័គ្រចិត្ត ឬយល់ព្រម យើងក៏មិនអាចបញ្ជូនករណីរបស់គាត់បន្តបានឡើយ»។ ជាទូទៅ បញ្ហាត្រូវបានបញ្ជូនបន្តមានចន្លោះពី ៥០ ទៅ ៧០ករណី ដូចជា ការបញ្ជូនទៅកាន់ស្ថាប័នប៉ូលិសឱ្យចុះជួយអន្តរាគមន៍ ឬតម្រូវការសេវាផ្លូវច្បាប់ទៅស្ថាប័នដៃគូ ខណៈបញ្ហាបញ្ជូនបន្តឆ្នាំ២០២២ មានត្រឹម ២០ ករណី។

លោកបានអះអាងថា៖ «ចំពោះករណីជនរងគ្រោះអាយុលើសពី ១៨ ឆ្នាំដែលមិនព្រមឱ្យយើងបញ្ជូនរឿងរបស់ពួកគេទៅកាន់អាជ្ញាធរ យើងនៅតែបញ្ជូន មានន័យថា យើងជាស្ថាប័នមួយដែលរំលោភសិទ្ធិមនុស្សខ្លួនឯង»។ ចំពោះករណីរំលោភបំពានលើក្មេងអាយុក្រោមអាយុ ១៥ឆ្នាំ ដែលខលមករកជំនួយ សំណុំរឿងរបស់ពួកគេត្រូវតែបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចដើម្បីស៊ើបអង្កេតបន្ត ទោះកុមារនោះមិនស្ម័គ្រចិត្តក៏ដោយ។ លោកនិយាយថា៖ «ទោះបីជាគាត់មិនឱ្យយើងបញ្ជូនសំណុំរឿងនេះទៅស្ថាប័នជំនាញយ៉ាងណាក៏ដោយក៏យើងត្រូវតែបញ្ជូន ដោយសារនៅក្នុងច្បាប់ក្រមព្រហ្មទណ្ឌតម្រូវឱ្យស្ថាប័នធ្វើការជាមួយក្មេង ត្រូវដឹងថា វាជារឿងពិត យើងត្រូវតែបញ្ជូន ដើម្បីឱ្យសមត្ថកិច្ចស៊ើបអង្កេតបន្ត និងចាប់ខ្លួនជនបង្ក»។ លោកបន្ថែមថា៖ «ពាក់ព័ន្ធការរួមភេទចំពោះបុគ្គលអាយុលើស ១៥ឆ្នាំ យើងត្រូវពិភាក្សាជាមួយគាត់សិនថា តើករណីនេះជាការចាប់បង្ខំ ឬរំលោភឬក៏អត់ ?»។

ករណីបញ្ជូនបន្តដ៏ស្មុគស្មាញ ស្ត្រីជាម្ដាយ មានកូនស្រីតូចដែលបានអះអាងថា ត្រូវបានឪពុកធំចាប់រំលោភតាំងពីអាយុ ៣ ឆ្នាំ បាននិយាយដោយសុំមិនបញ្ចេញអត្តសញ្ញាណថា កូនស្រីរបស់អ្នកស្រីតែងតែចង្អុលមុខជនបង្កជាអ៊ំបង្កើត នៅពេលម្ដាយដឹងថា ប្រដាប់ភេទកូនស្រីតូចមានបញ្ហា។ អ្នកស្រី បានឱ្យដឹងថា អ្នកស្រីបានប្រាប់ហេតុការណ៍នេះដល់ស្វាមី និងម្ដាយក្មេកដែលរួមរស់នៅផ្ទះជាមួយគ្នា។ ប៉ុន្តែគ្មាននរណាជឿ និងបានចោទអ្នកស្រីថាបានធ្វើបាបកូនស្រីខ្លួនឯងដើម្បីចោទប្រកាន់បងថ្លៃ។ ស្ត្រីដែលត្រូវបានស្វាមីនិងសាច់ញាតិខាងស្វាមីបណ្ដេញចេញពីផ្ទះរូបនេះ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «ខ្ញុំបានប្ដឹងដល់អាជ្ញាធរ រួចបន្តទូរស័ព្ទទៅលេខជំនួយ ១២៨០ និងអង្គការអាដហុកថែមទៀត។ ប៉ុន្តែគិតមកដល់ពេលនេះ វាមានរយៈពេលជាង១ឆ្នាំហើយ ហើយខាងអង្គការដែលបានជួយជាមេធាវីក៏មិនមានចម្លើយអំពីករណីនេះដែរ ដោយសារពួកគេនិយាយថា វាធ្លាក់ទៅដល់ដៃតុលាការហើយ»។

អ្នកស្រី បានបន្ថែមថា អ្នកស្រីចង់បានយុត្តិធម៌ និងមិនចង់ឱ្យកូនស្រីតូចមានជំបៅផ្លូវចិត្តនៅពេលធំដឹងក្ដីនោះទេ។ ដូច្នេះ អ្នកស្រីចង់ឱ្យបណ្ដឹងនេះត្រូវបានដោះស្រាយឆាប់ចប់។ អំពើរំលោភបំពានផ្លូវភេទមានការកើនឡើងអំឡុងពេលបិទខ្ទប់រំពឹកដល់កាលគ្រាបិទខ្ទប់ដោយសារជំងឺរាតត្បាតកូវីដ ១៩ ចំនួនទូរស័ព្ទហៅចូលមានការកើនឡើងទាំងខ្សែបណ្ដាញរបស់រដ្ឋ និងសង្គមស៊ីវិល។ ដូចគ្នានេះ អង្គការ ទូរស័ព្ទជំនួយកុមារកម្ពុជា ១២៨០ ក៏មានការកើនឡើង ដោយទូរស័ព្ទតែងតែរោទ៍ជាប់ជានិច្ច ដែលភាគច្រើនសម្ដែងការបារម្ភ ភ័យខ្លាច និងអស់សៀ្បងជាដើម។

លោក សុខថៃ បាននិយាយថា៖ «ទាក់ទងបញ្ហានេះ អ្នកជំនាញពិគ្រោះយោបល់ព្យាយាមផ្ដល់ប្រឹក្សាឱ្យពួកគាត់រក្សាចិត្តឱ្យស្ងប់ ហើយយើងបញ្ជូនពួកគាត់ទៅរកគណៈកម្មការស្បៀងនៅក្នុងពេលបិទខ្ទប់។ អ្នកហៅទូរស័ព្ទមកសុទ្ធតែទទួលបានការផ្ដល់ប្រឹក្សាផ្លូវចិត្ត និងថែទាំសុខភាពអំឡុងពេលផ្ទុះជំងឺរាតត្បាត ក៏ដូចជាជំរុញឱ្យទៅចាក់វ៉ាក់សាំង»។ ក្រោយបញ្ចប់ការបិទខ្ទប់ និងបើកប្រទេសឡើងវិញ ចំនួនការហៅទូរស័ព្ទ Helpline ក៏នៅមានច្រើនគ្រាន់តែផ្លាស់ប្ដូរទិសដៅទៅរកបញ្ហាសុខភាពបន្តពូជ វិបត្តិផ្លូវចិត្ត ដែលកើតចេញពីបញ្ហាហិរញ្ញវត្ថុគ្រួសារ អំពីហិង្សា និងការរំលោភបំពាន។ យ៉ាងណាមិញ បញ្ហារំលោភបំពានផ្លូវភេទអំឡុងឆ្នាំ២០២១ មាន ៣៨ករណី ខណៈអំឡុងពេលបិទខ្ទប់នៃឆ្នាំ២០២០ អំពើរំលោភបំពានផ្លូវមានរហូតដល់ ៤៨ករណី។

មិនខុសពីមុនកូវីដ ១៩ ចំនួនការហៅទូរស័ព្ទមានប្រមាណ ៣ ០០០ដងក្នុង១ខែដដែល តែមាននិន្នាការផ្លាស់ប្ដូរមួយគឺក្មេង និងយុវជន ចេះប្រើបណ្ដាញសង្គម ជាមួយសារជាសំឡេង និងការសរសេរជាអក្សរ។ ដូច្នេះ ពួកគាត់ប្រើប្រាស់ទាំងបណ្ដាញទូរស័ព្ទ និងបណ្ដាញសង្គម។ លោក សុខថៃ បានបន្តថា៖ «បញ្ហាច្រើនជាងគេ គឺវិបត្តិផ្លូវចិត្ត ស្ត្រេស ជាកត្តាទទួលសម្ពាធពីគ្រួសារ ដោយសារគ្រួសាររងសម្ពាធបន្ត ដូចជា ជំពាក់បំណុលធនាគារ។ អំពើហិង្សាលើកុមារ ជាពិសេស ក្មេងស្រី និងស្ត្រី បញ្ហារឿងបំលោភបំពាន ហើយក្រៅពីនេះ ពួកគាត់សាកសួរព័ត៌មានសុខភាពផ្លូវចិត្ត សុខភាពរាងកាយ ការសិក្សា និងការងារប្រចាំថ្ងៃ»៕

# ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០២២

## ក្រសួងមហាផ្ទៃ

## បន្តចុះអនុស្សរណៈជាមួយអង្គការក្រៅរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស

https://www.btv.com.kh/article/18467 2022/12/23 09:28:22 am

ភ្នំពេញ៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស របស់ក្រសួងមហាផ្ទៃ នៅរសៀលថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២២នេះ បានចុះហត្ថលេខា លើអនុស្សារណៈយោគយល់គ្នាជាមួយអង្គការដែនដីមនុស្សហូឡង់-ប្រចាំកម្ពុជា ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានលើកុមារ ដោយអនុស្សរណៈបានធ្វើ ឡើងរវាង លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងប្រធានអង្គការខាងលើនេះ។

ថ្លែងបន្ទាប់ពីចុះអនុស្សរណៈនោះ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា ការចុះអនុស្សរណៈ ជាមួយ អង្គការក្រៅរាជរដ្ឋាភិបាលនេះ គឺដើម្បីរួមគ្នាទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានលើកុមារនៅកម្ពុជាឲ្យមានប្រសិទ្ធភាពបន្ថែមទៀត ខណៈបញ្ហានេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបានកំពុងយក ចិត្តទុកដាក់យ៉ាងខ្លាំងនោះ។ លោកជំទាវ ជូ ប៊ុនអេង បានបន្តថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បាន ធ្វើការជាមួយដៃគូជាច្រើនរួមទាំងអង្គការសហប្រជាជាតិផងនោះ បានខិតខំយ៉ាងសកម្មក្នុងការទប់ស្កាត់ ការជួញដូរមនុស្ស និងការរំលោភបំពានលើមនុស្សគ្រប់ប្រភេទ ដោយមិនប្រកាន់និន្នាការអ្វីនោះឡើយ។

យ៉ាងណាក៏ដោយ លោកជំទាវ ជូ ប៊ុនអេង បានសំដែងនូវ ក្តីសោមនស្សរីករាយ និងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះកិច្ចសហការល្អ ជាមួយដែនដីមនុស្សហូឡង់នាពេលនេះ បានក្លាយទៅជាដៃគូមួយទៀត ក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ការចុះអនុស្សរណៈជាមួយអង្គការក្រៅរាជរដ្ឋាភិបាល និងដៃគូនានានេះ គឺមានគោលបំណងដូចជា៖ ការសហការប្រមូលព័ត៌មាន សម្រាប់ជំនួយដល់នីតិវិធីច្បាប់, ការសហការក្នុងការធ្វើអន្តរាគមន៍ និងសង្គ្រោះ ការសហការសម្របសម្រួល ក្នុងការលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាព ការសហការសិក្សាស្រាវជ្រាវ និងតស៊ូមតិ ដើម្បីវិភាគ ចងក្រងរបាយការណ៍ អំពីបេកគំហើញ និងអនុសាសន៍ជាដើម៕ អត្ថបទ៖បាន ចក់

## សមត្ថកិច្ចកម្ពុជា

## បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៤នាក់

http://freshnewsasia.com/index.php/en/localnews/271012-2022-12-23-03-48-51.html 2022-12-23 10:48am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៦៧០ករណី មានមនុស្ស ១,៦៣៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤២៥សំណើ និងបិទសំណុំរឿង ២១៨សំណើ (រកឃើញមនុស្ស ១,០៣៤នាក់, ឃាត់ខ្លួនជនសង្ស័យ ១២០នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៧ករណី។

សូមបញ្ជាក់ថា សម្ដេចក្រឡាហោម ស ខេង បានចេញលិខិតមួយអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិ ស្ថានតំណាងបរទេសប្រចាំកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចនៃបណ្ដាប្រទេសពាក់ព័ន្ធ បន្តសហការផ្ដល់ព័ត៌មានពាក់ព័ន្ធអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនផ្សេងទៀត ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តប្ដេជ្ញាចិត្តប្រកប ដោយឆន្ទៈមោះមុត ក្នុងការអនុវត្តតាមច្បាប់ជាធរមានដើម្បីប្រយុទ្ធប្រឆាំងអំពើឆបោក-ជំរិតទារប្រាក់ តាមប្រព័ន្ធបច្ចេកវិទ្យា បទល្មើសគ្រឿងញៀន បទល្មើសសម្អាតប្រាក់ ល្បែងស៊ីសងអនឡាញខុសច្បាប់ ព្រមទាំងបន្តផ្ដល់ការគាំពារ និងជួយសង្គ្រោះ ទាំងពលរដ្ឋកម្ពុជាដែលរងគ្រោះដោយអំពើជួញដូរនៅឯបរទេស និងសង្គ្រោះជនបរទេសដែលរងគ្រោះដោយអំពើជួញដូរនៅកម្ពុជានេះ៕

## ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ កិច្ចអន្តរាគមន៍ជួយជនរងគ្រោះស្ត្រីនិងកុមារ ដោយការបំពានផ្លូវភេទ និងវិធីសាស្ត្រធ្វើចំណាកស្រុកដោយសុវត្ថិភាព

https://www.khemaradaily.com/p/241652 By វណ្ណៈ កិត្តិស័ក្តិ-December 23, 2022

(កំពង់ធំ)៖ លោកជំទាវ លំ គន្ធារី អភិបាលរងខេត្តកំពង់ធំ និងក្រុមការងារថ្នាក់ខេត្ត ស្រុក និងអាជ្ញាធរមូលដ្ឋានបានអញ្ជើញចូលរួម វគ្គផ្សព្វផ្សាយកិច្ចអន្តរាគមន៍ជួយជនរងគ្រោះស្ត្រីនិងកុមារ ដោយការបំពានផ្លូវភេទ វិធីសាស្ត្រធ្វើចំណាកស្រុកដោយសុវត្ថិភាព កម្មវិធីផ្សព្វផ្សាយនេះក៏មានការចូលរួមពីបងប្អូនប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សប្រមាណជាង៤០០នាក់ ស្ថិតនៅភូមិប្លៀក ឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ នៅព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

លោក យិន ប៊ុនរ័ត្ន អនុប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានលើកឡើងថា ត្រូវបង្កើនសកម្មភាពអប់រំផ្សព្វផ្សាយ ត្រូវបានធ្វើឡើងតាមគ្រប់មធ្យោបាយមានជាអាទិ៍ ការផ្សព្វផ្សាយតាមកម្មវិធីវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្ដាញសង្គម ការចុះផ្សព្វផ្សាយអប់រំតាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព។ គិតក្នុងរយៈពេល១០ខែកន្លងមកនេះ តាមរបាយការណ៍ ដែលលេខាធិការដ្ឋាន បានបូកសរុបមកពីបណ្ដាក្រុមការងារទាំង៦ និងអង្គការដៃគូ ចុះអប់រំផ្សព្វផ្សាយផ្ទាល់ សរុបបានចំនួន២២៣លើក មានអ្នកចូលរួមសរុបចំនួន ១៧.០៥៧នាក់ ស្រី ១១,៦៩០នាក់។

ឆ្លៀតក្នុងឱកាសនេះលោកជំទាវ លំ គន្ធារី អភិបាលរងខេត្តកំពង់ធំ បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ខិតខំដោះស្រាយបញ្ហា ដែលជះឥទ្ធិពលពីវិបត្តិកូវីដ-១៩ គួបផ្សំនឹងផលប៉ះពាល់ នៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងគ្រោះធម្មជាតិ ដែលបានយាយីនៅគ្រប់ទីកន្លែង។ ជាពិសេស ចំពោះការធ្វើសមាហរណកម្មពលករ ដែលបានវិលត្រឡប់ពីប្រទេសគោលដៅ ប្រមាណ៣០ម៉ឺននាក់ ដែលភាគច្រើនជាអ្នកដែលចាកចេញពីភូមិស្រុក រយៈពេលយូរ ខ្វះលទ្ធភាពក្នុងការទ្រទ្រង់ជីវភាព ឱ្យទទួលបានស្ថានភាពល្អប្រសើរ មានការងារ មុខរបរជាប្រក្រតី និងទទួលបានសេវាសង្គម ទាំងឡាយដូចប្រជាពលរដ្ឋដទៃទៀត ។

លោកជំទាវក៏បានបន្តទៀតថា នៅក្នុងឆមាសទី១ នៃឆ្នាំ២០២២ កន្លងទៅស្ថានភាពនៃអំពើជួញដូរមនុស្សមានភាពល្អប្រសើរ ដោយអាត្រានៃបទល្មើសបានថយចុះ គួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ។ស្ថា

នភាពទូទៅ បានរៀបរយល្អប្រសើរហើយចំពោះសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ បែរជាកើតមានបទល្មើសថ្មី លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងដោយឧក្រិដ្ឋជនមួយចំនួន ដែលសម្ងំលាក់ខ្លួនប្រព្រឹត្តបទល្មើស ក្នុងអាជីវកម្ម បន្លំក្លែក ដោយប្រើប្រាស់ឱកាសដ៏ល្អ ។ សកម្មភាពឧក្រិដ្ឋប្រឆាំងនឹងសិទ្ធិមនុស្ស ឧក្រិដ្ឋជនបានប្រព្រឹត្ត សកម្មភាពឃោរឃៅទៅលើជនរងគ្រោះ ដោយពលកម្ម ដោយបង្ខំ ការឆបោកតាមប្រព័ន្ធអនឡាញ ការអូសទាញជនងាយរងគ្រោះពីក្រៅប្រទេស ដើម្បីបង្ខំឱ្យបម្រើសកម្មភាពឆបោកខុសច្បាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ។

លោកជំទាវ លំ គន្ធារី បានផ្តាំផ្ញើសូមអ្នកដែលបានចូលរួមក្នុងវគ្គផ្សព្វផ្សាយច្បាប់ ខិតយកចិត្តទុកដាក់ក្នុងការស្តាប់ អំពីការធ្វើបទបង្ហាញរបស់វាគ្មិន និងចូលរួមចំណែកក្នុងការលុបបំបាត់ រាល់អំពើជួញដូរមនុស្សគ្រប់ទម្រង់។សូមឱ្យតាមបណ្តាអាជ្ញាធរក្នុងស្រុក ត្រូវធ្វើការផ្សព្វផ្សាយអំពីអំពើ ហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្ស វិធីសាស្រ្តចំណាកស្រុកដោយសុវត្ថិភាព ជូនដល់ប្រជាពលរដ្ឋនៅ តាមតំបន់គោលដៅរៀងៗខ្លួន ដោយស្មារតីទទួលខុសត្រូវ និងចូលរួមចំណែកក្នុងការងារនេះទាំងអស់គ្នាឱ្យបានល្អប្រសើរបំផុត។

## ជនរងគ្រោះនៃការឆបោកជនជាតិថៃដែលប្រើបណ្តាញសង្គមហ្វេកបុកដើម្បីសុំការជួយសង្គ្រោះ ឥឡូវបានត្រឡប់មកប្រទេសថៃវិញហើយ

https://www.khmertimeskh.com/501208111// December 24, 2022

ជនរងគ្រោះ៧នាក់ ដែលបានសុំការជួយសង្គ្រោះតាមរយៈបណ្តាញសង្គមហ្វេកបុកពីក្រុមជនពាលដែលមានទីតាំងផ្សេង ឥឡូវនេះបានត្រឡប់មកពីកម្ពុជាវិញហើយ។ បុរស២នាក់ និងស្រ្តី៥នាក់ នោះបានត្រឡប់ទៅប្រទេសថៃវិញដោយឆ្លងព្រំដែនក្នុងស្រុកអារញ្ញខេត្តស្រះកែវកាលពីដើមសប្តាហ៍នេះដោយមានបុគ្គលិកស្ថានទូតថៃ និងមន្រ្តីសន្តិសុខកម្ពុជាបានជូនដំណើរផងដែរ។ មានតែ៤នាក់ប៉ុណ្ណោះដែលមានឯកសារធ្វើដំណើរត្រឹមត្រូវ ប៉ុន្តែអ្នកទាំង៧បានអះអាងថា ពួកគេត្រូវបាននាំយកមកកម្ពុជាដោយផ្ទុយនឹងឆន្ទៈរបស់ពួកគេតាមរយៈការឆ្លងដែនដែលគ្មានអ្នកត្រួតពិនិត្យត្រឹមត្រូវ ដែលនេះពាក់ព័ន្ធនឹងប្រតិបត្តិការឆបោកនៅតាមបណ្តាព្រំដែនប្រទេសកម្ពុជា។

ជនរងគ្រោះបានស្នើសុំជំនួយតាមបណ្តាញសង្គមហ្វេសប៊ុក។ ពួកគេបានអះអាងថា ជនឆបោកជនជាតិចិនបានបោកបញ្ឆោតពួកគេឲ្យធ្វើការនៅខេត្តស្វាយរៀងជាប់ព្រំដែនវៀតណាម។ ពួកគេបាននិយាយថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការ១៥ម៉ោងក្នុងមួយថ្ងៃដោយគ្មានប្រាក់ខែ។ បន្ទប់ស្នាក់នៅរបស់ពួកគេត្រូវបានហ៊ុមព័ទ្ធដោយលួសខ្សែភ្លើង ដូច្នេះពួកគេមិនអាចរត់គេចបានទេ ហើយជំនួសមកវិញ ពួកគេបានស្វែងរកការសង្គ្រោះតាមប្រព័ន្ធហ្វេសបុក។ ជនរងគ្រោះដែលត្រូវបានគេជួយសង្គ្រោះបានត្រឡប់មកស្រុកកំណើតពីប្រទេសកម្ពុជាវិញហើយបាននិយាយថាពួកគេត្រូវបានបង្ខំឱ្យបោកប្រាស់ជនជាតិថៃផ្សេងទៀតដើម្បីល្បួងពួកគេអោយខ្ចីប្រាក់។ ប្រសិនបើពួកគេមិនអាចបំពេញការងារបានល្អ ក្រុមជនពាលនឹងវាយដំពួកគេ។

បន្ទាប់ពីឃើញការផ្សាយផ្ទាល់របស់ពួកគេសុំជំនួយតាមបណ្តាញសង្គមហ្វេសបុក មន្ត្រីអន្តោប្រវេសន៍ខេត្តស្រះកែវបានចុះប្រតិបត្តិការជួយសង្គ្រោះ។ ទីតាំងឆបោកតាមប្រព័ន្ធទូរស័ព្ទនៅកម្ពុជាជាច្រើនកន្លែងត្រូវបាននគរបាលខេត្តស្រះកែវចុះបង្ក្រាបកាលពីសប្តាហ៍មុន។ ពួកគេទាំងអស់សុទ្ធតែមានរឿងស្រដៀងគ្នា ដែលចាត់ទុកខ្លួនឯងជាមនុស្សគ្មានកំហុស។ អ្នកគ្រប់គ្នាបានអះអាងថាពួកគេត្រូវបានគេបោក និងជួញដូរ។ ក្រុមជនឆបោកស្ទើរតែទាំងអស់បានអះអាងថាពួកគេគឺជាជនរងគ្រោះពិតប្រាកដ អ្នកដែលគួរតែត្រូវបានចាប់ខ្លួនគឺជនជាតិចិន។

នៅដើមឆ្នាំនេះ នគរបាលបានចាប់បានជនឆបោកជនជាតិថៃចំនួន២១ នាក់នៅក្នុងប្រទេសកម្ពុជា ដែលជាសមាជិកនៃក្រុមបីផ្សេងគ្នាក្រោមការគ្រប់គ្រងដោយជនជាតិចិន។ ប្រធានក្រុមការងារតាមអ៊ីនធឺណិតរបស់

នគរបាលបាននិយាយថាទំហំទឹកប្រាក់ដែលបានមកពីការឆបោកនេះមានប្រមាណជាង ៥០០ លានបាត (១៤ លានដុល្លារ)។ ការជួញដូរមនុស្សបានក្លាយជាបញ្ហាដែលកើតមានជាយូរមកហើយនៅអាស៊ីអាគ្នេយ៍។ ពេលនេះបណ្ដាញជនឧក្រិដ្ឋកំពុងស្វែងរកបន្ថែមទៀត ដើម្បីល្បួងជនរងគ្រោះប្រភេទផ្សេងគ្នា។ គោលដៅរបស់ពួកគេមានទំនោរទៅរកយុវជនក្មេងៗ មានចំណេះដឹងគ្រាន់បើ ចេះកុំព្យូទ័រ និងចេះនិយាយបានច្រើនភាសា។ ទាំងនេះត្រូវបានគេមើលឃើញថាជាយុទ្ធសាស្ត្ររបស់ក្រុមជនពាលដែលត្រូវការកម្លាំងពលកម្មមានជំនាញ ដើម្បីធ្វើសកម្មភាពឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត រួមមានការក្លែងបន្លំជារបៀបស្នេហា ការក្លែងបន្លំគ្រីបតូ ការលាងលុយកខ្វក់ និងល្បែងស៊ីសងខុសច្បាប់។ Thaiger

## ជនជាតិម៉ាឡេស៊ីសរុបចំនួន ២២៧នាក់ ដែលធ្លាក់ខ្លួនក្នុងការឆបោកនៅកម្ពុជា ត្រូវបានជួយសង្គ្រោះនៅឆ្នាំនេះ និងម្នាក់មិនទាន់បានរាប់បញ្ចូល

https://www.khmertimeskh.com/501208297//?p=1208297 December 25, 2022

ក្រសួងការបរទេស គិតត្រឹមថ្ងៃទី២០ ខែធ្នូ បានទទួលរបាយការណ៍សរុបចំនួន៤៨៨ នៃពលរដ្ឋម៉ាឡេស៊ីដែលជាជនរងគ្រោះនៃក្រុមបោកប្រាស់ការងារនៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងប្រទេសថៃ។ ស្ថិតិជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះមកដល់ពេលនេះមានចំនួន ២២៧ នាក់នៅកម្ពុជា ៦១ នាក់ (នៅឡាវ) ៣៨ នាក់ (នៅថៃ) និង ៣៣ នាក់ (នៅមីយ៉ាន់ម៉ា)។ សេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស បាននិយាយថា មនុស្សសរុបចំនួន៣៥៩ នាក់ត្រូវបានជួយសង្គ្រោះ ដោយ៣៣១ នាក់ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសម៉ាឡេស៊ី និង ២៨ នាក់ទៀតកំពុងត្រូវបានឃុំឃាំង ដើម្បីជួយដល់ការស៊ើបអង្កេត និងបញ្ហាទាក់ទងនឹងឯកសារ។

ក្រសួង តាមរយៈស្ថានទូតម៉ាឡេស៊ី នៅតាមបណ្តាប្រទេសពាក់ព័ន្ធ និងសហការយ៉ាងជិតស្និទ្ធជាមួយនគរបាលភូមិន្ទម៉ាឡេស៊ី (PDRM) នឹងបន្តកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីតាមដានជនរងគ្រោះចំនួន ១២៩ នាក់ផ្សេងទៀត ដែលមិនទាន់បានរាប់បញ្ចូល ពាក់ព័ន្ធនឹងប្រទេសកម្ពុជា (មួយករណី) ថៃ (៨ករណី) ឡាវ (២៩ ករណី) និងមីយ៉ាន់ម៉ា (៩១ករណី)។ "ក្រសួងក៏សង្ឃឹមផងដែរសម្រាប់កិច្ចសហប្រតិបត្តិការរបស់សាធារណជន ហើយត្រូវដឹង និងជូនដំណឹងជានិច្ច ទាក់ទងនឹងបញ្ហានៃក្រុមឧក្រិដ្ឋកម្មបោកប្រាស់ដែលផ្តល់ការងារនៅក្រៅប្រទេស។

សេចក្តីថ្លែងការណ៍បានសរសេរថា "ជនរងគ្រោះ ឬសមាជិកគ្រួសារដែលត្រូវបានគេសង្ស័យថាជាប់ពាក់ព័ន្ធក្នុងក្រុមឧក្រិដ្ឋជនទាំងនេះ ត្រូវបានស្នើសុំឱ្យរាយការណ៍ទៅនគរបាលភូមិន្ទម៉ាឡេស៊ី និង ក្រសួងការបរទេស ជាបន្ទាន់" ។ ជនរងគ្រោះ ឬញាតិសន្តានអាចរាយការណ៍ និងបញ្ជូនព័ត៌មានដែលពាក់ព័ន្ធទៅ ក្រសួងការបរទេស តាមរយៈអ៊ីមែល៖ bkrm@kln.gov.my ។

"ក្រសួងសូមថ្លែងអំណរគុណចំពោះនគរបាលភូមិន្ទម៉ាឡេស៊ី សម្រាប់វិធានការឆាប់រហ័ស និងបុរេសកម្មរបស់ពួកគេក្នុងការកំណត់ទីតាំង និងជួយសង្គ្រោះជនរងគ្រោះ ដែលជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធរបស់ក្រសួងការបរទេស ជាមួយស្ថានទូតម៉ាឡេស៊ីនៅទីក្រុងបាងកក។ "ទន្ទឹមនឹងនោះ ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរថៃ ចំពោះកិច្ចសហប្រតិបត្តិការ និងអាទិភាពក្នុងការជួយរដ្ឋាភិបាលម៉ាឡេស៊ី ជួយសង្គ្រោះជនរងគ្រោះពីក្រុមឆបោកនេះ។ សេចក្តីថ្លែងការណ៍បានបន្ថែមថា "ក្រសួងការបរទេស ក៏បានថ្លែងអំណរគុណចំពោះសមាជិកសភា Teruntum YB Tuan Sim Chon Siang ដែលបានបន្ថែមជំនួយរបស់គាត់ក្នុងការជួយនាំយកជនរងគ្រោះទៅផ្ទះ"។ Bernama

## កម្លាំងនគរបាលការពារព្រំដែន ឃាត់ខ្លួនជនជាតិឥណ្ឌូនេស៊ី៨នាក់ បម្រុងឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ ឯមេខ្យល់ រត់គេចខ្លួនបាត់

https://cen.com.kh/archives/594553.html Posted ByPen Srey NeatDecember 25, 2022

បន្ទាយមានជ័យ ៖ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៣ ម៉ោង១៨និង៣០នាទី កម្លាំងនគរបាលនៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១ និងកម្លាំងប៉ុស្តិ៍សិលាខ្មែរ បានស្ទាក់ឃាត់ជនជាតិឥណ្ឌូនេស៊ី ចំនួន០៨នាក់(ប្រុស)ខណៈពួកគេបម្រុងលួចឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ នៅត្រង់ចំណុចខាងលិចប៉ុស្តិ៍ប្រហែល ៥០០ម៉ែត្រ ភូមិសិលាខ្មែរឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។ ចំណែកមេខ្យល់បានគេចខ្លួនបាត់ ។ បន្ទាប់ពីឃាត់ខ្លួន ជនជាតិឥណ្ឌូនេស៊ីខាងលើត្រូវបានបញ្ជូនមកទីបញ្ជាការវរៈ ដើម្បីសួរនាំ និងផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន និងរង់ចាំបទបញ្ជាថ្នាក់លើអនុវត្តបន្តតាមនីតិវិធី ។

សូមបញ្ជាក់ថា យោងការណែនាំនិងការដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាលទាំងអស់ត្រូវទប់ស្កាត់បង្ក្រាប រាល់បទល្មើសឆ្លងដែនខុសច្បាប់ និងបទល្មើនានាកន្លងមក ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធលី

# ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០២២

## អាជ្ញាធរខេត្តកំពង់ធំ ក្រើនរំលឹកឱ្យពលរដ្ឋប្រយ័ត្នចំពោះជនខិលខូច ជៀសវាងធ្លាក់ក្នុងអំពើជួញដូរមនុស្ស

https://m.freshnewsasia.com/index.php/en/localnews/271360-2022-12-26-09-39-17.html 2022-12-26 04:39pm

**(កំពង់ធំ)៖** រដ្ឋបាលខេត្តកំពង់ធំ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ បានប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី១៦ ក្រោមប្រធានបទ **«រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ប្រកបដោយចីរភាព»** រួមជាមួយការដាស់តឿនក្រើនរំលឹកដល់ប្រជាពលរដ្ឋត្រូវបង្កើនការប្រុងប្រយ័ត្នចំពោះល្បិចកលថ្មីៗរបស់ខិលខូច ជៀសវាសធ្លាក់ខ្លួនក្នុងអំពើជួញដូរមនុស្ស។

នៅចំពោះមុខអ្នកចូលរួមប្រមាណ៤០០នាក់នាពិធីនោះ លោក ញឹក បានខេង អភិបាលរងខេត្តកំពង់ធំ បានថ្លែងថា ការលុបបំបាត់អំពើជួញដូរមនុស្ស គឺផ្តើមចេញពីបុគ្គលម្នាក់ៗ ដូច្នេះសូមប្រជាពលរដ្ឋគ្រប់រូបប្រុងប្រយ័ត្នចំពោះល្បិចកលថ្មីៗរបស់ជនល្មើសជួញដូរមនុស្ស។ លោកបានលើកឡើងថា ប្រជាជនមួយចំនួននៅតែមានបំណងចេញទៅរកការងារធ្វើនៅក្រៅប្រទេសដោយប្រថុយប្រថាន មិនស្តាប់ការអប់រំណែនាំមិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់និងជឿការអូសទាញភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់យ៉ាងធ្ងន់ធ្ងរ។

ជាមួយគ្នានោះ លោក ញឹក បានខេង បានជំរុញដល់ក្រុមការងារត្រូវយកចិត្តទុកដាក់បំពេញភារកិច្ចឱ្យបានល្អតាមតួនាទីដែលរាជរដ្ឋាភិបាលប្រគល់ឱ្យប្រកបដោយការទទួលខុសត្រូវ ខិតខំដោះស្រាយបញ្ហាដែលនៅសេសសល់ ដោយអនុវត្តតាមអភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល និងវះកាត់»** ដើម្បីធ្វើថ្នាក់ខ្លួនជាមន្ត្រីល្អ សក្តិសមនឹងការជឿទុកចិត្តពីរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ។ លោកបានជំរុញឱ្យសមត្ថកិច្ចពាក់ព័ន្ធត្រូវខិតខំតាមដានបាតុភាពនិងបទល្មើសផ្សេងៗ ដើម្បីទប់ស្កាត់មូលហេតុរួមផ្សំដែលនាំឱ្យមានអំពើជួញដូរមនុស្ស និងការរំលោភ

បំពានផ្សេងៗ។ ត្រូវពង្រឹងនិងតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនានាឱ្យមានប្រសិទ្ធភាព។ លោកបានបន្តថា សមត្ថកិច្ចពាក់ព័ន្ធមិនត្រូវព្រងើយកន្តើយ ឬគាំទ្រអំពើល្មើសដែលកើតមាន ត្រូវខិតខំរួមគ្នាដោះស្រាយផ្តល់យុត្តិធម៌ដល់អ្នកដែលរងគ្រោះ ព្រមាននិងដាក់ទោសជនល្មើសឱ្យសក្តិសមនឹងអំពើដែលបានប្រព្រឹត្ត ដើម្បីជាការលើកទឹកចិត្តដល់អំពើល្អ សុចរិតភាព និងយុត្តិធម៌ក្នុងសង្គម។

លើសពីនេះ លោកបានណែនាំឱ្យសមត្ថកិច្ចពាក់ព័ន្ធខិតខំផ្សព្វផ្សាយអប់រំតាមសាលារៀន តាមវេទិកាសហគមន៍នានា ជាពិសេសក្នុងគោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាព ឱ្យយល់ដឹងពីផលប៉ះពាល់នៃការប្រព្រឹត្តល្បែងស៊ីសងខុសច្បាប់ អំពើហិង្សា ការរំលោភបំពានលើស្ត្រី និងកុមារ អំពើជួញដូរមនុស្ស គ្រឿងញៀន និងគ្រឿងស្រវឹងគ្រប់ប្រភេទ៕

## ពលករកម្ពុជាកើនឡើងនៅក្រៅប្រទេស នាំឲ្យការផ្ញើប្រាក់មកស្រុកមានការកើនឡើង

https://www.khmertimeskh.com/501209287// December 27, 2022

កម្ពុជាកំពុងផ្សារភ្ជាប់នៅក្នុងតំបន់ ខណៈដែលប្រភពចម្បងនៃកម្លាំងពលករក្រៅស្រុកផ្ញើប្រាក់មកស្រុកជាច្រើន ដោយសារតម្រូវការពលករ បន្ទាប់ពីការងើបឡើងវិញ នៃពាណិជ្ជកម្ម និងសេដ្ឋកិច្ច ក្រោយពីការរាតត្បាតពីជំងឺកូវីដ-១៩។ យោងតាមក្រសួងការងារ ពលករផ្ញើប្រាក់មកស្រុកប្រហែល ២ ៧២០ លានក្នុងឆ្នាំនេះ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារមានប្រសាសន៍ថា ចំនួនពលករចំណាកស្រុកកើនឡើង ហើយបានផ្ញើប្រាក់រហូតដល់ ២,៧២០ លានដុល្លារពោលគឺកើនឡើង ៣,៤ ភាគរយ ខណៈកាលពីឆ្នាំមាន២,៦៣០លានដុល្លារ ។ ពួកគេក៏បាននាំនាំនូវគំនិតថ្មី ជំនាញ និងបទពិសោធន៍ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស។ លទ្ធភាពក្នុងការបញ្ជូនពលករទៅកូរ៉េខាងត្បូងត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំរវាងអភិបាលខេត្តកណ្តាល លោក គង់ សោភ័ណ និង លោក Choi Dong-in of Heupect នៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងការជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ នៅសាលាខេត្តកណ្តាល។ គោលបំណងនៃជំនួបពិភាក្សានេះ ដើម្បីពិនិត្យ ពិភាក្សាអំពីលទ្ធភាពនៃការបញ្ជូនពលករទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ និងជាឱកាសដ៏ល្អដល់យុវជន ប្រជាជននៅក្នុងមូលដ្ឋានខេត្ត ដើម្បីបង្កើនប្រាក់ចំណូលសេដ្ឋកិច្ចគ្រួសារ បង្កើនជំនាញ និងបទពិសោធន៍ ពិសេសដល់យុវជន ដើម្បីយកចំណេះដឹងទាំងនោះ មកជួយអភិវឌ្ឍមូលដ្ឋានខេត្តកណ្តាល ឲ្យកាន់តែរីកចម្រើនជាបន្តបន្ទាប់ថែមទៀត។

យោងតាមរបាយការណ៍ក្នុងខែសីហា ឆ្នាំ ២០២២ ពលករកម្ពុជាជាង ៤៦,៤៦០ នាក់បានធ្វើការនៅកូរ៉េក្នុងវិស័យឧស្សាហកម្ម កសិកម្ម និង សំណង់ ។ ពលករកម្ពុជាមានធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី ជប៉ុន កូរ៉េខាងត្បូង និង សិង្ហបុរី ។ យោងតាមរបាយការណ៍ ប្រជាជនកម្ពុជាធ្វើការនៅប្រទេសថៃមានចំនួន ១,២២ លាននាក់ កូរ៉េខាងត្បូងមានជាង ៤៦,០០០នាក់ ម៉ាឡេស៊ីមាន ២៣,០០០ នាក់ ជប៉ុនមាន ១១, 000 នាក់ និង ៨០០នាក់នៅសិង្ហបុរី ហើយភាគច្រើនគឺជាស្ត្រី។

កម្ពុជាទទួលស្គាល់ថា កំលាំងពលកម្មក្រៅស្រុករួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក៏ដូចជាកាត់បន្ថយភាពក្រីក្រផងដែរ។ ទន្ទឹមនឹងមានវិធានការមួយចំនួន ដើម្បីការពារផលប្រយោជន៍អ្នកស្វែងរកការងារធ្វើចំណាកស្រុក រដ្ឋាភិបាលក៏បានដាក់បង្ហាញ គោលនយោបាយស្តីពីការធ្វើចំណាកស្រុកសម្រាប់កម្ពុជាឆ្នាំ ២០១៩-២០២៣»។ លនយោបាយនេះមានបំណងពង្រឹងការគ្រប់គ្រប់ពលកម្មក្រៅស្រុក បង្កើនប្រសិទ្ធភាពក្នុងការការពារ ផ្សព្វផ្សាយសិទ្ធិ និងផលប្រយោជន៍ និងភ្ជាប់ការធ្វើចំណាកស្រុកទៅការនឹងការអភិវឌ្ឍ សង្គម និង សេដ្ឋកិច្ច៕ សុ ជាតា

# ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០២២

## កម្ពុជាមានគម្រោងបញ្ជូនពលករទៅធ្វើការនៅប្រទេសអ៊ីស្រាអែលនៅឆ្នាំក្រោយ

https://www.kampucheathmey.com/local-news/437774 ថ្ងៃអង្គារ ២៧ ធ្នូ២០២២ដោយ Sokhom Khon

កម្ពុជាមានគម្រោងបញ្ជូនពលករទៅធ្វើការនៅប្រទេសអ៊ីស្រាអែលនៅឆ្នាំ២០២៣ខាងមុខនេះ ដែលជាទីផ្សារថ្មីមួយទៀតដែលនឹងជួយលើកស្ទួយដល់ជីវភាពប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិកាន់តែប្រសើរឡើងថែមទៀត។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅព្រឹកថ្ងៃទី២៧ធ្នូនេះថា តាមគម្រោងយើងនឹងចាប់ផ្ដើមធ្វើការចរចារជាមួយប្រទេសអ៊ីស្រាអែល នៅដើមត្រីមាសទី៣ទៅលើនីតិវិធីនានាក្នុងការបញ្ជូនពលករដើម្បីធ្វើយ៉ាងណារៀបចំបញ្ជូនពលករយើងទៅធ្វើការឱ្យបាននៅឆ្នាំ២០២៣។ លោកបានបន្តថា « យើងកំពុងចចារជាមួយអ៊ីស្រាអែលនៅមិនទាន់បញ្ចប់នៅឡើយទេ ហើយក្នុងផែនការយើងបញ្ជូនពលករទៅក្នុងឆ្នាំ២០២៣នេះលើវិស័យកសិកម្ម»។ លោកបានបន្តទៀតថា អ៊ីស្រាអែលដែលជាប្រទេសមានការរីកចំរើនខ្លាំងលើវិស័យកសិកម្ម គឺជាទីផ្សារថ្មីមួយទៀតសម្រាប់ពលករកម្ពុជាក្នុងការទទួលបានបទពិសោធន៍ និងបច្ចេកទេសថ្មីៗបន្ថែមទៀតទាក់ទិននិងវិស័យកសិកម្ម។

យោងតាមរបាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា បច្ចុប្បន្ននេះមានពលករខ្មែរប្រមាណជាង១លាន៣សែននាក់ធ្វើការនៅក្រៅប្រទេស ក្នុងនោះនៅថៃមានច្រើនជាងគេហួតដល់ទៅចំនួន ១ ២២០ ១៩៧នាក់ នៅកូរ៉េខាងត្បូងមានជាង ៤៥០០០នាក់នៅម៉ាឡេស៊ីមាន២៣០២៧នាក់ នៅជប៉ុនមាន១១៤៥៣នាក់ នៅសិង្ហបុរីមាន៨២១នាក់ នៅចិនហុងកុង មាន២០២នាក់និងអារ៉ាប៊ីសាអូឌីត៤៣នាក់ដោយក្នុង១ឆ្នាំៗបានផ្ញើថវិកាមកក្រុមគ្រួសារវិញប្រមាណជាង៣ពាន់លានដុល្លារផងដែរ៕ អត្ថបទ៖ សំអឿន

## ក្រុងតៃប៉ិស្នើឲ្យមានការដាក់ទោសទណ្ឌធ្ងន់ធ្ងរជាងមុនចំពោះឧក្រិដ្ឋកម្មនៅបរទេស និងការឆបោកមនុស្ស

https://www.khmertimeskh.com/501209526// Khmer Times December 27, 2022

គណៈរដ្ឋមន្ត្រីតៃប៉ិបានស្នើដាក់ទោសទណ្ឌឱ្យកាន់តែធ្ងន់ធ្ងរ ចំពោះឧក្រិដ្ឋជនដែលពាក់ព័ន្ធនឹងការឆបោកប្រជាជនខ្លួនឱ្យប្រព្រឹត្តិបទល្មើសនៅក្រៅប្រទេស បន្ទាប់ពីប្រតិបត្តិការបោកប្រាស់ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជាមួយចំនួនត្រូវបានរកឃើញថាមានជនជាតិតៃវ៉ាន់បានចូលរួមផងដែរនោះ។ គណៈរដ្ឋមន្ត្រីបានឱ្យដឹងថា នៅក្រោមសំណើនេះ រាល់បទល្មើសពាក់ព័ន្ធនឹងការល្បួងជនជាតិតៃវ៉ាន់ឱ្យចូលរួមជាមួយអង្គការឧក្រិដ្ឋកម្មនៅក្រៅប្រទេសចិន នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៧ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២០លានដុល្លារតៃវ៉ាន់ (៦៥៣,៦៤៨ ដុល្លារ) ។ ប្រសិនបើជនល្មើសកំណត់គោលដៅលើជនរងគ្រោះដែលមានអាយុក្រោម ១៨ ឆ្នាំ ទោសនឹងត្រូវកើនឡើងពាក់កណ្តាល នេះបើយោងតាមវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំប្រចាំសប្តាហ៍របស់ខ្លួនកាលពីថ្ងៃទី១៥ខែធ្នូ។

យោងតាមច្បាប់ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម ការជ្រើសរើសមនុស្សឲ្យចូលរួមប្រព្រឹត្តិបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែទៅ៥ឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ១០លានដុល្លារតៃវ៉ាន់ ដោយមិនគិតពីថាតើឧក្រិដ្ឋកម្មកើតឡើងនៅតៃវ៉ាន់ ឬនៅក្រៅប្រទេសនោះទេ។ ទន្ទឹមនឹងនោះ វិសោធនកម្មបានចែងថា ទ្រព្យសម្បត្តិរបស់ក្រុមណាដែលគាំទ្រអង្គការឧក្រិដ្ឋកម្ម ដូចជាការផ្តល់មូលនិធិ ឬការជ្រើសរើសបុគ្គលិក នឹងត្រូវរឹបអូសបន្ទាប់ពី

សងសំណងដល់ជនរងគ្រោះ។ វិសោធនកម្មដែលព្រាងដោយក្រសួងយុត្តិធម៌នឹងត្រូវគណៈរដ្ឋមន្ត្រីបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិដើម្បីពិចារណា។

ក្រសួងបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា ប្រសិនបើវិសោធនកម្មត្រូវបានអនុម័ត ជនដែលត្រូវបានផ្តន្ទាទោសពីបទពាក់ព័ន្ធនឹងការជួញដូរជនជាតិតៃវ៉ាន់មកកម្ពុជា ដើម្បីប្រព្រឹត្តិបទល្មើសដូចជាការឆបោកតាមទូរគមនាគមន៍ ការកេងប្រវ័ញ្ចផ្លូវភេទ និងការវះយកសរីរាង្គនឹងត្រូវទទួលទោសធ្ងន់ធ្ងរជាងនេះ ។ គិតត្រឹមថ្ងៃទី១២ ខែធ្នូ រដ្ឋាភិបាលតៃវ៉ាន់បានជួយជនជាតិតៃវ៉ាន់ឱ្យវិលត្រឡប់មកប្រទេសកំណើតវិញមានចំនួន ៤០៣នាក់ ដែលភាគច្រើនត្រូវបានគេល្បួងមកប្រទេសកម្ពុជាដោយសន្យាផ្តល់ការងារដែលមានប្រាក់ខែខ្ពស់ ហើយបន្ទាប់មកពួកគេត្រូវបានបង្ខំឱ្យធ្វើការឱ្យក្រុមឧក្រិដ្ឋជន ប៉ុន្តែមនុស្សប្រហែល ៣០០ នាក់ត្រូវបានគេជឿថា ត្រូវបានគេបង្ខាំងនៅក្នុងប្រទេសកម្ពុជា នេះបើតាមលោក Wallace Chow អគ្គនាយកនៃនាយកដ្ឋានកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៃក្រសួងការបរទេសក្រសួងការបរទេស៕ Focus Taiwan

# ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០២២

## កិច្ចប្រជុំពង្រឹងវិធានការបង្ការ
## បង្ក្រាបបទល្មើសព្រហ្មទណ្ឌ បទល្មើសគ្រឿងញៀននិងប្រឆាំងការជួញដូរមនុស្ស

https://www.gdlf-kh.com/2022/12/28/-3/ Dy Ramorn មណ្ឌលគីរី

មណ្ឌលគីរី៖ នៅរសៀល ថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ នាវេលាម៉ោង២និង៣០នាទី នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី បានបើកកិច្ចប្រជុំពង្រឹងវិធានការ បង្ការបង្ក្រាបបទល្មើសព្រហ្មទណ្ឌនិងបទល្មើសគ្រឿងញៀននិងការជួញដូរមនុស្ស។

ពិធីនេះបានធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្ត និង មានការអញ្ជើញចូលរួមពីលោក លោកស្រីស្នងការរងព្រមទាំងនាយនាយរងការិយាល័យ លោកនាយ នាយរងផ្នែកនិងមន្ត្រីទាំងអស់ ក្នុងផែនការងារនគរបាលព្រហ្មទណ្ឌលោក ស្នងការរង ទទួលដឹកនាំការិយាល័យចរាចរណ៍ផ្លូវគោកលោកនាយ នាយរងការិយាល័យនាយផ្នែក ចំណុះការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក លោក អធិការ អធិការរងទទួលការងារព្រហ្មទណ្ឌ លោកអធិការរងទទួលការងារប្រឆាំងគ្រឿងញៀន លោកអធិការរងទទួលការងារប្រឆាំងការជួញដូរមនុស្ស, លោកអធិការរងទទួលការងារចរាចរណ៍ផ្លូវគោក, លោកនាយផ្នែកចំណុះការងារជំនាញទាំង៤ នៃអធិការដ្ឋាននគរបាល, ក្រុង/ស្រុក ទាំង៥លោក នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់ ទាំង២១ ដែលបានចូលរួមសរុបចំនួន៩៧នាក់។

ជាកិច្ចចាប់ផ្តើមបើកកិច្ចប្រជុំលោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្តបានមានប្រសាសន៍បើកកិច្ចប្រជុំនិងបានអនុញ្ញាតឲ្យលោក លោកស្រីស្នងការរងព្រមទាំង លោកអធិការនគរបាល ក្រុង/ស្រុក លើកឡើងអំពីបញ្ហាប្រឈមមួយចំនួនពីការរៀបចំផែនការ សកម្មភាពយកមកដោះស្រាយមិនតែប៉ុណ្ណោះ លោកឧត្តមសនីយ៍ទោ ស្នងការបានមានប្រសាសន៍ជំរុញដល់លោក លោកស្រីស្នងការរងដែលទទួលការងារនៅតាមបណ្តាផែនទាំងបី ព្រមទាំងលោកអធិការក្រុង/ស្រុកទាំង៥ ឲ្យយកចិត្តទុកដាក់និងតម្លើងបញ្ជីឈ្មោះ ដើម្បីយកមករាយការណ៍ជូនលោកស្នងការ នូវរាល់ការខ្វះខាតកម្លាំងមន្ត្រីនគរបាលនៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់ ដើម្បីងាយស្រួលក្នុងការបំពេញបន្ថែមក៏ដូចជា ងាយស្រួលក្នុងការបង្ការបង្ក្រាបទប់ស្កាត់នៅរាល់បទល្មើសនានា នៅមូលដ្ឋានគ្រប់គ្រងរបស់ខ្លួនទាន់សភាពការណ៍។

លោកក៏បានលើកយកនូវប្រសាសន៍ល្អៗពីវិន័យ ០០៦ យកមកលាតត្រដាងដើម្បីជាសារដាស់តឿងដល់មន្ត្រីនគរបាលទាំងអស់ឲ្យយកទៅអនុវត្តន៍និងគោរពឲ្យបានខ្ជាប់ខ្ជួន ដើម្បីយកបំរើនិងការពារបងប្អូនប្រជាពលរដ្ឋយើង។ មុនបញ្ចប់លោកឧត្តមសេនីយ៍ទោស្នងការក៏បានថ្លែងនូវអំណរគុណ និងជូនពរដល់កងកម្លាំងមន្ត្រីនគរបាលរដ្ឋបាលទាំងអស់ឲ្យជួបតែសេចក្តីសុខចម្រើនគ្រប់ៗគ្នា៕

# ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២២

## ជនជាតិថៃ២៤នាក់ដែលត្រូវបានចាប់ខ្លួននៅមជ្ឈមណ្ឌលហៅទូរស័ព្ទឆបោកនៅកម្ពុជា ប្រឈមនឹងការចោទប្រកាន់ពីបទឆបោកនៅពេលត្រឡប់មកដល់ប្រទេសវិញ

https://www.khmertimeskh.com/501210834// Khmer Times December 29, 2022

ក្នុងប្រតិបត្តិការរួមគ្នារបស់នគរបាលកម្ពុជា-ថៃ កាលពីខែមិថុនា ឆ្នាំនេះនៅក្រុងព្រះសីហនុ ម្នាក់ឈ្មោះ Nokyoong អាយុ២៦ ឆ្នាំ ជាជនជាតិថៃ ជាស្ត្រីមេម៉ាយមានកូនបីនាក់ និងបងប្អូនជីដូនមួយរបស់នាងឈ្មោះ Neung អាយុ៤០ ឆ្នាំ ត្រូវបាននគរបាលវាយឆ្មក់ និងឃាត់ខ្លួននៅកន្លែងធ្វើការហៅទូរស័ព្ទដែលពួកគេបានធ្វើការអោយ ហើយក្នុងចំណោមអ្នកត្រូវបានចាប់ខ្លួនមានជនជាតិថៃ ៧៤ នាក់ត្រូវបានឃុំខ្លួន។ ពេលត្រលប់មកដល់ប្រទេសថៃវិញ ពួកគេកំពុងត្រូវបានចោទប្រកាន់ដោយតុលាការ រួមជាមួយនឹងមនុស្ស២២ នាក់ផ្សេងទៀតដើម្បីកំណត់ថាតើពួកគេជាជនរងគ្រោះ ឬឧក្រិដ្ឋជនដែលបន្លំខ្លួនជាជនរងគ្រោះ។ ការកាត់ក្តីរបស់ពួកគេនឹងមិនចាប់ផ្តើមរហូតដល់ចុងខែឧសភា ឆ្នាំ២០២៣។ នគរបាលគិតឃើញផងដែរថាជនរងគ្រោះមួយចំនួនគឺជាសមាជិកនៃក្រុមឆបោក។

Jaruwat Jinmonca សហស្ថាបនិកនៃអង្គការប្រឆាំងការជួញដូរមនុស្សនៃមូលនិធិ Immanuel របស់ប្រទេសថៃនិយាយថា ករណីរបស់ Nokyoong និង Neung គឺជារឿងគួរឱ្យភ័យខ្លាច។ អង្គការរបស់លោកបានជួយសង្គ្រោះជនរងគ្រោះថៃចំនួន ៣៧៤ នាក់ពីការជួញដូរមនុស្សនៅអាស៊ីអាគ្នេយ៍ក្នុងឆ្នាំនេះ ហើយបន្តជួយអ្នកដែលជាប់ពាក់ព័ន្ធនឹងការចាញ់បោកដើម្បីការពារខ្លួននៅក្នុងតុលាការ។ លោកបានបន្តថា "យើងបានធ្វើការជាមួយនគរបាល យើងបានប្រាប់ថាពួកគេជាជនរងគ្រោះ យើងបានបង្ហាញភស្តុតាងដល់ពួកគេ ប៉ុន្តែនគរបាលមិនស្តាប់ទេ នគរបាលនៅតែចោទប្រកាន់ពួកគេ"។ "នគរបាលមានគោលដៅរបស់ពួកគេ ពួកគេបានកំណត់គោលដៅកម្ចាត់មជ្ឈមណ្ឌលហៅទូរស័ព្ទខុសច្បាប់ ប៉ុន្តែពួកគេមិនបានព្យាយាមយល់ពីស្ថានភាពរបស់ជនរងគ្រោះនោះទេ។"

យោងតាមរបាយការណ៍ ស្តីពីការជួញដូរមនុស្សឆ្នាំ២០២២ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ប្រទេសកម្ពុជា មីយ៉ាន់ម៉ា វៀតណាម ប្រ៊ុយណេ និងម៉ាឡេស៊ី បានបរាជ័យក្នុងការបំពេញតាមស្តង់ដារអប្បបរមាក្នុងការលុបបំបាត់ការជួញដូរ ហើយត្រូវបានជាបចំណាត់ថ្នាក់ទាបបំផុតលំដាប់ទី៣ ។ ប្រទេសថៃត្រូវបានជាប់លំដាប់ប្រភេទទី២ ដោយរបាយការណ៍បានកត់សម្គាល់ថា ប្រទេសនេះ «មិនបានបំពេញតាមស្តង់ដារអប្បបរមាបានពេញលេញទេ ប៉ុន្តែ [កំពុង] ប្រឹងប្រែង»។ វាបានកត់សម្គាល់ពីការថយចុះនៃការកាត់ទោស និងការផ្តន្ទាទោសបើធៀបនឹងឆ្នាំមុន ការលំបាកក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការផ្តល់សេវាមិនបានគ្រប់គ្រាន់ដល់ជនរងគ្រោះគឺជាបញ្ហាដែលគួរឱ្យព្រួយបារម្ភ។ របាយការណ៍នេះបានកោតសរសើរដល់ប្រទេសថៃក្នុងការស៊ើបអង្កេតប្រឆាំងនឹងមន្ត្រីពុករលួយ និងបានកាត់ទោសមនុស្សពីរនាក់ឲ្យជាប់ពន្ធនាគារ ប៉ុន្តែត្រូវប្រឹងប្រែងបន្ថែមទៀត។ របាយការណ៍បានបន្តថា៖ «អំពើពុករលួយបន្តធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស។

អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ Tamasak Wicharaya ដែលមើលការខុសត្រូវលើការប្រឆាំងការជួញដូររបស់រដ្ឋាភិបាលបាននិយាយថា រដ្ឋាភិបាលថៃមានច្បាប់សម្រាប់បង្ក្រាបមន្ត្រីពុករលួយនៅក្នុងតំបន់នេះ។ ឧត្តមសេនីយ Tamasak បានបន្តថា អាជ្ញាធរថៃត្រូវតែធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ រួមទាំងដំណើរការពិនិត្យជនរងគ្រោះអោយបានទូលំទូលាយ។ លោកបានបន្ថែមថា "មនុស្សជាច្រើនគឺជាជនស្លូតត្រង់ ត្រូវបានគេជួញដូរ [ខណៈដែល] ស្វែងរកការងារ ដូចជាការធ្វើការនៅក្នុងកន្លែងកម្សាន្ត ប៉ុន្តែអ្នកខ្លះបានក្លាយជាសមាជិកនៃក្រុមជនពាល" ។ «អ្នកខ្លះទទួលបានប្រាក់ចំណូលពីបទឧក្រិដ្ឋ ហើយដូច្នេះ ពួកគេមិនមែនជាជនរងគ្រោះទៀតទេ។ "នេះជាស្ថានភាពដ៏ផ្តាំផ្តង និងស្មុគស្មាញខ្លាំងណាស់ ប៉ុន្តែយើងត្រូវតែមានភាពមិនលម្អៀង"។

Nokyoong និង Neung បានបញ្ជាក់ថា ពួកគេត្រូវបានក្រុមជនពាលអោយប្រាក់ខ្លះក្នុងអំឡុងពេលដែលពួកគេជាប់នៅទីនោះ ដែលស្មើនឹងប៉ុន្មានរយដុល្លារប៉ុណ្ណោះក្នុងមួយខែ។ ពួកគេសង្ឃឹមថា ការពិតនេះនឹងមិនបិទបាំងសំណុំរឿងព្រហ្មទណ្ឌរបស់ពួកគេឡើយ។ លោកបានបន្ថែមថា ប្រទេសថៃកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីជួយជនរងគ្រោះ និងព្យាយាមតាមដានបណ្តាញឧក្រិដ្ឋកម្មឆ្លងដែនដែលកំណត់គោលដៅលើពួកគេ។ នៅក្នុងឆ្នាំថ្មីនេះ ប្រទេសថៃនឹងបើកមជ្ឈមណ្ឌលឧត្តមភាពក្នុងទីក្រុងបាងកក ដើម្បីប្រឆាំងការជួញដូរមនុស្ស ដោយលោកឧត្តមសេនីយ៍ Tamasak សង្ឃឹមថានឹងក្លាយជា "ស្ថាប័ន" ដោះស្រាយបញ្ហានៅក្នុងតំបន់។

អូស្ត្រាលីនឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីជួយដល់ប្រទេសថៃក្នុងការបង្កើតមជ្ឈមណ្ឌល និងធ្វើឱ្យមជ្ឈមណ្ឌលនេះដំណើរការ និងជួយបង្កើតកម្មវិធីសិក្សាជាតិថ្មីសម្រាប់ប្រឆាំងការជួញដូរ ដោយផ្តោតលើវិធីសាស្ត្រផ្អែកលើយេនឌ័រ និងជាមជ្ឈមណ្ឌលជួយជនរងគ្រោះ។ ជាមួយនឹងការចោទប្រកាន់ពីការឆបោករបស់ពួកគេនៅតែបន្តព្យួ Nokyoong និង Neung នៅតែមានភាពភ័យខ្លាចពីការចាប់ខ្លួននេះ។ Nokyoong បាននិយាយថា៖ « ឥឡូវនេះយើងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋហើយមិនអាចដាក់ពាក្យសុំការងារបានទេ យើងពិតជាមិនអាចធ្វើអ្វីបានទាំងអស់។ បងប្អូនជីដូនរបស់នាងភ័យខ្លាចដែលនគរបាលមិនអាចចាប់បានមេក្លោង ប៉ុន្តែពួកគេសង្ឃឹមថាអ្នកដទៃនឹងអាចរៀនពីបទពិសោធន៍របស់ពួកគេ។ នាងបានបន្តថា៖«ខ្ញុំចង់ដាស់តឿនប្រជាពលរដ្ឋកុំចាញ់បោកដែលថាផ្តល់ ការងារល្អ លុយច្រើន វាមិនមែនបែបនោះទេ វាជាការងារទាសករ» ។ Nokyoong បានក្រើនរំលឹកអ្នកដ៏ទៃឱ្យគិតបានហ្មត់ចត់មុននឹងសម្រេចទទួលយកអ្វីមួយ។ នាងបាននិយាយថា "មានអ្នកបោកប្រាស់ជាច្រើននៅទីនោះ ហើយខ្ញុំមិនចង់ឱ្យនរណាម្នាក់ឆ្លងកាត់អ្វីដែលពួកយើងបានឆ្លងកាត់នោះទេ៕ *ABC*

## ពលករខ្មែរ ៣០០០នាក់ នឹងទៅធ្វើការនៅអ៊ីស្រាអែល ឆ្នាំ២០២៣

https://www.khmertimeskh.com/501211282// ខ្មែរថាមស៍ December 30, 2022

កម្ពុជានឹងបញ្ជូនពលករ៣,០០០ នាក់ទៅកាន់ប្រទេសអ៊ីស្រាអ៊ែល ក្រោយកិច្ចសន្យាការងាររយៈពេល៥ឆ្នាំចាប់ពីឆ្នាំទៅ ខណៈដែលជាផ្នែកមួយនៃជាជំរុញតាមរយៈការបញ្ជូនពលកររវាងរដ្ឋ និងរដ្ឋផ្ទាល់។ យោងតាមក្រសួងការងារ ពលករកម្ពុជានឹងត្រូវបានបញ្ជូនទៅធ្វើការនៅវិស័យកសិកម្មនៅអ៊ីស្រាអ៊ែល។ អ៊ីស្រាអ៊ែលត្រូវបានគេទទួលស្គាល់ជាប្រទេសកសិកម្មបច្ចេកវិទ្យាខ្ពស់ ហើយជាប្រទេសផលិតកសិកម្មនៅលើពិភពលោក។ ការចរចារជាមួយរដ្ឋាភិបាលអ៊ីស្រាអ៊ែលគឺជិតរួចរាល់ហើយដែលថាពលករកម្ពុជាត្រូវបានការពារ ដោយរដ្ឋាភិបាលអ៊ីស្រាអ៊ែលតាមច្បាប់ការងារ។ ចំពោះផ្នែកកសិកម្មនេះ រដ្ឋាភិបាលអ៊ីស្រាអែល ចង់អនុវត្តប្រព័ន្ធបញ្ជូនជារបៀប G2G (ការបញ្ជូនពលកររវាងរដ្ឋ និងរដ្ឋផ្ទាល់) ដោយធ្វើដូចសាធារណរដ្ឋកូរ៉េដែរ។ រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីស្រាអែល បាន និងកំពុងពិភាក្សាគ្នាលើទម្រង់នៃប្រព័ន្ធបញ្ជូននេះ។

នៅឆ្នាំ២០២៤ អ៊ីស្រាអែល អាចនឹងបង្កើនចំនួនកសិកម្ម ព្រមទាំងបើកទីផ្សារផ្នែកសំណង់ ហើយគ្រោងយកពលករពីកម្ពុជាទៅប្រមាណ ៥០០០នាក់ផងដែរ។ រដ្ឋាភិបាលអ៊ីស្រាអ៊ែលនៅក្នុងឆ្នាំនេះបានយល់ស្របក្នុងការបង្កើតកូតាសិស្សរយៈពេល៥០ឆ្នាំក្នុងមួយឆ្នាំ ទៅ ២៥០ ក្នុងមួយឆ្នាំ សម្រាប់ប្រជាជនកម្ពុជា។

រដ្ឋាភិបាលកម្ពុជាបានស្នើទៅរដ្ឋាភិបាលអ៊ីស្រាអ៊ែល ដើម្បីបង្កើតមជ្ឈមណ្ឌលសម្រាប់ការបណ្ដុះបណ្ដាលបច្ចេកវិទ្យាកសិកម្ម និង រដ្ឋបាលនៅកម្ពុជា។ បច្ចេកវិទ្យាទំនើបពីអ៊ីស្រាអ៊ែល គឺត្រូវបានរំពឹងទុកក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មជាមួយនឹងគម្រោងធ្វើទំនើបកម្មកម្ពុជា។ ក្រៅពីនេះ កម្ពុជា និង អ៊ីស្រាអ៊ែល បានយល់ស្របក្នុងកិច្ចសហប្រតិបត្តិការផ្សព្វផ្សាយនៅក្នុងវិស័យម្ហូបអាហារ និង សន្តិសុខទឹកនៅក្នុងសហគមន៍ព្រៃឈើ។

ភាគីទាំងពីរបានយល់ព្រមក្នុងការបង្កើតក្រុមបច្ចេកទេសដើម្បីរៀបចំMoU សម្រាប់ស្ថេរភាព រួមទាំង កិច្ចសហប្រតិបត្តិការអភិវឌ្ឍកសិកម្មភាពធន់។ ជាមួយគ្នានេះ នៅក្នុងឆ្នាំ ២០២៣ ក្រសួងការងារកម្ពុជានឹងពង្រីកកិច្ចដោយឡែកនៅឆ្នាំ២០២៣ ក្រសួងការងារក៏បានពង្រីកសហប្រតិបត្តិការ ដែលមានចែងក្នុង MoU ជាមួយសាធារណរដ្ឋកូរ៉េស្រាប់ ដោយបង្កើនទីផ្សារការងារតាមរដូវកាល ជាមួយបណ្ដាក្រុង និងស្រុកនានាក្នុងប្រទេសនេះ តាមរយៈគណកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅធ្វើការងារនៅបរទេស(MTOSB)។ បច្ចុប្បន្នក្រុង និងស្រុកនានា នៃសាធារណរដ្ឋកូរ៉េ បានស្នើសុំពលករតាមតម្រូវការ ដែលភាគច្រើនខាងផ្នែកកសិកម្មប្រមាណ ៤០០០នាក់៕ ប្រែសម្រួលដោយ៖ សុ ជាតា